ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 30-Jan-2017, 14:05
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៤៦៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆរ័ន្ត

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ចូសេហ្វ អេនឌ្រូ បិយលី | អង់គ្លេស |
| លោក នីកូឡាស គូមជែម | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ប៉ែន សុចាន់ (2-TCCP-298) | ខ្មែរ |
| លោក ជាល ជឿន (2-TCW-960) | ខ្មែរ |

# ខ្ទបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ÷ លោកស្រី ប៉ែន សុចាន់** (2-TCCP-298)

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី ........ ទំព័រ ៣
សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្តើមពី ........ ទំព័រ ៦
សួរដោយលោក គង់ សំអុន ផ្តើមពី ........ ទំព័រ ៣៩
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី ........ ទំព័រ ៤៥

**ការសួរសំណួរទៅសាក្សី÷ លោក ជាល ជឿន** (2-TCW-960)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៦៩
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ៧២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-960។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ លើកលែងតែលោក លីវ សុវណ្ណ មេធាវីការពារក្ដីឱ្យលោក នួន ជា អវត្តមាន ដោយមូលហេតុសុខភាព។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺលោកស្រី ប៉ែន សុចាន់។ លោកស្រីមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។

[០៩:០៣:៤២]

នៅថ្ងៃនេះដែរមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-960។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព្រឹកនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឯម ហ៊ីយ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការ ដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ បានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះ ហើយនិងវិលមុខពេលអង្គុយ និងបានផ្តល់អនុសាសន៍ថា សូមឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:០៥:១២]

ផ្អែកលើមូលដ្ឋាននេះ និងយោងបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

មុននឹងផ្តល់វេទិកាជូនទៅភាគីមេធាវីការពារក្តី អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកស្រីចៅក្រម ហ្វេនស៍ ដើម្បីសួរសំណួរមួយចំនួន ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន ហើយសូមជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំមានសំណួរបន្តិចបន្តួចទេ។ ហើយគោលដៅនៃការសួររបស់ខ្ញុំ គឺដើម្បីស្វែងរក ថាតើអាជ្ញាធរ<ដែលពាក់ព័ន្ធនឹង>ការរៀបចំពិធី<រៀបការលោកស្រីនោះបានដឹងពីអាយុរបស់លោកស្រី>ដែរឬក៏អត់។ ខ្ញុំមានសំណួរពីរបីដែលត្រូវសួរ ហើយម្សិលមិញ លោកស្រីបានប្រាប់ថា នៅពេលដែលបានរៀបការ គឺលោកស្រីអាយុ១៥, ១៦ឆ្នាំប៉ុណ្ណោះ។ តើខ្ញុំចាំអ៊ីចឹង ត្រឹមត្រូវទេ?

[០៩:០៦:៣៣]

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស លោកស្រី ត្រឹមត្រូវ។

**ស៖** លោកស្រីក៏បានប្រាប់យើងម្តងថា លោកស្រីនៅពេលនោះ នៅក្នុងកងកុមារ។ តើខ្ញុំចាំត្រឹមត្រូវទេ? ហើយទី២ ប្រសិនបើលោកស្រីនៅក្នុងកងកុមារហ្នឹង តើនៅពេលដែលលោកស្រីរៀបការហ្នឹង លោកស្រីស្ថិតនៅក្នុងកងកុមារហ្នឹងដដែល ឬមួយក៏យ៉ាងម៉េច?

**ឆ៖** ចាស អត់ទេលោកស្រី គេបញ្ជូនខ្ញុំទៅបានប្រហែលជា៣ខែចាស។ ចេញពីកងកុមារទៅនៅកងចល័ត ៣ខែចាស។

**ស៖** ខ្ញុំសូមបញ្ជាក់បន្តិច នៅពេលដែលលោកស្រីរៀបការហ្នឹង តើលោកស្រីនៅក្នុងកងចល័តឬក៏កងកុមារ?

**ឆ៖** ចាស ខ្ញុំនៅកងចល័ត។

**ស៖** តើ<>មានកំណត់អាយុមនុស្ស<ច្បាស់លាស់ទេ>នៅក្នុងកងចល័ត<នោះ> ឬមួយក៏មនុស្ស<គ្រប់>អាយុ<ទាំងអស់នៅក្នុង>កងចល័ត<នេះ>?

**ឆ៖** កាលនោះ គេអត់បានកំណត់ថា អាយុប៉ុន្មានទៅប៉ុន្មានទេ លោកស្រី។ គេអាចយកចាប់បញ្ជូនទៅទាំងអស់។

[០៩:០៨:០៣]

**ស៖** បើអ៊ីចឹង គឺបានន័យថា លោកស្រីនៅក្នុងកងចល័តបាន៣ខែ <>មុន <និងក្រោយពេល

លោកស្រី>នៅក្នុងកងកុមារ <ឬក៏ខ្ញុំយល់ច្រឡំទេ>?

**ឆ៖** កាលនោះខ្ញុំនៅក្នុងកងកុមារ តែយើង គេមើលឃើញថាយើងទូលទន្ត្រានខេត្តលែងសម ហើយ គេឲ្យយើងទៅកងចល័ត។ ដល់ពេលអ៊ីចឹង ខ្ញុំចេញពីកងកុមារ ខ្ញុំនៅកងចល័តជាមួយមេកង អ៊ុំហ្នឹងរហូត នៅភូមិដើមរកា។

**ស៖** ខ្ញុំយល់ ប៉ុន្តែតើនៅក្នុងកងកុមារហ្នឹងអាយុប៉ុន្មានឆ្នាំ បានគេឲ្យនៅក្នុងកងកុមារហ្នឹង?

**ឆ៖** នៅប្រហែលជាអាយុ១៤ ទៅ១៥ឆ្នាំ ចាស។

**ស៖** អ៊ីចឹងនៅពេលដែលគេបញ្ជូនទៅកងចល័តហ្នឹង បានន័យថា អាជ្ញាធរ គេមើលឃើញថា លោកស្រីហ្នឹង គឺមើលទៅពេញវ័យហើយ។ ប៉ុន្តែសួរថាតើ<គេ>សម្រេច<ដោយរបៀបណា>ថា <លោកស្រីគ្រប់អាយុនោះ? តើពួកគេបាននិយាយថា "ឥឡូវអ្នកឯងអាយុ១៥ឆ្នាំហើយ អ៊ីចឹងអ្នកឯងត្រូវទៅ?" ឬក៏ពួកគេនិយាយថា "មើលទៅអ្នកឯងគ្រប់អាយុហើយ អ្នកឯងពេលនេះទៅកងចល័ត?" តើលោកស្រីដឹងទេ ថា>អាជ្ញាធរគេសម្រេចថាយ៉ាងម៉េច <នៅពេលគេ>ប្តូរពីកងកុមារ ទៅកងចល័តហ្នឹង? តើគេមានលក្ខណៈអីវាយតម្លៃអីដែរឬទេ?

[០៩:០៩:៤៣]

**ឆ៖** ចាស អង្គាល់នុំងគេគ្មានកង ក្រុមណាទេ គ្រាន់តែថាមានប្រធានគេប្រជុំថា មើលមិត្តណារាងធំជាង បញ្ជូនទៅកងចល័តទៅ ព្រោះកងចល័តអត់មានអ្នកធ្វើការធំៗទេ។ ឥឡូវកងចល័តក៏គេចេញអស់ ឥឡូវចង់រើសកងចល័តបន្ថែម នៅក្នុងសាលារៀននេះ មានអ្នកធំៗដែរអត់? ដល់អ៊ីចឹងគ្រូអ្នកអប់រំសាលាហ្នឹង មិនបានបង្រៀនអក្សរ ក៏មិនបានធ្វើអីដែរ គ្រាន់តែថាបានដើរទូលតែទន្ត្រានខេត្តមកចិញ្ច្រាំជី ហើយនិងហូបបាយទឹកបបរហ្នឹងឯង តែគ្មានអ្នកណាគេចាត់ចែងថាយើងទៅត្រង់នេះ គេមានតែមេគេមកស្នើថា កងកុមារនេះមានមនុស្សធំល្មមចេញទៅកងចល័តបានហើយនៅ? ហើយអ៊ីចឹងគ្រូយើងថាមានពីរបីនាក់ដែរ អ៊ីចឹងគេសុំរើសយក គេដឹកយើងចេញទៅ។ គេឲ្យយើងរៀបចំសាក់កាដូ តែយើងខ្ញុំគ្មានសាក់កាដូអីទេ មានតែខោអាវមួយចង្កេះឆ្អេះនឹងខ្លួន ចេញទៅ មានក្រមា មុងមួយដែលជាប់នឹងក។

**ស៖** តាមដែលលោកស្រីដឹង គឺបានន័យថា គេមិនសម្រេចទៅលើអាយុទេ គេគ្រាន់តែផ្អែកទៅលើរូបរាងខាងក្រៅ រូបរាងមើលទៅឃើញថាយ៉ាងម៉េច អីយ៉ាងម៉េចអ៊ីចឹងមែនទេ?

**ឆ៖** គេមើលឃើញថា ដូចថាយើងហ្នឹងទូលទន្ត្រានខេត្ត យើងអង្គុយលេងដីលែងសមអីជាមួយក្មេងៗអ៊ីចឹង យើងរើសអាចម៍គោរាងធំជាងគេអ៊ីចឹង គេចាត់ចែង គ្រូប្រើឲ្យទៅកងចល័តហើយចាស។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** អ៊ីចឹងឥឡូវខ្ញុំត្រឡប់មកសួរឡើងវិញ ថាតើអាជ្ញាធរ នៅពេលដែលគេរៀបការលោកស្រីហ្នឹង គេដឹងថាលោកស្រីអាយុប៉ុន្មានឆ្នាំទេ? ឥឡូវខ្ញុំសួរលោកស្រីអ៊ីចេះ តើពួកគេមានសួរលោកស្រីនៅពេលហ្នឹងថា លោកស្រីអាយុប៉ុន្មានឆ្នាំទេ?

**ឆៈ** គេគ្មានបានសួរនាងខ្ញុំទេ បើបានគេសួរខ្ញុំ ខ្ញុំអាចដឹងជាមុន នេះគេអត់បានសួរទេ។

**សៈ** អ៊ីចឹងឥឡូវខ្ញុំចង់សួរបន្តទៀត តើលោកស្រីមានប្រាប់គេទេ? ម្សិលមិញលោកស្រីថា លោកស្រីប្រាប់គេថា មិនទាន់ចង់រៀបការទេ ព្រោះមិនទាន់ពេញវ័យ។ តើលោកស្រីមានប្រាប់គេថា លោកស្រីអត់ចង់រៀបការទេ ព្រោះលោកស្រីអាយុទើប១៥, ១៦ឆ្នាំ? អ៊ីចឹងប៉ុន្តែខ្ញុំចង់សួរថា នៅពេលដែលគេឱ្យលោកស្រីរៀបការហ្នឹង លោកស្រីមានប្រាប់គេពីអាយុរបស់លោកស្រីដែរឬទេ?

[០៩:១២:៣២]

**ឆៈ** គេមិនដែលមកយកចិត្តទុកដាក់នឹងយើង អាយុប៉ុន្មាននឹងអាយុប៉ុន្មាន តែគេគ្រាន់តែហៅយើងទៅ គឺយើងដឹងខ្លួនរបស់យើង នៅក្នុងឃើញគេបើកខោអាវ ហើយគេថាឱ្យចូលទៅអង្គុយរៀបការរៀប អង្គការកំណត់ឱ្យមានគ្រួសារ។ ភាសាការគឺអត់មានទេ មានតែកំណត់ឱ្យមានគ្រួសារចាស។

**សៈ** តាមលោកស្រីដឹង តើគេមានកម្រិតអាយុក្នុងការរៀបការដែរឬទេ? តើមានច្បាប់ ឬក៏មានគោលការណ៍អ្វីដែលគេកំណត់ថា មនុស្សម្នាក់ហ្នឹងទាល់តែមានអាយុប៉ុណ្ណេះប៉ុណ្ណោះបានអាចរៀបការបាន ឬមួយក៏គេអត់មានកំណត់អីទេ?

**ឆៈ** សម័យនោះ គេអត់មានឱ្យយើងដឹងខ្លួនទេ ក៏គេមិនបានសួរដែរចាស។ គេគ្មានចាត់ចែងថាឱ្យយើងដឹង ឱ្យយើងមានមេកងមេអីណា គ្មានមេបាអាចារ្យអីដូចសម័យនេះទេចាស។

**សៈ** ខ្ញុំប្រហែលជាសួរមិនច្បាស់ ខ្ញុំចង់ដឹងថាតើមានច្បាប់ ឬក៏បញ្ញត្តិអ្វីមួយថា ស្ត្រីម្នាក់ទាល់តែមានអាយុ១៨ឆ្នាំឡើង បាន១រៀបការដែរឬទេ នៅសម័យនោះ?

**ឆៈ** សម័យនោះគ្មានច្បាប់ទេ។ ដូចខ្ញុំបាននិយាយហើយ គេថាអង្គការត្រូវតែកំណត់ ហើយខ្ញុំគ្មានសិទ្ធិដឹងឮអីទាំងអស់ ព្រោះយើងនៅតូច អត់មានដឹងថាអ្នកណាប្រធាន អ្នកណាបង្ខំអ្នកណា គឺខ្ញុំអត់បានចាប់អារម្មណ៍ទេចាស។

[០៩:១៤:៣០]

**សៈ** ខ្ញុំដឹងថានៅពេលនោះលោកស្រីក្មេង ប៉ុន្តែមុនរបបខ្មែរក្រហម លោកស្រីដឹងទេថា មុនរបបខ្មែរក្រហមអាយុប៉ុន្មានឆ្នាំដែរ បាននារីៗគេរៀបការ?

**ឆ៖** ខ្ញុំអត់ដែលបានចាប់អារម្មណ៍ទៅខាងហ្នឹង ខ្ញុំអត់ដឹងថាប៉ុន្មានគេរៀបការ ប៉ុន្មានរៀបការ គឺខ្ញុំអត់បាននឹកឃើញទៅអ៊ីចឹងចាស។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មិនអីទេលោកស្រី ខ្ញុំសូមបញ្ចប់ការសួរសំណួររបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំមានសំណួរបន្តិចខ្លះៗ មុននឹងខ្ញុំចាប់ផ្ដើមសួរអំពីពិធីរៀបការរបស់លោកស្រី។ ជាដំបូងខ្ញុំចង់សួរលោកស្រីអំពីការចូលនៅក្នុងឯកសារមួយ ភាពយន្តឯកសារមួយដែលគេហៅថា "អាពាហ៍ពិពាហ៍ក្រហម"។ កាលពីម្សិលមិញលោកស្រីបានឆ្លើយថា មុនពេលដែលលោកស្រីចូលទៅក្នុង -- មុនពេលលោកស្រីចូលរួមក្នុងការថតខ្សែវីដេអូហ្នឹង គឺមានមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់បានសម្ភាសជាមួយលោកស្រី។ ហើយលោកស្រីបានប្រាប់ថា មេធាវីនោះមិនបានណែនាំលោកស្រីឲ្យជួបជាមួយផលិតករភាពយន្តទេ។ គឺលោកស្រីគ្រាន់តែសរសេរទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហើយ<លោកស្រីនិយាយថា> "ប្រហែលជាដោយសារតែលោកស្រី<និយាយថា លោកស្រី>មានអាយុក្មេងពេក<> ទើបគេ<មកទាក់ទង>លោកស្រី។" តើលោកស្រីពិតជាបានឆ្លើយអ៊ីចឹងមែនទេ កាលពីម្សិលមិញ?

[០៩:១៧:០៨]

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស ខ្ញុំបានឆ្លើយអ៊ីចឹងមែន ចាស។

**ស៖** នៅក្នុងខ្សែវីដេអូនោះ គឺថានៅពេលដែលគេចាប់ផ្ដើមថតវីដេអូនោះ លោកស្រីកំពុងតែចាប់ផ្ដើមដំណើរការសរសេរពាក្យសុំតាំងខ្លួនរបស់លោកស្រី ហើយលោកស្រីបានពិភាក្សាជាមួយមិត្ត

ភក្តិ<ឈ្មោះ ឈាន> ថាតើត្រូវឆ្លើយសំណួរយ៉ាងម៉េចខ្លះ អីយ៉ាងម៉េចខ្លះ? ហើយលោកស្រីក៏បានឆ្លើយផងដែរថា កូនប្រុសពៅរបស់លោកស្រីនោះ គឺកូនប្រុសដែលបានរៀនបានខ្ពង់ខ្ពស់នោះ បានជួយលោកស្រី នៅក្នុងការបំពេញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ តើអ៊ីចឹងមែនទេ? តើ<គេថតភាពយន្តនោះ>នៅពេលដែលលោកស្រី<សរសេរពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងឬ>?

**ចៅក្រម កូឌា ហ្វេនស៍៖**

សូមឲ្យលោកមេធាវីផ្តល់នូវលេខឯកសារយោងនៃខ្សែភាពយន្តនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកស្រីចៅក្រមចង់បានអានាទី ប៉ុន្មាននាទី ប៉ុន្មាននាទីហ្នឹងមែនទេ? បើសិនបើអ៊ីចឹង ខ្ញុំនឹងប្រាប់នៅពេលបន្តិចទៀតនេះ។

[០៩:១៨:៣៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នៅក្នុងខ្សែវីដេអូ គឺយើងមើលទៅឃើញថា លោកស្រីកំពុងតែបំពេញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យើងឃើញជាច្រើនប្លង់ដែលនិយាយអំពីចំណុចនេះ។ តើអ៊ីចឹងមែនទេ?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស លោកប្រធាន អ៊ីចឹងមែន។

**ស៖** តើលោកស្រីអាចប្រាប់បានទេថា តើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងសម្ភាសលោកស្រីបានដោយរបៀបណាមុនពេលដែលលោកស្រីចាប់ផ្តើមថតខ្សែវីដេអូនោះ?

**ឆ៖** កាលនោះ គាត់បានទៅរកអ្នករៀបការសម័យខ្មែរក្រហម ដែលគេធ្វើបាបកាលសម័យខ្មែរក្រហម។ ហើយរួចហើយ ក៏ខ្ញុំនឹកឃើញថា ខ្លួនឯងរៀបការអង្គាល់សម័យខ្មែរក្រហម ខ្ញុំបានដាក់ពាក្យបណ្តឹងតាមរយៈមេធាវី ចាស។

**ស៖** តើលោកស្រីសម្ភាសមុនពេលថតភាពយន្តហ្នឹង ឬក៏ក្នុងពេលថតភាពយន្តហ្នឹង ឬក៏ក្រោយពេលថតភាពយន្តនោះ?

**ឆ៖** ចាស ដែលខ្ញុំសម្ភាស មុនថត លោកប្រធាន។

[០៩:២០:៣៨]

**ស៖** អ៊ីចឹងនៅពេលដែលយើងឃើញរូបភាពលោកស្រីរវល់បំពេញពាក្យសុំតាំងខ្លួនទុំង ការពិត

វាមិនមែនជាការបំពេញពិតប្រាកដនោះទេ វាគ្រាន់តែជាការសម្តែងឡើងវិញ ព្រោះថាលោកស្រីបានបំពេញពាក្យសុំតាំងខ្លួនរួចមកហើយ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំបានបំពេញហើយ បានខ្ញុំថតខ្សែវីដេអូតាមក្រោយ ចាស។

**ស៖** <ដើម្បីឲ្យច្បាស់> អ៊ីចឹងផលិតករ<បានស្នើសុំឲ្យលោកស្រី>--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

ដើម្បីបញ្ជាក់ឲ្យបានច្បាស់បន្តិច គឺថាដើមបណ្តឹងរដ្ឋប្បវេណី បានដាក់នូវពាក្យសុំតាំងខ្លួនជាច្រើនទម្រង់។ ប្រសិនបើខ្ញុំចាំមិនខុសទេ នៅពេលដែលលោកស្រីបានដាក់ហ្នឹង គឺលោកស្រីបានដាក់នៅច្រើនពេល គឺមានពាក្យសុំតាំងខ្លួនខ្លះ មុនពេល ខ្លះនៅក្នុងពេលថតភាពយន្តហ្នឹង ហើយពេលខ្លះអាចនៅក្រោយទៀតផង។ ដូច្នេះយើងចង់ឲ្យមានការបញ្ជាក់ឲ្យបានច្បាស់ ថាតើទម្រង់មួយណាដែលយើងកំពុងតែជជែកគ្នានៅពេលនេះ។

[០៩:២១:៥៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់អំពីចំណុចនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្តឹង តើលោកស្រីចាំទេ ថាតើទម្រង់មួយណាដែលផលិតករភាពយន្តហ្នឹង គេសុំឲ្យលោកស្រី – ខ្ញុំចង់សួរអ៊ីចេះវិញ ថាតើទម្រង់មួយណាដែលលោកស្រីបំពេញ នៅពេលដែលគេថតភាពយន្តនោះ? តើលោកស្រីចាំទេ?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ខ្ញុំចាំបាន។ ចាំបានត្រង់គេចូលទៅថតភាពយន្ត ខ្ញុំដាក់ពាក្យបណ្តឹងថា ខ្ញុំការពីអាយុ១៤ទៅ១៥ឆ្នាំនុ៎ង ពេលហើយ ក៏មិនដឹងជាថា គាត់ចង់ថតខ្ញុំនៅពេលណា ក៏ខ្ញុំអត់បានដឹងដែរ។ ទាល់តែខ្ញុំដាក់ពាក្យបណ្តឹងជាច្រើនសា ច្រើនវគ្គ ច្រើនជាន់ ឃើញខ្ញុំដាក់ទៅ ប្រហែលជាយ៉ាងណា ក៏ខ្ញុំមិននឹកស្មានថា ខ្សែភាពយន្តនោះចង់ថតនាងខ្ញុំ ក៏ខ្ញុំអត់បានគ្រោងទុកជាមុនដែរ ចាស ព្រោះខ្ញុំដាក់ពាក្យបណ្តឹង

ជារឿយៗតាមមេធាវី។ ដែលខ្ញុំឈឺចាប់ខ្លោចផ្សាកាលពីសម័យខ្មែរក្រហមធ្វើបាបនាងខ្ញុំ តាំងពីខ្ញុំនៅតូច ខ្ញុំក៏ដឹងថាមានតុលាការកាត់ទោសខ្មែរក្រហម គឺខ្ញុំសុំតាំងខ្លួនជាដើមបណ្តឹងគឺខ្ញុំដាក់មកជូនតុលាការ។

**សៈ** ត្រឹមត្រូវហើយ គឺមានទម្រង់ជាច្រើន ប៉ុន្តែលោកស្រីចាំទេ ថាតើទម្រង់មួយណា ឬក៏ពាក្យសុំមួយណាដែលកូនប្រុសលោកស្រីជួយលោកស្រីក្នុងការសរសេរ? ហើយថាតើទម្រង់មួយណាដែលលោកស្រីពិភាក្សាជាមួយមិត្តភក្តិរបស់លោកស្រី?

**ឆៈ** កាលនោះ ខ្ញុំអត់បានចាំទេ លោកប្រធាន ព្រោះខ្ញុំបានដាក់ ខ្ញុំបានប្រើឲ្យកូនសរសេរមែន។ ហើយដល់ពេលថត ក៏ខ្ញុំមិនបានដឹងថា គេទៅថតពេលណាដែរ ដែលខ្ញុំដាក់ហើយ គឺខ្ញុំបញ្ជូនមកបាត់ហើយ។ ហើយដែលពិគ្រោះជាមួយមិត្តភក្តិនេះ ខ្ញុំបានពិគ្រោះមែន តែខ្ញុំអត់ចាំពេល អត់ចាំថ្ងៃទេ។

[០៩:២៤:១៣]

**សៈ** ឥឡូវនេះ ខ្ញុំសូមបន្តទៅមុខទៀត។ ខ្ញុំចង់សួរលោកស្រី ថាតើផលិតករភាពយន្ត ឬក៏អ្នកចូលរួមក្នុងការថតភាពយន្តនោះ តើគេមានផ្តល់លុយកាក់ ឬក៏ផ្តល់កម្រៃអ្វីសម្រាប់ការដែលលោកស្រីចូលរួមក្នុងការថតខ្សែភាពយន្តនោះដែរឬទេ?

**ឆៈ** ខ្សែភាពយន្តនោះ គឺមិនបានប្រគល់លុយ ប្រគល់ប្រាក់អីមកដល់នាងខ្ញុំទេចាស។ គ្រាន់តែថា ខ្ញុំតាំងខ្លួនជាដើមបណ្តឹង ខ្ញុំតាំងនាមជាដើមបណ្តឹង ជាការងាររបស់ខ្ញុំ នៅក្នុងខ្លួនរបស់ខ្ញុំដែលខ្ញុំលំបាកណាស់។ អ៊ីចឹងខ្ញុំត្រូវតែដាក់ឲ្យថតយ៉ាងម៉េចក៏ថតចុះ ឲ្យតែត្រូវតាមតម្រូវការដែលចិត្តរបស់ខ្ញុំ។

**សៈ** មានសំណួរមួយទៀតទាក់ទងទៅនឹងការចូលរួមថតខ្សែភាពយន្តនោះ។ ម្សិលមិញលោកស្រីបានបញ្ជាក់ថា លោកស្រីបានជួបផលិតករភាពយន្តហ្នឹង ប្រហែលជាដោយសារតែលោកស្រីនិយាយថា លោកស្រីនៅក្មេង អ៊ីចឹងមែនទេ?

**ឆៈ** ខ្ញុំបាននិយាយអ៊ីចឹងមែន ចាស។

**សៈ** ខ្ញុំយល់ ប៉ុន្តែខ្ញុំគ្រាន់តែចង់ដឹងថា ហេតុអ្វីបានជា<លោកស្រីគិតថា> ដោយសារតែលោកស្រី<និយាយថា លោកស្រី>នៅក្មេងទើបអ្នកថតខ្សែភាពយន្តហ្នឹង គេទាក់ទងជាលោកស្រី?

**ឆៈ** ចាស គេទាក់ទងទៅនាងខ្ញុំមែន តើអ្នកមីងព្រមថតដែរឬអត់? តែរឿងរបស់អ្នកមីងទេ តែការអ្នកមីងបានថតកាល និយាយរឿងការពិត កាលអ្នកមីងរងគ្រោះកាលសម័យខ្មែរក្រហម។ ហើយខ្ញុំក៏បានយល់ព្រមថតជាមួយប្រធាន លីដា ហ្នឹងដែរចាស។

[០៩:២៦:៣៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ក្នុងការជជែកពិភាក្សាគ្នានោះ <ឬក៏ការពិភាក្សានាពេលក្រោយៗមកទៀត> គេក៏និយាយថា គេចាប់អារម្មណ៍ជាមួយនឹងខ្សែរឿង ជាមួយនឹងរឿងរបស់លោកស្រី ដោយសារលោកស្រីនៅក្មេង អ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងមែនលោកប្រធាន។

**ស៖** តើគេមានប្រាប់ទេ ហេតុអ្វីបានជាអាយុក្មេងរបស់លោកស្រីហ្នឹង គឺជាចំណុចសំខាន់សម្រាប់ការថតភាពយន្តនោះទេ?

**ឆ៖** ចាស សំខាន់ណាស់ ព្រោះយើងនៅក្មេង មិនទាន់ពេញវ័យ គេថា បានកើតសាលាក្ដីខ្មែរក្រហម យើងត្រូវតែដាក់ពាក្យបណ្ដឹង ត្រូវតែថត និយាយឱ្យបងប្អូន និងក្មេងសាក្រោយបានដឹងកាលពីជំនាន់ផ្ដាច់ការនោះ ចាស។ ខ្ញុំចង់និយាយដោយខ្លួនឯង ចាស។

**ស៖** មិនអីទេ ខ្ញុំសូមបន្តទៅមុខទៀត។ ខ្ញុំនឹងពិភាក្សាអំពីការថតភាពយន្ត និងវីដេអូ នៅពេលបន្តិចទៀត បន្តទៀត ប៉ុន្តែឥឡូវនេះខ្ញុំចង់សួរលោកស្រីអំពីការរៀបការលើកទី២ របស់លោកស្រី។ ម្សិលមិញលោកស្រីនិយាយអំពីកូនប្រាំមួយនាក់ ហើយនៅពេលថតវីដេអូហ្នឹង គឺឃើញកូនស្រីពីរកូនប្រុសមួយ គឺកូននៅក្នុងការរៀបការទី២។ តើលោកស្រីអាចរៀបរាប់អំពីប្ដីទី២ របស់លោកស្រីបានទេ?

**ឆ៖** ខ្ញុំអត់យល់ ចង់ឱ្យខ្ញុំឆ្លើយកន្លែងណា សូមបញ្ជាក់ម្ដងទៀត ចាស។

**ស៖** តើប្ដីទី២ របស់លោកស្រីហ្នឹង ជួបលោកស្រីរៀបការដោយរបៀបណា? តើប្ដីទី២ ហ្នឹងមានលក្ខណៈបែបណាដែរ? គឺថាលោកស្រីអាចនិយាយអ្វីក៏បានដែរ អំពីការរៀបការលើកទី២ របស់លោកស្រីនោះ។

[០៩:២៨:៥៨]

**ឆ៖** ចាស អង្កាល់នុំង ខ្ញុំបានរៀបការមែន គេចូលស្នើខ្ញុំដល់ម៉ែ ដល់ឪ។ អ៊ីចឹងក៏ខ្ញុំមិនចាំឆ្នាំខែនឹងការ មិនចាំឆ្នាំណាដែលខ្ញុំស្រលាញ់គ្នាទេ ព្រោះអង្កាល់ហ្នឹងខ្ញុំរៀបការជាមួយគាត់បានកូនប្រាំមួយនាក់។ ស្រីប្រាំ ប្រុសមួយ ពៅ អាយុ១៥ឆ្នាំហើយ តែគាត់បានចែកឋានចោលខ្ញុំតាំងពីកូនពៅហ្នឹងអាយុ៣ខែ ឥឡូវកូនខ្ញុំអាយុ២៥ឆ្នាំហើយ។

**ស៖** នៅក្នុងខ្សែវីដេអូ គឺនៅនាទី<១៩:២៨>វិនាទី និង១៩:៣៥វិនាទី លោកស្រីបាននិយាយថាលោកស្រីរីករាយ គឺថាលោកស្រីសប្បាយចិត្តជាមួយនឹងការរៀបការនឹងប្ដីរបស់លោកស្រី ប៉ុន្តែប្ដីលោកស្រីស្លាប់បាត់ទៅហើយ។ តើលោកស្រីពិតជាបាននិយាយអ៊ីចឹង នៅក្នុងខ្សែវីដេអូនោះមែនទេ?

**ផ៖** ចាស ខ្ញុំបាននិយាយមែនលោកប្រធាន។

**ស៖** លោកស្រីពេញចិត្តនឹងការរៀបការលើកទី២របស់លោកស្រី ហើយលោកស្រីបាននិយាយប្រាប់កូននៅក្នុងខ្សែភាពយន្តហ្នឹង។ ប៉ុន្តែខ្ញុំចង់សួរថា តើប្ដីលោកស្រី ប្ដីទី២ហ្នឹងធ្លាប់ដែលធ្វើបាប ឬក៏ប្រើអំពើហិង្សា ដូចជាវាយដំលោកស្រីអីដែរឬទេ?

**ផ៖** ចាស នៅជំនាន់ហ្នឹងគាត់ធ្វើបាបខ្ញុំមែន ដែលខ្ញុំដាក់ក្នុងខ្សែវីដេអូ។ បានខ្ញុំថា គាត់បានគាត់ធ្វើជាទាហាន គាត់ក៏មានស្រីច្រើន អ៊ីចឹងគាត់បានធ្វើបាបផ្លូវចិត្តខ្ញុំជាច្រើន។ អ៊ីចឹងបានថាខ្ញុំមេម៉ាយតាំងអាយុកូន៣ខែរហូតដល់កូន២៥ឆ្នាំ ខ្ញុំបានរងកម្មពីសម័យខ្មែរក្រហមផង ខ្ញុំបានរងគ្រោះមកសម័យនេះទៀត។ ខ្ញុំប្ដេជ្ញាថាមិនយកប្ដី ខ្ញុំចិញ្ចឹមកូនប្រាំមួយនាក់ ក្មួយមួយ ប្រាំពីរនាក់ ម្ដាយមួយ ប្រាំបីនាក់ប្រាំបួននាក់ទាំងខ្ញុំ គឺខ្ញុំចិញ្ចឹមតែម្នាក់ឯង។ ខែធ្វើស្រែគឺខ្ញុំធ្វើស្រែ រួចពីធ្វើស្រែខ្ញុំដឹកក្រូច ដឹកស្វាយរកលុយឲ្យកូនរៀន ខ្ញុំបានវេទនាគ្រប់ផ្លូវចាស។

[០៩:៣១:៥៧]

**ស៖** លោកស្រីដើមបណ្ដឹង ខ្ញុំសូមអាននូវសម្រង់មួយទាក់ទងទៅនឹងអ្វីដែលលោក -- គឺនឹងចេញពីរឿងរ៉ាវរបស់លោកស្រី គឺ E3/9197។ ខ្ញុំមិនមានលេខ ERN នៅត្រង់ទំព័រមួយនេះទេ ខ្ញុំនឹងផ្ដល់លេខ ERN នៅពេលបន្តិចទៀតនេះ។ គឺនៅទំព័រ១៥ នៅក្នុងសៀវភៅ ដូច្នេះយើងអាចពិនិត្យមើលទាំងអស់គ្នា។ ខ្ញុំសូមដកស្រង់នូវសម្ដី៖ "ប្ដីទី២ គឺជាទាហានដែលបានលែងលះជាមួយស្ត្រីម្នាក់ដែលគាត់បានរៀបការនៅក្នុងសម័យ<ខ្មែរក្រហម ហើយ>ភាពផ្អែមល្ហែមមិនមានបន្តរយៈពេលយូរនោះទេ។ គឺថាចំណងស្នេហាក្លាយទៅជាជូរចត់នៅពេលដែលមានកូនទី៣។ គាត់ត្រូវបានគេវាយធ្វើបាប បង្កហិង្សាទាំងផ្លូវកាយ និងផ្លូវចិត្ត ក៏ដូចជាផ្លូវភេទ ដោយសារតែប្ដីរបស់គាត់មានក្បត់ មានសហាយ។ ដោយរស់នៅក្នុងអាពាហ៍ពិពាហ៍ដែលប្រកបដោយអំពើហិង្សា។ លោកស្រី សុចាន់ <និងកូនៗរបស់គាត់ទាំងអស់ត្រូវរស់នៅជាមួយម្ដាយរបស់គាត់។ ការរស់នៅក្នុងអាពាហ៍ពិពាហ៍ដែលមានអំពើហិង្សា លោកស្រីសុចាន់ បានរៀបរាប់អំពើហិង្សាលើរូបគាត់ ដូចជា>ការគំរាមកំហែង<ដោយ>បាញ់កាំភ្លើងឡើងលើឬមួយក៏<បាញ់ផ្ទប់ដី ឬក៏>ភ្ជង់កាំភ្លើងទៅនឹងក្បាលរបស់គាត់ជាដើមនោះ។ <ប្ដីគាត់បានស្លាប់នៅឆ្នាំ១៩៩៣។>" អ្វីដែលខ្ញុំអានឲ្យលោកស្រីស្ដាប់ហ្នឹង តើវាជាការឆ្លុះបញ្ចាំងត្រឹមត្រូវអំពីពិធីរៀបការ<លើកទី២>របស់លោកស្រីដែរឬទេ?

**ចៅក្រម ក្លូឌា ហ្វេនស៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មុនពេល<គាត់ឆ្លើយ ខ្ញុំគិតថា វាអាចជួយគាត់ បើសិនជាលោកប្រាប់គាត់ថា នរណាជាអ្នកនិយាយអំពីគាត់។ គាត់មិនដឹង>លេខ ERN <នោះទេ>។

[០៩:៣៤:០៨]

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំយល់។ គាត់បាននិយាយបែបនេះដោយខ្លួនគាត់ ប្រាប់ទៅអ្នកដែលសរសេរសៀវភៅនេះ។ នេះគឺជារឿងរ៉ាវរបស់គាត់។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ប៉ុន្តែម៉េចបានជាលោកមិនប្រាប់គាត់ថា នេះជាសៀវភៅអ្វី ហើយនរណាជាអ្នកសរសេរសៀវភៅនេះ? ក៏ដូចជាប្រាប់ដល់សាធារណជនដែរ។>

**អ្នកបកប្រែ៖**

លោកប្រធានស្នើសុំឱ្យលោកស្រីចៅក្រមនិងលោកមេធាវី ទុកគម្លាតបន្តិចនៅក្នុងការជជែកគ្នា។

**លោក វ៉ិចទ័រ កូប៉េ៖**

<នេះគឺជាសៀវភៅដែល>និយាយអំពី<រឿងរ៉ាវខុសៗគ្នារបស់ស្ត្រីដែលបាន>រៀបការ។ <សៀវភៅនេះមានឈ្មោះថា "អតីត និងបច្ចុប្បន្នភាពរបស់ជនរងគ្រោះពីការ>បង្ខំ<ឱ្យរៀបការ"។> ERN <ជាភាសាអង់គ្លេស>មានលេខ <00992331> គឺមានរឿងរ៉ាវផ្សេងៗទៀតក្រៅពីរឿងរ៉ាវរបស់លោកស្រីនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី អ្វីដែលខ្ញុំបានអានឱ្យលោកស្រីស្តាប់អំពីអាពាហ៍ពិពាហ៍លើកទី២របស់លោកស្រី គឺជាការឆ្លុះបញ្ចាំងត្រឹមត្រូវអំពីអ្វីដែលកើតឡើងចំពោះលោកស្រីមែនទេ?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស ត្រឹមត្រូវ លោកប្រធាន។

**ស៖** តើលោកស្រីមានបាននិយាយដូចគ្នាប្រាប់ផលិតករភាពយន្តអំពីពិធី អំពីការរៀបការលើកទី២របស់លោកស្រីដែរឬទេ?

**ឆ៖** ចាស ខ្ញុំបាននិយាយ។

[០៩:៣៥:៤១]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកស្រីមានបានមើលខ្សែភាពយន្តហ្នឹងចប់សព្វគ្រប់ទេ នៅពេលដែលថតហើយ?

**ឆ៖** ថតហើយ នាងខ្ញុំអត់បានមើលសព្វគ្រប់ទេ ទើបតែបានចប់ប្រហែលជាមួយឆ្នាំជាងបានខ្ញុំសុំឌីសតាមរយៈមេធាវី ចាស។

**ស៖** តើផលិតករភាពយន្តហ្នឹង គាត់មានកាត់ចេញនូវបណ្តុំដែលនិយាយអំពីការរៀបការលើកទី២របស់លោកស្រីដែរឬទេ ព្រោះនៅពេលដែលយើងមើលភាពយន្តហ្នឹងទៅ ហាក់ដូចជាលោកស្រីសប្បាយចិត្ត ឬក៏ពេញចិត្តនឹងជីវិតអាពាហ៍ពិពាហ៍លើកទី២របស់លោកស្រីនោះ?

**ឆ៖** គ្មានៗកាលដែលខ្ញុំថតនោះ គ្មានគេកាត់ចេញពីរឿងពាក្យសម្តីរបស់ខ្ញុំទេ ចាស ខ្ញុំពេញចិត្តនិងរីករាយនិយាយឲ្យបានកូនដឹង ថាម្តាយពិបាកបែបណា ខ្ញុំបាននិយាយទៅកាន់ លីដា អ៊ីចឹងមែន។

**ស៖** ប្រហែលជាមានការកាត់ចេញខ្លះហើយនូវនេះ ប៉ុន្តែឥឡូវខ្ញុំសូមបន្តទៅមុខទៀត។ ទៅនិយាយអំពីខ្សែភាពយន្ត គឺការដកស្រង់មួយទៀតគឺនៅនាទី៣២:១២វិនាទី។ នៅត្រង់នាទីនេះគឺលោកស្រីបានជជែកគ្នាជាមួយនឹងប្អូនថ្លៃរបស់លោកស្រី គឺប្អូនស្រីប្តីទី១របស់លោកស្រី តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ដែលដាក់គាត់ប្អូនថ្លៃខ្ញុំគឺខុស គាត់បងថ្លៃខ្ញុំលោកប្រធាន។ គឺត្រឹមត្រូវ ប៉ុន្តែប្អូន -- បង មិនមែនប្អូនទេ។

**ស៖** អ៊ីចឹងហើយបាទ គឺបងថ្លៃ បានន័យថាបានត្រូវជាបងស្រីប្តីទី១របស់លោកស្រី អ៊ីចឹងមែនទេ?

[០៩:៣៨:២១]

**ឆ៖** ចាស អ៊ីចឹងមែនលោកប្រធាន។

**ស៖** តើលោកស្រីអាចជម្រាបបន្តិចបានទេ ថាតើបងថ្លៃរបស់លោកស្រីហ្នឹងជាមនុស្សបែបណា? គាត់<ជាអ្នក>ណា <ហើយ>គាត់<ធ្វើអ្វី>ចន្លោះពីឆ្នាំ៧៥ ដល់៧៩?

**ឆ៖** នោះ ខ្ញុំអត់ដឹងថាគាត់នៅកន្លែងណា ប៉ុន្តែខ្ញុំដឹងថាគាត់ធ្វើមេកង ហើយដល់ពេលខ្ញុំជួបគាត់ហ្នឹង ជួបនៅលើខែបុណ្យភ្ជុំ ថ្ងៃឆ្លង ខ្ញុំបានជួបគាត់ ឃើញនៅលើវត្ត ខ្ញុំស្មានតែគាត់ស្លាប់ ឬរស់ ខ្ញុំអត់ដឹងដែរ។ ដល់ពេលខ្ញុំឃើញគាត់នៅលើវត្តហ្នឹង ខ្ញុំក៏បានសួររៀបរាប់គាត់ថានៅទីណា សព្វថ្ងៃបងនៅឯណា? ហើយក៏គាត់ឆ្លើយថា បងនៅបាក់មែក។ អ៊ីចឹងក៏ខ្ញុំថា អ៊ីចឹងចាំថ្ងៃណាមួយ ខ្ញុំនឹងទៅលេងផ្ទះបង សួររឿងពិតពីកាលខ្ញុំការកាលសម័យខ្មែរក្រហម តើបងបានដឹងដែរអត់។ តែពេលនាងខ្ញុំទៅដល់គាត់ ៗមានប្រសាសន៍ថាគាត់អត់បានដឹង គាត់អត់បានឃើញ ហើយគាត់ក៏មិនបានស្រឡាញ់ខ្ញុំ សួរឲ្យ

ប្អូនគាត់ដែរ គឺអង្គការគេចាត់តាំងមក គាត់អត់ដឹង គាត់អត់ឮ គាត់អត់ដឹងថាប្អូនហ្នឹងរៀបការជាមួយខ្ញុំទេ។ ដល់ពេលនាងខ្ញុំសួរអ៊ីចឹងបានគាត់ភ្ញាក់ខ្លួន គាត់ក៏បែកប្អូនគាត់ ៗថាកូនគាត់ហ្នឹង មិនដឹងស្លាប់ទីណាអីទីណា ក៏គាត់អត់បានដឹងដែរ។

**ស៖** នៅក្នុងខ្សែភាពយន្ត គឺឃើញលោកស្រី<ជិះកង់ទៅរកគាត់> ហើយទៅជួបគាត់នៅបាក់មែក អ៊ីចឹងមែនទេ?

[០៩:៤០:១៥]

**ឆ៖** ចាស ខ្ញុំកាលជួបគាត់ ខ្ញុំស្លៀកពាក់ពណ៌ស នៅលើវត្ត ប៉ុន្តែដែលខ្ញុំទៅជួបគាត់នោះ គឺខ្ញុំអត់បានស្លៀកពាក់សទេ ខ្ញុំស្លៀកខោរាងពណ៌ឈាមជ្រូក អាវរាងពណ៌ឈាមជ្រូក។

**ស៖** ខ្ញុំយល់ ប៉ុន្តែតើអ្នកថតភាពយន្តហ្នឹង គឺគេឱ្យលោកស្រីឡើងជិះកង់ទៅជួបបងថ្លៃលោកស្រី នៅបាក់មែកដើម្បីជជែកគ្នា<ជាមួយបងស្រីប្តីទី១របស់លោកស្រី> អ៊ីចឹងមែនទេ?

**ឆ៖** គឺចិត្តរបស់ខ្ញុំចេញទៅ គឺខ្ញុំមិនអស់ចិត្ត នឹងអាងមកដាក់ពាក្យបណ្តឹងបន្ថែម ព្រោះខ្ញុំបានជិះកង់ជួបគាត់ ក៏ខ្ញុំទៅលេងគាត់។ ហើយដល់ពេលហើយ ក៏គេអ្នកចង់ថត ខ្ញុំប្រាប់ទៅ គាត់បានទៅថតខ្ញុំនៅកន្លែងដើមអំពិល។ ប៉ុន្តែអាជិះកង់នោះ គឺខ្ញុំជិះទៅចិត្តឯង ខ្ញុំទៅសួរគាត់ដោយចិត្តឯង។

**ស៖** នៅពេលដែលលោកស្រីនិយាយជាមួយបងថ្លៃលោកស្រីនោះ គឺឈុតដែលលោកស្រីនិយាយគ្នាជាមួយបងថ្លៃហ្នឹង គឺគេបកប្រែជាភាសាអង់គ្លេសផងដែរ។ <>លោកស្រីហៅគាត់ថា "មេកង" <ហើយគាត់និយាយថា> "<ប្អូនប្រុសខ្ញុំគឺជាសមាជិកកូនកង> នៅក្នុងកងចល័ត ហើយត្រូវបានគេបញ្ជូនទៅសហករណ៍។ នៅពេលនោះ គឺគាត់ចូលទៅក្នុងកងភ្ជួរ។ នៅក្នុងពេលរៀបការ គឺមានគូជាច្រើនគូ។ ហើយខ្ញុំមិនមែនជាអ្នកដែលជ្រើសរើសលោកស្រី ឬក៏ស្នើសុំលោកស្រីនោះទេ។ ខ្ញុំដឹងភ្លាមៗនៅថ្ងៃដែលគេរៀបការ ដែលគាត់រៀបការប៉ុណ្ណោះ។ សមមិត្ត <អ៊ុំ> បានប្រាប់ខ្ញុំ គឺអ្នកដែលខ្ញុំធ្វើការជាមួយនោះ។" គឺគាត់និយាយបែបនេះនៅក្នុងខ្សែភាពយន្តនោះ ប៉ុន្តែលោកស្រីអត់ជឿអ្វីដែលគាត់និយាយទេ។ តើលោកស្រីអាចពន្យល់បានទេ ថាហេតុអ្វីបានជាលោកស្រីមិនជឿជាក់សម្តីបងថ្លៃរបស់លោកស្រី?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមឱ្យលោកផ្តល់លេខឯកសារយោងផង។

[០៩:៤២:៥០]

**លោក វ៉ិចទ័រ កូប៉េ៖**

គឺនៅនាទី៣២:១២វិនាទី នៅក្នុងខ្សែវីដេអូហ្នឹង ហើយនិងបន្តបន្ទាប់មកទៀត។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមធ្វើកត់សម្គាល់ ហើយអង្គជំនុំជម្រះនឹងសម្រេចថាតើត្រូវធ្វើយ៉ាងម៉េច។ <តើ>វាមិនមានជាការងាយស្រួលទេ<ឬ> នៅក្នុងការបង្ហាញ<សម្រង់ពី>វីដេអូ<ជាភាសាខ្មែរ>ជារៀងរាល់ដងនោះ <>ដើម្បីឲ្យគាត់ងាយស្រួលយល់នោះ <នូវអ្វីដែលបាននិយាយជាភាសាកំណើតរបស់គាត់? បើធ្វើដូច្នេះ គឺអាចជៀសវាងនូវ>ការបកប្រែ<ចោះៗ> ព្រោះថាលោក ៗអាន<អក្សររត់នៅក្នុងភាពយន្តនោះ>ជាភាសាអង់គ្លេស <នេះបើតាមខ្ញុំយល់>។ អ៊ីចឹង<តើវាមិនប្រសើរទេឬ ក្នុងការបង្ហាញសម្រង់តាមរបៀបដែលយើងធ្វើកាលពីម្សិលមិញ ដើម្បីឲ្យគាត់អាចដាក់ខ្លួនគាត់នៅក្នុងភាពយន្តឯកសារនោះ ហើយស្តាប់ដោយខ្លួនគាត់នូវភាសាកំណើតរបស់គាត់? ខ្ញុំគិតថា បើធ្វើដូច្នេះវាសមហេតុផលជាង>។ ប៉ុន្តែខ្ញុំគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមែនមិនយល់ស្របជាមួយនឹងការលើកឡើងនេះ ក៏ប៉ុន្តែខ្ញុំមិនបានរៀបចំបង្ហាញ*ហ្វ៊ីហ*ពិសេសមួយនេះទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងខ្ញុំសូមផ្អាកការសួរសំណួរនេះសិនទៅ <ហើយត្រឡប់មកសួរម្តងទៀត នៅពេលលោកបានរៀបចំត្រៀមរួចរាល់ហើយ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់អំពីការលើកឡើងរបស់លោកស្រីហើយ <ប៉ុន្តែនេះគឺជា>--

[០៩:៤៩:២២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នេះគឺដោយសារតែភាសា ខ្ញុំមិនដឹងថា ខ្ញុំស្តាប់បានច្បាស់ មិនច្បាស់ទេ ក៏ប៉ុន្តែអត្ថបទជាភាសាអង់គ្លេសនៅក្នុងខ្សែភាពយន្តហ្នឹងគឺសង្ខេបទេ គេសរសេរជាសង្ខេបទេនៅក្នុងខ្សែភាពយន្តនោះ។ អ៊ីចឹងមានការព្រួយបារម្ភអំពីការបកប្រែពីរដង។ ទី១ គឺដើមបណ្តឹងរដ្ឋប្បវេណីនិយាយជាភាសាខ្មែរ ហើយក្រោយមកគេដាក់ចំណងនៅក្នុងខ្សែភាពយន្តហ្នឹងជាភាសាអង់គ្លេស ហើយបានបកប្រែចេញពីភាសា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អង់គ្លេស ចំណងជើងខ្សែភាពយន្តជាសង្ខេបនោះ ទៅជាភាសាខ្មែរឡើងវិញម្តងទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំយល់ ប៉ុន្តែវាជាការចាប់ផ្តើមនៃកម្រងសំណួរវែងជាងនោះ ព្រោះវាក៏ចូលទៅសំណួររបស់> លោកស្រី<>ដែរ ដែលសួរថាតើអ្នកណាជាអ្នកស្នើសុំ ឬក៏រៀបចំឱ្យដើមបណ្តឹងរដ្ឋប្បវេណីនេះរៀប-ការ? ឥឡូវខ្ញុំសូមដាកចេញពី*ហ្វីលហ៍*ដែរអូនេះចុះ សួរសំណួរ<ទូទៅវិញ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកស្រីមានគិតទេថា នៅពេលមួយនោះ បងស្រីរបស់ប្តីទី១ លោកស្រីហ្នឹងគឺជាអ្នកស្នើសុំឱ្យលោកស្រីហ្នឹងរៀបការជាមួយនឹងប្អូនប្រុសរបស់គាត់? លោកស្រីមានបានគិតថាអ៊ីចឹងដែរទេពេលណាមួយនោះ?

[០៩:៤៦:០៥]

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស អង្កាល់ពេលជួបគាត់នៅលើវត្ត ខ្ញុំបានគិតអ៊ីចឹងមែន ខ្ញុំគិតក្នុងចិត្តខ្ញុំ តើក៏គាត់ឃើញខ្ញុំទៅសួរ ក៏ឬមួយយ៉ាងម៉េច បានខ្ញុំជិះកង់ទៅដល់ស្រែគាត់ច្រូតហ្នឹងចាស។

**ស៖** ហេតុអ្វីបានជាលោកស្រីបានគិតថា បងស្រីរបស់ប្តីទី១របស់លោកស្រីហ្នឹង គឺជាអ្នកដែលចង់ឱ្យប្អូនប្រុសរបស់គាត់ហ្នឹង រៀបការជាមួយលោកស្រី?

**ឆ៖** ចាស អង្កាល់នោះរបបផ្តាច់ការ ខ្ញុំអត់បានសួរគាត់ទេ ដល់មកសង្គមនេះ ខ្ញុំបានទៅសួរគាត់ ចង់ដឹងរឿងពិត តើគេមកស្រឡាញ់យើង ក៏ឬបក្សគេកំណត់។ ដល់ពេលខ្ញុំទៅសួរគាត់ គាត់ថាគាត់មិនបានដឹង គាត់មិនបានស្រឡាញ់នាងខ្ញុំទេ ទើបបានខ្ញុំអស់ចិត្តចាស។

**ស៖** នេះជាចម្លើយមួយគួរឱ្យចាប់អារម្មណ៍ណាស់ ក៏ប៉ុន្តែមិនមែនជាចម្លើយឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ។ សំណួរខ្ញុំសួរថា ហេតុអ្វីបានជាលោកស្រីគិតថា បងស្រីរបស់ប្តីមុនលោកស្រីហ្នឹងគឺជាអ្នកដែលចង់ឱ្យលោកស្រីហ្នឹងរៀបការជាមួយប្អូនប្រុសរបស់គាត់?

**ឆ៖** អានោះជាចម្ងល់របស់នាង--

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន តាមខ្ញុំស្តាប់ លោកស្រីមិនបាននិយាយថា គាត់បានគិតថា បងថ្លៃស្រីរបស់គាត់ជាអ្នកស្នើទេ គាត់គ្រាន់តែឆ្ងល់ ហើយចង់ដឹងថាតើបងស្រីហ្នឹងជាអ្នកដឹង ឬក៏បានស្នើឱ្យ

គាត់រៀបការជាមួយប្អូនប្រុសនោះតែប៉ុណ្ណោះ។ ដូច្នេះ នេះវាមិនមែនដូចអ្វីដែលមេធាវីការពារក្ដីបានលើកទេ។ សូមអរគុណលោកប្រធាន។

[០៩:៤៨:៣៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីទទួលស្គាល់ហើយ នៅពេលដែល<ខ្ញុំប្រាប់គាត់ពីបញ្ហានេះ គាត់បានបង្ហាញថា គាត់មិនជឿលើបងប្ដីទី១របស់គាត់ទេ។> ប៉ុន្តែយ៉ាងណាក៏ដោយចុះ ខ្ញុំរៀបចំសំណួរឡើងវិញទៅចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើត្រឹមត្រូវដែរឬទេ លោកស្រីដែលថា នៅពេលមួយនោះ មានពេលណាមួយលោកស្រីបានគិតថា គឺបងស្រីរបស់ប្ដីទី១លោកស្រីនុ៎ងហើយ ដែលជាអ្នកចង់ឲ្យលោកស្រីហ្នឹងបានរៀបការជាមួយនឹងប្អូនប្រុសរបស់គាត់។ <បើពិតមែន តើត្រឹមត្រូវទេថា> នៅពេលដែលបងស្រីរបស់ប្ដីទី១លោកស្រីឆ្លើយថា ទេ គាត់មិនមែនជាអ្នកចង់ឲ្យលោកស្រីរៀបការជាមួយប្អូនប្រុសរបស់គាត់នោះ លោកស្រីមិនជឿទេ អ៊ីចឹងឬក៏យ៉ាងណា?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** តែដល់ពេលនាងខ្ញុំជួបគាត់ គាត់ឆ្លើយអ៊ីចឹងមក ទើបតែខ្ញុំអស់ចិត្ត។ នោះគឺខ្ញុំចាត់ទៅជារបបផ្ដាច់ការរបស់ខ្មែរក្រហមចាស។

**ស៖** លោកស្រីមិនទាន់ឆ្លើយទៅនឹងសំណួរខ្ញុំទេ ប៉ុន្តែខ្ញុំចូលទៅនិយាយអំពីស្ត្រីមួយផ្សេងទៀតគឺបងស្រីប្ដីទី១របស់លោកស្រីហ្នឹង <ហាក់ដូចជា>បាននិយាយថា មិនមែនគាត់ទេ ជាអ្នកដែលផ្គូផ្គង ឬក៏ស្នើសុំនោះ។ ប៉ុន្តែមានស្ត្រីម្នាក់ផ្សេងទៀតនោះទេ ឈ្មោះ អ៊ុំ គឺ មឿន ហៅអ៊ុំ ស្ត្រីម្នាក់ឈ្មោះ មឿន ហៅ អ៊ុំ។ តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះ ថាតើស្ត្រីឈ្មោះ អ៊ុំ នេះជាអ្នកណាដែរ?

[០៩:៥០:៤៨]

**ឆ៖** ដែលឈ្មោះ មឿន ខ្ញុំអត់បាន មានឈ្មោះ មឿន ទេតែ អ៊ុំ នេះ ខ្ញុំទទួលស្គាល់ថា តែខ្ញុំគាត់មេកងចាស។ គឺ មឿន នោះអត់ៗបានដាក់ទេ។ ខ្ញុំបាន--

**ស៖** មានភាពច្របូកច្របល់បន្តិច ប៉ុន្តែគាត់ថា គាត់ឈ្មោះ ភាស់ មឿន ហៅ អ៊ុំ។ ខ្ញុំសូមបន្តទៅមុខទៀត។ ម្សិលមិញនៅពេលមួយយើងឃើញវីដេអូឃ្លីបនោះ គឺឃើញលោកស្រីហ្នឹងនិយាយជា

មួយឈ្មោះ អ៊ុំ ត្រឹមត្រូវដែរឬទេ? ហើយបើនៅក្នុងខ្សែភាពយន្តនោះ លោកស្រីពិតជានិយាយជាមួយឈ្មោះ អ៊ុំ តើ អ៊ុំ នោះជាអ្នកណា?

**ឆ៖** ខ្ញុំបាននិយាយមែន ហ្នឹងហើយជាមេកងរបស់ខ្ញុំ ព្រោះអ្នកថតគេចង់ដឹងការពិត គេខ្លាចខ្ញុំនិយាយមិនពិត។ អ៊ីចឹងខ្ញុំសុំឲ្យគាត់ទៅជួបមេកងហ្នឹងទៅ។ គេសួរខ្ញុំថា គេនៅរស់ ឬអត់? ថា នៅរស់។ អ៊ីចឹងសុំជួបគេបានអត់? អាហ្នឹងជារឿងរបស់លោកគ្រូ អ្នកគ្រូដែលមកថតខ្ញុំទេ បើខ្ញុំអាចជូនទៅបាន ព្រោះខ្ញុំឃើញគាត់ ខ្ញុំសឹងតែសន្លប់ហើយ ព្រោះគេបានវ៉ៃក្បាលខ្ញុំនឹងត្បូងចប គេបានធ្វើបាបខ្ញុំ។ ខ្ញុំឃើញមុខ ខ្ញុំឆ្អែតណាស់ អ្នកគ្រូ។ គ្រាន់តែថ្ងៃដែលខ្ញុំទៅជួប គឺមកវិញ ខ្ញុំខ្យល់គ។ គឺពិតមែន។

**ស៖** តើ អ៊ុំ នេះជាប្រធានកងចល័ត<ដែលលោកស្រីធ្វើការជាមួយគ្នានឹង>បងស្រីរបស់ប្ដីទី១លោកស្រី<នោះឬ? តើពីរនាក់គាត់នោះ>គឺជាអ្នកគ្រប់គ្រងកងចល័តរបស់លោកស្រីមែនទេ?

**ឆ៖** ចាស បងអ៊ុំ ខ្ញុំដឹងថា ធ្វើប្រធានកងនៅកន្លែងខ្ញុំ។ គាត់ហ្នឹងជាអនុប្រធានធ្វើការនៅក្នុងហ្នឹង ធ្វើអីធំជាងគ្នា អ្នកណាធំជាងអ្នកណា គឺខ្ញុំអត់មានសិទ្ធិសួរគាត់ដេញដោលទេ។ តែខ្ញុំដឹងច្បាស់ តែបងអ៊ុំ ហ្នឹងមេកង ដែលធ្វើបាបខ្ញុំដោយផ្ទាល់ដៃ។

[០៩:៥៣:០៣]

**ស៖** តើត្រឹមត្រូវដែរឬទេថា អ៊ុំ ហ្នឹងធ្វើការជាមួយនឹងបងស្រីរបស់ប្ដីទី១ លោកស្រី? តើអ្នកទាំងពីរនេះជាអ្នកដឹកនាំ ជាអ្នកក្ដោបក្ដាប់កងចល័តរបស់លោកស្រី ឬក៏អត់ទេ?

**ឆ៖** ខ្ញុំបានឃើញតែ បងអ៊ុំ ទេដែលពេលខ្ញុំរៀបការ រឿងគាត់ គាត់នៅកងផ្សេងពីខ្ញុំ គាត់ធ្វើអីក៏ខ្ញុំមិនដឹងដែរ ប៉ុន្តែគេថាគាត់ហ្នឹងធ្វើការ មេកងដែរ។ អ៊ីចឹងបានខ្ញុំតាំងចិត្តថា ខ្ញុំទៅសួរគាត់ ការថតនូវឃ្លីបវីដេអូ។

**ស៖** ដោយសារខ្ញុំមិនមានពេលវេលាច្រើន លោកស្រី អ៊ីចឹងខ្ញុំសុំបន្តទៅមុខទៅទៀត ឲ្យបានលឿន។ នៅពេលដែលលោកស្រីមើលខ្សែភាពយន្ត នៅក្នុងខ្សែភាពយន្តនេះ លោកស្រីកំពុងតែនិយាយជាមួយ អ៊ុំ។ នៅក្នុងខ្សែភាពយន្តនេះ គឺមើលទៅឃើញថា លោកស្រីមិនមែនទៅរកឈ្មោះ អ៊ុំ ទេ <គឺទៅ>រកប្ដីរបស់ អ៊ុំ ទេ គឺ អឿន ដែលជាប្ដីរបស់ អ៊ុំ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** មិនត្រឹមត្រូវទេចាស។ បងអ៊ុំ ហ្នឹងគាត់មេម៉ាយ គាត់អត់មានប្ដីទេ។ អឿន ហ្នឹងគឺធំជាងបងអ៊ុំ ហ្នឹងចាស។ នៅក្នុងខ្សែភាពយន្ត ខ្ញុំបញ្ជាក់ គឺមាននៅក្នុងហ្នឹងចាស។ គឺ អឿន មកធ្វើប្ដី អ៊ុំ គឺគ្មានទេ ខុស ៗដែលពាក្យខ្ញុំដាក់។ ខ្ញុំសូមបដិសេធ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** អ៊ីចឹងខ្ញុំយល់ហើយ។ អ៊ីចឹងចុះមេភូមិ ដែលលោកស្រីចង់ទៅជួបនោះហើយអត់នៅផ្ទះ ហើយលេចចេញ អ៊ុំ មកជួបលោកស្រី។ អ៊ីចឹងតើ អ៊ុំ នេះរៀបការជាមួយមេភូមិដែលលោកស្រីទៅរក ឬក៏យ៉ាងណា?

[០៩:៥៥:០៩]

**ធ៖** ខ្ញុំអត់យល់នឹងសំណួរ ព្រោះសំណួរមេភូមិនេះ ខ្ញុំអត់មាន ក៏ខ្ញុំអត់បានដាក់។ ខ្ញុំអត់បានទៅរកឈ្មោះមេភូមិ។ អឿន នេះគឺគណៈកងផ្នែកដែលធ្វើបាបខ្ញុំ ជិះសេះរើខ្ញុំពីក្រោយ។ ហើយខ្ញុំដាក់ ក៏អត់មានច្រឡូកច្របល់អ៊ីចឹងដែរចាស។ ខ្ញុំសុំមិនឆ្លើយ។

**ស៖** បាទ មិនថ្វីទេ។ តើមានពេលមួយលោកស្រី<ចាំទេថា លោកស្រីបានពិភាក្សាពី>ការរៀបការរបស់លោកស្រី <តើមានអ្វីបានកើតឡើង>ក្រោយការរៀបការ<ក្នុងអំឡុងយប់មួយនោះ? លោកស្រីបានពិភាក្សាជាមួយគាត់។ តើ>លោកស្រី<ចាំថាបានពិភាក្សារឿងនេះនៅក្នុងភាពយន្តនោះ>ទេ?

**ធ៖** យប់ទី១ ខ្ញុំបាននិយាយឈ្មោះជាមួយឈ្មោះអ្នកណា? លោកប្រធាន សូមអានឈ្មោះ។

**ស៖** សំណួររបស់ខ្ញុំ <តើលោកស្រីចាំទេ> គឺអ្នកផលិតករភាពយន្តក៏នៅទីនោះ នៅពេលដែលលោកស្រីនិយាយជាមួយ អ៊ុំ នូវអ្វីដែលបានកើតឡើងនៅយប់ដែលលោកស្រីរៀបការនោះ។ អ៊ីចឹងមែនទេ?

**ធ៖** ខ្ញុំអត់មានពាក្យថា និយាយជាមួយ រៀបការជាមួយ បងអ៊ុំ ដែលថា យប់រៀបការនោះ គឺអត់បាននិយាយទេ បានដាក់ពាក្យថា និយាយជាមួយឈ្លប។ ប្ដីខ្ញុំបានការហើយ គាត់ជួបឈ្លប ឈ្លបបានពន្យល់គាត់យ៉ាងម៉េច តែគ្រាន់តែខ្ញុំស្ដាប់ឮថា រៀបចាប់ដៃហើយគឺប្ដីប្រពន្ធហើយ ធ្វើអ្វីក៏ធ្វើទៅយប់នេះ ប្រយ័ត្នអង្គការហៅទៅកសាងខ្លួន យ៉ាប់ហើយ។ អាហ្នឹងស្ដាប់ឮ។ តែឲ្យខ្ញុំបាននិយាយជជែកនៅយប់ការហើយជាមួយមេកង អ៊ុំ ខ្ញុំអត់បានដាក់ទេ។

**ស៖** តើលោកស្រីមានបានបង្ហាញរូបថត ឬក៏រូបណាមួយទៅឲ្យ អ៊ុំ មើលទេ នៅពេលដែលផលិតករនោះកំពុងតែថតលោកស្រីនោះ?

[០៩:៥៧:៥៤]

**ធ៖** ចាស ខ្ញុំបានបង្ហាញរូបដែលគេចាប់ដៃ ចាប់ជើងស្រាតសំពត់នោះ ហ្នឹងជារឿងដូចរបស់ខ្ញុំ។ អ៊ីចឹងខ្ញុំឆ្លើយនៅក្នុងនោះ ខ្ញុំថា នេះជារឿងរបស់ខ្ញុំ ខ្ញុំបាននិយាយអ៊ីចឹងមែន។ គេប្រឌិតនេះ គេមិនកុហកទេ តែខ្ញុំនិយាយទៅគាត់ថា តែប្រជាជនដែលរស់កាលសម័យរបបផ្ដាច់ការ គេលំបាកដូចខ្ញុំដែរឬ

អត់? កាលនោះខ្ញុំបាននិយាយអ៊ីចឹងមែន ចាស។ ខ្ញុំឃើញរូបហ្នឹង ដូចជាថ្មីៗពេក។

**ស៖** តើអ្នកណាដែលជាអ្នកផ្ដល់រូបថតនេះមកឲ្យលោកស្រី ដែលលោកស្រីបានយកទៅបង្ហាញឈ្មោះ អ៊ុំ នុំង?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

<នេះជាការសង្កេត១០នាទីមកហើយ។> ឥឡូវខ្ញុំជំទាស់ម្ដង។ <តើខ្ញុំអាចសូមឲ្យ>អង្គជំនុំជម្រះ <>សូមឲ្យមេធាវីហ្នឹងបង្ហាញសម្រង់<បានទេ ព្រោះថាយើងកំពុងតែជួបបញ្ហាដូចមុនម្ដងទៀតហើយ>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ខ្ញុំយល់ស្រប។ លោក>មេធាវី <លោកចេញមិនផុតពីភាពចាំបាច់នៃការបង្ហាញខ្សែភាពយន្តនោះទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

<អ៊ីចឹងខ្ញុំស្នើសុំឲ្យបញ្ចាំងខ្សែភាពយន្តនោះ ដើម្បីមើលទាំងអស់គ្នា ព្រោះថា -->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងម៉េចមិនផ្លាស់ៗប្ដូរ ដូរកៅអីកន្លែងអង្គុយទៅ <លោករៀបចំសម្រង់ ហើយគាត់ចូលទៅក្នុង ហើយ-->។

[០៩:៥៩:១១]

**លោក វ៉ិចទ័រ កូប៉េ៖**

<បញ្ហាគឺថា ខ្ញុំបានសួរគាត់ថា តើគាត់បានបង្ហាញរូបថតទេ ហើយគាត់ឆ្លើយថា ចាស។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ឥឡូវនេះលោកមេធាវីកំពុងនិយាយពីរូបថត <ហើយវាគួរឲ្យចាប់អារម្មណ៍ណាស់សម្រាប់យើងក្នុងការមើល -->

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំយល់ ប៉ុន្តែ -->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<-- បញ្ហាទាំងមូលតែម្ដង។>

**លោក វ៉ិចទ័រ កូប៉េ៖**

<-- ចំពោះខ្ញុំ វាមិនចាំបាច់នោះទេ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ហើយសម្រាប់គាត់ក៏មិនចាំបាច់ដូចគ្នាដែរ។ ដូច្នេះលោកថា វាមិនចាំបាច់ទេឥឡូវនេះ?>

**លោក វ៉ិចទ័រ កូប៉េ៖**

<សម្រាប់ខ្ញុំ វាមិនចាំបាច់ទេ ព្រោះគាត់ទើបតែទទួលស្គាល់ថា គាត់បានបង្ហាញរូបថត ឬក៏រូបភាព ដែលអាចសន្និដ្ឋានថា រូបគាត់ត្រូវបានគេធ្វើបាប -->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ប៉ុន្តែ -->

**លោក វ៉ិចទ័រ កូប៉េ៖**

<-- បង្ហាញឲ្យ អ៊ុំ មើល។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ពេលដែលយើងកំពុងតែចង់ដឹង តើរូបថតហ្នឹង តើរូបថតស្អី? កំពុងនិយាយអំពីរូបថតអ្វី?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនចង់ឲ្យបញ្ចាំងខ្សែភាពយន្តហ្នឹង ខ្ញុំសួរតែចំណុចតូចមួយតែប៉ុណ្ណោះ សួរថាតើហេតុអីបានជាគាត់យករូបថតហ្នឹង មកបង្ហាញឈ្មោះ អ៊ុំ នៅពេលដែលគេកំពុងថតភាពយន្តនុ៎ង?

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០១:២៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី វ៉ិចទ័រ កូប៉េ លោកអាចបង្ហាញនូវចំណុចនៃខ្សែវីដេអូឃ្លីបដែលពាក់ព័ន្ធនឹងចំណុចទាំងឡាយដែលលោកមានបំណងសួរទៅដើមបណ្តឹងរដ្ឋប្បវេណីនេះដែរឬទេ? ដើម្បីឲ្យទាំងដើមបណ្តឹងរដ្ឋប្បវេណី ទាំងភាគី ទាំងចៅក្រម ភាគីដទៃទៀត ទាំងចៅក្រម បានយល់ និងបានឃើញច្បាស់អំពីឯកសារនោះ ហើយមានប្រតិចារឹកច្បាស់លាស់ផង។ ចៀសវាងសួរទៅ ដូចជាស្មានៗដូច្នេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

រូបថតនេះ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**លោក វ៉ិចទ័រ កូប៉េ៖**

-- គឺអាចឃើញជាច្រើននៅនាទីទី៤១ និង១០វិនាទី។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ទី១ សូមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ គឺថាការជំទាស់នេះ គឺចាត់ទុកជាបានការ។ នៅពេលដែលលោកសួរសាក្សី យកអ្វីចេញពីខ្សែភាពយន្ត គឺត្រូវតែបង្ហាញនូវឯកសារយោងត្រង់ចំណុចពាក់ព័ន្ធពីក្នុងខ្សែភាពយន្តនេះ។

[១០:០២:២៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ដើម្បីប្រតិចារឹក <យើងរកឃើញភាពមិនគួរឲ្យជឿបានថា ទើប>តែនៅថ្ងៃអង្គារនោះទេ ដែលយើងបានទទួលដំណឹងថា ដើមបណ្តឹងរដ្ឋប្បវេណីនេះគឺជាតួឯកនៅក្នុងខ្សែភាពយន្តឯកសារ ហៅថា "អាពាហ៍ពិពាហ៍ក្រហម" នេះ។ <ខ្ញុំមិនយល់ថា តើ>ហេតុអ្វីបានជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ចូលខ្លួនមកផ្តល់សក្ខីកម្មយឺត<ម្ល៉េះ ជាមួយនឹងព័ត៌មានសំខាន់នោះ។ ប៉ុន្តែយើងបានប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បី>មើលវីដេអូឡើង<>ទាំងអស់<>។ បើសិនណាជាអង្គជំនុំជម្រះឲ្យខ្ញុំបង្ហាញរាល់ផ្នែកពាក់ព័ន្ធទាំងនាទី ទាំងអ្វីអ៊ីចឹង គឺខ្ញុំត្រូវការពេលវេលាបន្ថែមទៀត ដើម្បីឲ្យវាមានលក្ខណៈសមហេតុសមផល ទៅនឹងការលើកឡើងរបស់ខ្ញុំ ក្នុងពេលសួរសំណួរណាមួយ។ <ជាថ្មីម្តងទៀត ខ្ញុំមិនមានបញ្ហាអីទេក្នុងការបង្ហាញរូបថតនោះ។> នេះដោយសារថា ការជូនដំណឹងមកយើងខ្ញុំអំពីដើមបណ្តឹងរដ្ឋប្បវេណីនេះ វាយឺតពេលបន្តិចទៅហើយ អ៊ីចឹងឯងអ៊ីចឹង។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

<មាន>ការជំទាស់<មួយសម្រាប់ប្រតិចារឹក ខ្ញុំសូមឆ្លើយតប>ពាក់ព័ន្ធនឹង<>ប្រតិចារឹកសវនាការនេះ<>។ វីដេអូហ្នឹងមានតាំងពីឆ្នាំ២០១២មកម្ល៉េះ តាំងពីយូរណាស់មកហើយ អ៊ីចឹងវាមិនមែនជារឿងថ្មីអ្វីទៀតទេ គឺច្រើនឆ្នាំមកហើយបួនប្រាំឆ្នាំទៅហើយ។ ហើយអ្នកទាំងអស់គ្នា ប្រហែលជាលើកលែងតែលោក កូប៉េ ទេមើលទៅ បានដឹងថា លោកស្រី សុចាន់ ហ្នឹងគាត់ជាតួឯកនៅក្នុងរឿងហ្នឹងហើយ <គឺ "អាពាហ៍ពិពាហ៍ក្រហម">។ អ៊ីចឹងគេដឹងគ្រប់គ្នាហើយ ប្រហែលជាមានតែលោក កូប៉េ

ទេអត់ដឹង។ <យើងមិនបានលាក់អ្វីទាំងអស់។> ហើយយើងក៏បានប្រាប់ជូន<ដំណឹង>តាំងពីថ្ងៃ<ព្រឹកអង្គារ> ថាយើងចង់ប្រើប្រាស់វីដេអូហ្នឹង ដើម្បីមកសួរគាត់។ អ៊ីចឹងអ្នកណាក៏គេដឹងដែរថា លោកស្រីសុចាន់ នេះជាតួឯកនៅក្នុងរឿងហ្នឹង អ្នកមានវត្តមាននៅទីនេះ គេដឹងគ្រប់គ្នា អត់មានអីលាក់កំបាំងទេ។

[១០:០៤:៥៥]

**លោក វ៉ិចទ័រ កូប៉េះ**

*(គ្មានការបកប្រែ)*--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដើម្បីកុំឲ្យខាតអស់ពេលពេលាក្នុងការជំទាស់តវ៉ាគ្នា <-- ខ្ញុំគិតថា យើងដឹងវាហើយ។> មានសំណើសុំមួយដើម្បីឲ្យផ្តល់ពេលវេលាទៅលោកបន្ថែមទៀត។ លោកត្រូវការពេលវេលាប៉ុន្មាន?

**លោក វ៉ិចទ័រ កូប៉េះ**

គឺថាយ៉ាងហោចណាស់ ក៏ខ្ញុំត្រូវការពេលវេលានៅពេលឈប់សម្រាកនេះដើម្បីរកត្រង់ចំណុចរូបថតនេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ខ្ញុំមិនដឹងថាលោកទៅខាងណាទេ ប៉ុន្តែសេចក្តីសម្រេចគឺសម្រាប់>ពេលវេលា<បន្ថែមទៀតនៅពេលលោក>សួរតាំងជាមួយដើមបណ្តឹងរដ្ឋប្បវេណី<ដោយប្រើផ្នែកនៃវីដេអូ>នេះ?

**លោក វ៉ិចទ័រ កូប៉េះ**

ទោះជាយ៉ាងណាក៏ដោយ ក៏ពេលវេលានេះសមស្របល្មមនឹងឈប់សម្រាកសិនហើយលោកប្រធាន ដើម្បីឲ្យខ្ញុំរកមើលចំណុចពាក់ព័ន្ធ ហើយឲ្យខាង អេ.វី *យូទីត*នេះចាក់បញ្ចាំង។ ហើយជាពិសេសត្រង់ចំណែកការសន្ទានារវាងគាត់ និងបងថ្លៃស្រីរបស់ប្តីដំបូងរបស់គាត់ ប្តីទី១របស់គាត់នោះ។

[១០:០៥:៣២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<តើលោកត្រូវការពេលវេលាទាំងអស់ប៉ុន្មាន?>

**លោក វ៉ិចទ័រ កូប៉េះ**

<អត់ទេ យើងអាចធ្វើនៅក្រោយពេលឈប់សម្រាក ដូច្នេះ -->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ៊ីចឹងពេលវេលាបន្ថែមត្រូវការប៉ុន្មាន?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំត្រូវការពេលវេលាបន្ថែម៣០ ទៅ៣៥នាទីបន្ថែមទៀត<ដើម្បីសួរគាត់>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ចុះក្រុមមេធាវីការពារក្ដី ខៀវ សំផន ម៉េចដែរត្រូវការពេលវេលាបន្ថែម ឬក៏យ៉ាងណាដែរ?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនដឹងថា តើមេធាវីគាត់សួរសំណួរអីបន្ថែមទៀតទេ មិនដឹងថាប្រធានបទគាត់សួរយ៉ាងម៉េចទេ ហើយគាត់សុំថែម៣៥នាទី អ៊ីចឹង<តើ>ខ្ញុំ<អាចស្នើសុំ>ថា <>យើង<អាចសុំរយៈពេល> ៣៥នាទី<បន្ថែមទៀតសម្រាប់ក្រុមមេធាវីការពារក្ដីទាំងមូលបានទេ ហើយបើដូច្នោះវាអាចនឹងឆ្លងចូលទៅដល់ពេលល្ងាចទៀត។ តាមដែលខ្ញុំព្រួយបារម្ភនោះ បើសិនជាយើងអាចបញ្ចប់មុនពេលបន្តិច យើងអាចធ្វើដូច្នោះបាន ប៉ុន្តែបើសិនជាយើងសុំម៉ោងបន្ថែម>៣៥នាទី <នោះវានឹងធ្វើឲ្យយើងចាប់ផ្ដើមសួរនៅក្រោយពេលសម្រាក។ ដូច្នេះយើងស្នើសុំថាពេលវេលាបន្ថែមនោះ ត្រូវផ្ដល់ឲ្យនៅដើមដំបូងនៃ>ពេលរសៀល។ <>ហើយបើសិនជាអាចចប់មុន ក៏ចប់មុនទៅ។

[១០:០៦:៥៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន <ពេលលោកចៅក្រមកំពុងពិភាក្សានេះ> ខ្ញុំសូមធ្វើការកត់សម្គាល់សម្រាប់ជាប្រតិចារឹក ព្រោះថាខ្ញុំទើបតែពិនិត្យផ្ទៀងផ្ទាត់ហ្នឹង គឺថាអង្គជំនុំជម្រះបានទទួលយកវីដេអូហ្នឹងតាំងពីខែមិថុនា ឆ្នាំ២០១៥។ <នេះគឺដើម្បីកែតម្រូវកាលបរិច្ឆេទ។> អ៊ីចឹងគេថតតាំងពី២០១២ ហើយអង្គជំនុំជម្រះទទួលយកនៅខែមិថុនា ឆ្នាំ២០១៥។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវពេលសម្រាកហើយ។ សម្រាកចាប់ពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ អញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(សវនាការសម្រាកពីម៉ោង ១០:០៧ នាទី ដល់ម៉ោង ១០:២៩ នាទី)*

[១០:២៩:៣៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយអង្គជំនុំជម្រះសម្រេចផ្តល់វេទិកា -- អ៎! ផ្តល់ពេលវេលាបន្ថែមទៅក្រុមមេធាវីការពារក្តីទាំងពីរក្រុមចំនួនរយៈពេល១៥នាទី។ ហើយនៅព្រឹកនេះ អង្គជំនុំជម្រះធ្វើសវនាការរហូតដល់ម៉ោងដប់មួយនិងសែសិបប្រាំនាទី រហូតដល់ចប់ការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

ផ្តល់វេទិកាជូនទៅលោកមេធាវីការពារ លោកមេធាវីការពារក្តីលោក នួន ជា គឺលោកមេធាវី វ៉ិចទ័រ កូប៉េ បន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតស្នើសុំពីលោកប្រធាន គឺសុំឱ្យខាងសោតទស្សន៍បង្ហាញខ្សែវីដេអូពីរ គឺទី១ គឺការសន្ទនារវាងដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងបងថ្លៃ<ប្តីទី១>របស់គាត់ គឺនាទី ៣១:២២វិនាទី ដល់៣៤:២៦វិនាទី។ ហើយចំពោះខ្សែអាត់វីដេអូទី២ គឺនាទី៤១:០០ ដល់៤៣:០០នាទី គឺជាការសន្ទនាគ្នារវាង<គាត់ជាមួយ> អ៊ុំ នៅពេលដែលគាត់បង្ហាញនូវរូបថតមួយសន្លឹកនេះ។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីឱ្យខាងសោតទស្សន៍ចាក់បញ្ចាំងនូវខ្សែអាត់វីដេអូពីរខ្សែអាត់ដែលខ្ញុំបានស្នើសុំនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយឱ្យផ្នែកខាងអេ.វី ចាក់ផ្សាយនូវវីដេអូឃ្លីបលើអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់មេធាវី វ៉ិចទ័រ កូប៉េ។

[១០:៣២:១១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...សុចាន់៖ កាលខ្ញុំជួបបងឯងនៅវត្តហ្នឹង វា កាលហ្នឹងខែភ្ជុំ ភ្ជុំជិតផ្លូងអ្វីបង? (មិនស្គាល់អត្ត*

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

សញ្ញាណ)៖ ភ្ជុំថ្ងៃឆ្លងបណ្ដោយហ្នឹង។ សុចាន់៖ អើ! ខ្ញុំឃើញបងឯង ខ្ញុំស្មានតែបងឯងនៅវត្ត -- អ៎! នៅប្រឡាយរំដេង។ អ៎ នៅអាដែងប្រឡាយរំដេងយើង ព្រៃធំណ៎ា។ មានដឹងថា បងឯងនៅបាក់មែកនេះណ៎ា។ ដល់ពេលខ្ញុំ ជួបបងឯងនៅបាក់មែកហ្នឹង ចង់មកលេងជាមួយបងឯង។ ចង់សួរធ្វើដូចថា ចង់ដឹងរឿងការពិតរបស់ខ្ញុំ កាលពីសម័យខ្មែរក្រហមហ្នឹង។ ដែលរៀបការប្អូនបងឯងហ្នឹង ពេលគេរៀបការខ្ញុំ បងឯងមានដឹងថា គេទៅសួរខ្ញុំ ទៅប្រាប់ខ្ញុំ ហើយបងឯងមានស្គាល់ខ្ញុំ ហើយប្ដីខ្ញុំហ្នឹង ដូចថាគាត់នៅកន្លែងណា មេកងគាត់នៅកន្លែងណា? ប្អូនបងឯងហ្នឹងនៅអង្គភាពណា? ខ្ញុំថាមកសួរបងឯង ចង់ដឹងច្បាស់ថា ខ្ញុំដូចឆ្ងល់ថាម៉េចបានជាខ្ញុំ ហើយគាត់ហ្នឹងទៅជួបគ្នា អង្កាល់ហ្នឹង? ដូចថាចង់ជួប ចង់សួរ ថា បងឯងហ្នឹងមេកង ក្រែងលោដឹងខ្លះអ៊ីចឹង។ ហើយដល់ពេលអ៊ីចឹងបងឯងមានដឹងមុនទេ? (មិនស្គាល់អត្តសញ្ញាណ)៖ អត់ទេ អត់មានបានដឹងទេ។ ហើយដឹងថា កាលពីដំបូងបង្អស់ គេឲ្យវាទៅនៅកងចល័តឯកោងកាង ចល័តស្រុកគេ រួចគេរំសាយមកតាមសហករណ៍ហ្នឹង ក៏គេ វាឲ្យវានៅកងភ្ជួរ។ សុចាន់៖ ចាស។ (មិនស្គាល់អត្តសញ្ញាណ)៖ ដល់ពេលគេកំណត់រៀបការហ្នឹង រៀបវាច្រើនគូ ប៉ុនមិនដឹងណាខ្លះ ដល់គេប្រាប់ថាប្អូនដែរហ្នឹង។ ហើយអញហ្នឹង ក៏មិនពេញចិត្តអ្ហែង ទាក់ទាញឲ្យសួរអីដែរ ក៏អត់ទេ។ សុចាន់៖ អត់ដឹងដែរ? (មិនស្គាល់អត្តសញ្ញាណ)៖ អើ! ដល់ពេលគេការ បានដឹង។ គេប្រាប់ថា ប្អូនមិត្តឯងត្រូវរៀបការជាមួយ--។ សុចាន់៖ ចុះពីអ្នកណាគេអ្នកប្រាប់? (មិនស្គាល់អត្តសញ្ញាណ)៖ អាណា មីអុំមីអីហ្នឹង អ្នកនៅជាមួយគ្នាហ្នឹង។ សុចាន់៖ វាមិនបានស្គាល់អាប្ដីខ្លួនឯងហ្នឹង អារៀបការសម័យគ្រួសារកាលសម័យខ្មែរក្រហមហ្នឹង អត់ដែលស្គាល់មុខ។ គាត់ ខ្ញុំចងចាំជាមួយគាត់ហ្នឹង វាគ្មានកន្លែងចងចាំថាឲ្យពាក្យល្អដាក់ប្អូនបងឯងអត់ទេ គ្មានដែលបានថា ដឹងថាល្អយ៉ាងម៉េច អាក្រក់យ៉ាងម៉េច ព្រោះដេកមិនដែលទល់មុខគ្នា ហើយក៏មិនដែលមើលមុខគ្នា ហើយមិនដែលដេកថា ឲ្យមានសិទ្ធិសេរីភាពក្នុងខ្លួនទេបង ខ្ញុំជួប។ អត់មានចិត្តថា ប្ដីខ្ញុំ បងខ្ញុំ ធ្វើអី នៅឯណា អត់មានចាប់អារម្មណ៍សួរគ្នា ថាម៉ែឪនៅឯណាអត់។ អត់ដែលបានថា គឺតែជួបគ្នាដឹងតែពីទឹកភ្នែកតែម្ដង ឲ្យតែជួបគ្នា ដឹងតែ--។ គាត់ហ្នឹងក៏គាត់ស្ដាប់ឈ្លប ហើយដឹងតែខោ យប់ឡើងតែពីរដាន់។ យប់ ថ្ងៃក៏ដូចនៅអារម្មណ៍ ថាជួបប្អូនបងឯង គ្មានកន្លែងសុខ ព្រោះយើងអត់ស្រឡាញ់ អ្ហ៎បង។ (មិនស្គាល់អត្តសញ្ញាណ)៖ រឿងហ្នឹង ជំនាន់ហ្នឹង តែថាមាត់ណាមាត់ហ្នឹង។ ថាអង្គការគេចាត់តាំងអាម៉េច គឺអ៊ីចឹង ព្រោះអីរបបគេផ្ដាច់ការអ៊ីចឹង។ មួយម៉ាត់ងាប់ ម៉ាត់រស់។ និយាយត្រូវរស់ និយាយសុខងាប់។ តែប៉ុណ្ណឹងឯង។

សុចាន់៖ តាំងពីជួបបងថ្លៃហ្នឹងមក មិនទឹកស្មានថា គាត់និយាយមកកាន់យើងអ៊ីចឹងសោះ។ ជួប

*គាត់ហើយ យើងមានតែភាពអាម៉ាស ខ្មាស់ខ្លាំងជាងមុន។ យើងក្រឡេកមើលទៅមេខ្មែរក្រហម រស់នៅឃុំភូមិជាមួយគ្នា យើងចង់សួរគេដែរ ប៉ុន្តែយើងមិនបាន។...”*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:៣៥:៤១]

**លោក វិចទ័រ កូប៉េ៖**

ប្រហែលជាខាងសោតទស្សន៍ គាត់មិនទាន់បាន ប៉ុន្តែខ្ញុំសូមអនុញ្ញាតម្ដងទៀត គឺសូមឲ្យចាក់នូវខ្សែអាត់ទី២របស់ខ្ញុំ។

[១០:៣៥:៥៣]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*“...(មិនស្គាល់អត្តសញ្ញាណ)៖ នេះកន្លែងរោងដាំបាយ យើងដើរពីនោះមកអ៊ីចេះ ហូបបាយ។ សុចាន់៖ បាយកន្លែងផ្ទះគេនេះ--។ (មិនស្គាល់អត្តសញ្ញាណ)៖ (ឮមិនច្បាស់) កន្លែងបាយកន្លែងហ្នឹងឯង។ នេះ! យើងមិនព្រម គេធ្វើបាបយើងអ៊ីចឹងឯង។ ហើយយើងមិនដឹងធ្វើម៉េច ព្រោះយើងរស់នៅក្រោមរបបគេ។ សុចាន់៖ (យ៉ំ)។ (មិនស្គាល់អត្តសញ្ញាណ)៖ គេវាប់យើងអ៊ីចឹងឯង។ សុចាន់៖ ហេតុអីសម័យនុ៎ង កាលហ្នឹងរូបខ្ញុំអ៊ីចឹង (យ៉ំ)។ អាហ្នឹងនៅទួលស្លែង បើនៅវាលត្បែង បានឮដួយ។ (មិនស្គាល់អត្តសញ្ញាណ)៖ ព្រោះអស់ហើយ បើគេសម្លាប់ចោល ភ្លឺបៗតែម្ដងទៅ វាធូរ វាអ៊ីចឹង។ សុចាន់៖ ដល់ពេលទារុណកម្មហ្នឹង នឹក សូម្បីតែនិយាយយប់ក៏ខ្ញុំយំដែរបង រឿងហ្នឹង។ (មិនស្គាល់អត្តសញ្ញាណ)៖ មិនដឹងធ្វើម៉េច! នៅស្អីទៀតអូន? ឆ្លល់ពីស្អីទៀត? សុចាន់៖ ខ្ញុំចេះតែឆ្ងល់ នូវភាពឈឺចាប់របស់ខ្ញុំ ៗអត់ភ្លេចទេ កាលហ្នឹងឡើងប្ដេជ្ញាអ៊ីចេះ ជាពាក្យសមរម្យណ៎ាបងពីសម័យហ្នឹង វាទូទៅ មិនមែនតែរូបខ្ញុំទេ កាលសម័យហ្នឹង ប៉ុន្តែរូបនេះជារូបខ្ញុំ ជាម្នាក់ឯង គ្មានគេដូចខ្ញុំ តែសម័យហ្នឹងគេមានដូចខ្ញុំអ៊ីចឹងដែរអត់? (មិនស្គាល់អត្តសញ្ញាណ)៖ វាមានឆ្លងកាត់គ្រប់តែរូបហ្នឹង ឲ្យតែរូបណាដែលមិនៗពេញចិត្ត។ សុចាន់៖ តែគេថតនេះ មិនមែនរឿងប្រឌិតទេបង គឺរឿងពិត អានេះខ្ញុំឃើញ រូបខ្ញុំដែលខ្ញុំឈរនិយាយនៅកន្លែងហ្នឹង កន្លែងការដ្ឋាន ដូចជាអតីតប្រវត្តិខ្ញុំនៅកន្លែងហ្នឹង ខ្ញុំឈឺចាប់បំផុតនៅកន្លែងហ្នឹង។ ប៉ុន្តែហ្នឹងរូបនេះជារូបពិត យើងមិនអាចប្រកែកនឹងវាបានទេ កាលហ្នឹង (យ៉ំ)។ (មិនស្គាល់អត្តសញ្ញាណ)៖ វាមិនដឹងទៅធ្វើម៉េច?”*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៣៨:០៦]

**លោក វ៉ិចទ័រ កូប៉េះ**

ប្រហែលជាយើងៗត្រូវសម្រាក ឬក៏ផ្អាកមួយភ្លែតសិន លោកប្រធាន។

*(ដើមបណ្តឹងរដ្ឋប្បវេណីកំពុងយំ)*

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើលោកស្រីមានអារម្មណ៍ធូរស្រាលឡើងវិញសូមប្រាប់ឲ្យយើងដឹង ដើម្បីជាកំណត់ត្រាប្រតិចារឹកក្នុងពេលឥឡូវនេះ ដើមបណ្តឹងរដ្ឋប្បវេណីគាត់កំពុងតែយំ។

**លោកស្រី ប៉ែន សុចាន់៖**

ចាស អត់អីទេ លោកប្រធាន *(កំពុងយំ)*។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី កាលពីមុនយើងឈប់សម្រាកបន្តិច គឺខ្ញុំបានសួរលោកស្រីអំពីរូបថត ដែលលោកស្រីបង្ហាញទៅ អ៊ុំ។ នៅក្នុងខ្សែវីដេអូ យើងឃើញថា លោកស្រីនិយាយថារូបថតហ្នឹងជារូបថតពិត។ ដូច្នេះខ្ញុំចង់ដឹងថា តើអ្នកណាជាអ្នកផ្តល់រូបថតនេះទៅឲ្យលោកស្រី?

[១០:៣៩:៣៩]

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស លោកប្រធាន រូបថតនេះ គេចង់យករូបនាងខ្ញុំប្រដូច តែបើខ្ញុំដេកធ្វើទៅ វាភាពអាម៉ាសច្រើន។ អ៊ីចឹងខ្ញុំសូមឲ្យគេសំណូមពរគូរជារូប ប៉ុន្តែខ្ញុំមិនដូចមានគេចាប់ជើងខាងក្រោមពីរទេ គ្រាន់តែគេចងដៃខ្ញុំឡើងលើ ប្តីខ្ញុំសម្រាតពីខ្ញុំអស់ គេរំលោភខ្ញុំចាស។ នេះជាភស្តុតាង តែធ្វើអ៊ីចឹងពិតដូចរូបមីងដែរអត់ នោះគេមិនបានប្រឌិតមកពីណាទេ គឺខ្ញុំឲ្យធ្វើជាៗរូបហ្នឹងជារូបរបស់ខ្ញុំ បានធ្វើអ៊ីចឹង។ ខ្ញុំមានតែឈ្លបប្រាំនាក់ទេឈរមើល តែគេមិនបានមកកាន់រូបរាងកាយនាងខ្ញុំទេ។ តែរូបគេស្រាតនោះហ្នឹងរូបជារបស់ខ្ញុំ ដែលដៃខ្ញុំចំណងទៅជញ្ជាំងហើយៗ។ តែឈ្លបគេឈរមើល គេបានពោលថា "អើ! ម្អែងធ្វើអ៊ីចឹងបានល្អជូនកូនអង្គការ អ្នកណារឹងនឹងសម្លាប់ចោល" គេបានសើចហើយក៏គេដើរចេញបាត់ទៅ។ រូបថតនេះមិនមែនជាគេប្រឌិតមកឲ្យខ្ញុំទេ ខ្ញុំអ្នកឲ្យគេប្រឌិតឲ្យខ្ញុំឃើញរូបហ្នឹង ខ្ញុំអាចទៅសួរមេកង។ ហើយក៏មេកងលោក គេមានប្រសាសន៍ គឺលោកបានឮហើយគេធ្វើអ៊ីចឹង បើមិនធ្វើអ៊ីចឹងគេសម្លាប់

ចោល។ គេបាននិយាយនៅក្នុងហ្នឹងហើយចាស។

**ស៖** តើលោកស្រីបានស្នើសុំឱ្យផលិតករភាពយន្តគូររូបភាពនេះមែនទេ?

**ឆ៖** ចាស ខ្ញុំថាឲ្យខ្ញុំដេកហើយធ្វើខ្ញុំមិនៗពេញចិត្ត។ ខ្ញុំឲ្យគេគូរជារូប បញ្ជាឲ្យគេគូររូបហ្នឹងធ្វើអ៊ីចឹងទៅរបបផ្ដាច់ការបានធ្វើបាបខ្ញុំបែបនេះ ឲ្យខាងភ្ញៀវបរទេសគាត់បានឃើញ ឲ្យតុលាការគាត់បានឃើញ ថារូបនាងខ្ញុំគឺអ៊ីចឹងពិតប្រាកដមែនចាស។

[១០:៤១:៤៣]

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកស្រីបន្តទៅទៀត ប្រសិនបើខ្ញុំនិយាយខុសលោកស្រីប្រាប់ខ្ញុំផង។ ប៉ុន្តែតាមរយៈខ្សែវីដេអូហ្នឹង យើងឃើញថាលោកស្រីប្រាប់ អ៊ុំ ថារូបភាពនេះ រូបភាពហ្នឹងកើតនៅវាលត្បែង។ តើលោកស្រីមានប្រាប់ អ៊ុំ នៅពេលដែលលោកស្រីបង្ហាញរូបថតហ្នឹង ថារូបភាពហ្នឹងឬក៏ហេតុការណ៍ហ្នឹងវាកើតនៅវាលត្បែងទេ?

**ឆ៖** ហេតុការណ៍ហ្នឹងកើតនៅវាលត្បែងចាស។

**ស៖** ប៉ុន្តែនៅក្នុងខ្សែអាត់វីដេអូដែល នៅក្នុងវីដេអូដែលនេះ គឺលោកស្រីនិយាយអំពីរោងអាហារ រោងបាយ <ហើយនៅក្នុងសក្ខីកម្មផ្សេងទៀត>លោកស្រីបាននិយាយអំពីផ្ទះមួយដែលលោកស្រីនៅជាមួយប្ដីលោកស្រីនៅយប់ដំបូង។ តើផ្ទះហ្នឹងនៅវាលត្បែងឬក៏នៅយ៉ាងម៉េចដែរ? តើលោកស្រីអាចពន្យល់ចំណុចនេះឲ្យលម្អិតបន្តិចបានទេ?

**ឆ៖** នៅវាលត្បែងចាស។

**ស៖** អ៊ីចឹងមានន័យថា យប់ទី១ និងយប់ទី២ ដែលលោកស្រីនៅជាមួយប្ដីហ្នឹងគឺនៅវាលត្បែងអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** តើវាលត្បែងហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** កាលដែលខ្ញុំបានដាក់នោះ គឺខ្ញុំមិនបានដាក់នៅវាលត្បែងទេ ខ្ញុំនៅដាក់ភូមិប្រឡាយរំដេងលោកប្រធាន។ សូមបញ្ជាក់មើលម្ដងទៀតចាស។

[១០:៤៣:៤៩]

**ស៖** អាហ្នឹងខ្ញុំយល់ ប៉ុន្តែខ្ញុំចង់ដឹងថាវាលត្បែងហ្នឹងជាកន្លែងអី? ហើយវាលត្បែងហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** ភូមិប្រឡាយរំដេងហ្នឹងជា ខាងទំនប់១៧មេសា ពួករបបផ្ដាច់ការឲ្យយើងរែក ប្រើធ្វើការក្នុងមួយថ្ងៃ១២ម៉ែត្រគូប។ ខ្ញុំធ្វើមិនដែលរួចទេ គឺកន្លែងហ្នឹងកន្លែងកងយុទ្ធនារី គេធ្វើការកម្លាំងៗគេហៅពីសម័យខ្មែរក្រហមគេហៅ "កងពិសេស" ត្រង់ហ្នឹងចាស។

**ស៖** ប្រហែលជាខ្ញុំសួរមិនច្បាស់លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី គឺថា អ៊ុំ គិតថារូបភាពហ្នឹងនៅវាលត្បែង។ តើវាលត្បែងហ្នឹងជាកន្លែងអី? ជាមន្ទីរសន្តិសុខ ជាទីរួមស្រុក ជាទីប្រជុំជន ឬក៏ជាអីដែរ? ខ្ញុំចង់ដឹងថាវាលត្បែងហ្នឹងជាកន្លែងអ្វី?

**ឆ៖** ចាស នៅវាលត្បែងហ្នឹងគឺ យប់ដែលយើងដេក។ គេការហើយ គេបញ្ជូនយើងពីដើមរកាទៅ គេដាក់ក្នុងភូមិហ្នឹង គេដាក់ជាក្រុមៗ។ តែខ្ញុំកើតហេតុការណ៍គឺនៅកន្លែងហ្នឹងចាស។ មិនមែនជាកន្លែងកងពល កងនោះទេ ជាកន្លែង ជាកងនារី សមមិត្តហ្នឹងគាត់នៅកាន់ក្ដាប់កន្លែងរបបផ្ដាច់ការ ឲ្យកម្លាំងស៊ីបាយ មួយថ្ងៃ១០នាក់១កំប៉ុងគឺ១០នាក់។ ហើយប្រើឲ្យពលកម្មនោះ ក្នុងមួយថ្ងៃរែកដី១២ម៉ែត្រគូប ជម្រៅមួយម៉ែត្រ ទៅមុខ១២ម៉ែត្រគូប។ បើមិនហើយគេកសាង បើហើយគេថាឲ្យមាន់ស្មោរអ៊ីចឹងទៅណា លោកប្រធាន។ ជាកន្លែងធ្វើការទេចាស។

[១០:៤៥:៤៦]

**ស៖** ឥឡូវនេះខ្ញុំបញ្ជាក់ឲ្យច្បាស់បន្តិច។ ម្សិលមិញ លោកស្រីបាននិយាយអំពីរាត្រីផ្សំដំណេកនៅ<យប់>ទី១ និង<យប់>ទី២។ អំពីអ្វីដែលកើតឡើង គឺវាមិនដូចគ្នាទៅនឹងអ្វីដែលកើតឡើងចំពោះលោកស្រីនៅវាលត្បែង ដូចដែលលោកស្រីបង្ហាញប្រាប់ អ៊ុំ ទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** តែខ្ញុំអត់បានដាក់នៅវាលត្បែងទេ លោកប្រធាន។

**ស៖** ប្រហែលជាមានបញ្ហាបកប្រែ ប៉ុន្តែខ្ញុំ បើតាមអក្សរនៅក្នុងខ្សែវីដេអូ ជាភាសាអង់គ្លេសហ្នឹង អ៊ុំ ប្រើប្រាស់ពាក្យ "វាលត្បែង" បានន័យថា គាត់យល់ឃើញថា រូបភាពហ្នឹងគឺវាកើតនៅទីនោះ គឺថាជារូបភាពដែលកើតឡើង ដែលលោកស្រីនិយាយថា កើតឡើងចំពោះលោកស្រីហ្នឹង គឺវាកើតឡើងនៅវាលត្បែង។ តើអ៊ីចឹងមែនទេ?

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

ខ្ញុំគិតថាប្រហែលជាមេធាវីការពារក្ដីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការទាយស្មានហើយ ទាក់ទងទៅនឹងអ្វីដែល អ៊ុំ បាននិយាយនៅពេលនោះ។ ដូច្នេះខ្ញុំគិតថា--

**ចៅក្រម ក្លូឌា ហ្វេនស៖**

ខ្ញុំគ្រាន់តែគិតថា មេធាវីគាត់ចង់និយាយអំពីអ្វីដែល អ៊ុំ និយាយនៅក្នុងខ្សែវីដេអូ។ <តើអ៊ីចឹងមែនទេ?>

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថា អ៊ុំ គាត់និយាយ<អំពីវាលត្បែង> នៅក្នុងខ្សែវីដេអូ មិនមែនជាការទាយស្មាននោះទេ។

[១០:៤៧:៣៣]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

ខ្ញុំឃើញពាក្យ "វាលត្បែង" ប៉ុន្តែខ្ញុំមិនច្បាស់ ថាតើសំណួរហ្នឹងគ្រាន់តែសួរថា គាត់និយាយថា វាលត្បែង ឬមួយក៏ អ៊ុំ ជឿជាក់ថា ហេតុការណ៍នេះកើតឡើងនៅវាលត្បែង។ <ទាំងពីរនោះជាសំណួរខុសគ្នា។>

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំបញ្ជាក់ឡើងវិញឲ្យបានច្បាស់បន្តិចចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងឈុតដែលលោកស្រីនិយាយជាមួយ អ៊ុំ អំពីវាលត្បែងនោះ គឺថាឈុតដែលលោកស្រីបង្ហាញរូបថតហ្នឹង គឺគាត់និយាយអំពីវាលត្បែង។ អ៊ីចឹងលោកស្រីគិតថា ហេតុការណ៍ដែលលោកស្រីរៀបរាប់ប្រាប់ អ៊ុំ ហ្នឹងគឺថា លោកស្រីគិតថា អ៊ុំ ហ្នឹងក៏គាត់ដឹងថា ហេតុការណ៍ហ្នឹងកើតនៅវាលត្បែងដែរឬទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺលោកកំពុងតែសួរដើមបណ្ដឹងឲ្យទាយស្មាន ថាអ្នកដទៃហ្នឹង គេគិតយ៉ាងម៉េចហើយ។ វាជាការទាយស្មាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែនេះជាការសន្ននាទល់មុខគ្នា។ យើងឃើញថា អ៊ុំ ក៏គាត់និយាយអំពីវាលត្បែងដែរ គឺថានៅក្នុងហេតុការណ៍ដែលបង្ហាញនៅក្នុងរូបថតនោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូចឥឡូវខ្ញុំសួរអ៊ីចេះវិញ តើលោកស្រីមានប្រាប់ អ៊ុំ ថារូបថតដែលលោកស្រីបង្ហាញ អ៊ុំ ហ្នឹង ថារូបថតហ្នឹងវាជាហេតុការណ៍កើតឡើងនៅវាលត្បែងទេ?

[១០:៤៨:៥៩]

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ខ្ញុំអត់បានប្រាប់ទេ លោកប្រធាន។

**ស៖** អ៊ីចឹងខ្ញុំសួរបន្តទៀត។ តើលោកស្រីបានឮ អ៊ុំ និយាយអំពីវាលត្បែងទេ នៅក្នុងខ្សែអាត់ នៅក្នុងខ្សែវីដេអូដែលខ្ញុំបង្ហាញនោះ? ប្រសិនបើលោកស្រីបានឮ អ៊ុំ និយាយអំពីវាលត្បែងដែរ ខ្ញុំចង់សួរថាហេតុអ្វីបានជា អ៊ុំ គាត់និយាយអំពីវាលត្បែង?

**ឆ៖** វាលត្បែង ទីតាំងរបស់គាត់ គាត់កាន់ក្តាប់នៅទីនោះ ហើយគាត់បានឃាតករដែលដល់ផង។

**ស៖** ខ្ញុំប្រហែលជាត្រូវពិនិត្យមើលទៅលើប្រតិចារឹកឡើងវិញម្តងទៀតហើយមើលទៅ។ ឥឡូវអ៊ីចេះវិញ ប្រសិនបើខ្ញុំនិយាយខុស លោកស្រីប្រាប់ខ្ញុំ។ អ៊ីចឹងបានន័យថា លោកស្រីមិនចង់ថា ហេតុការណ៍នៅក្នុងរូបថតហ្នឹង កើតឡើងនៅក្នុងវាលត្បែងទេ តើត្រូវ ឬក៏ខុស?

**ឆ៖** មិនកើតនៅវាលត្បែងទេ កើតនៅភូមិដើមរកា។ វាលត្បែងដូចអត់មានទេ ខ្ញុំដាក់តែប្រឡាយរំដេង។ ដែលវាលត្បែង ខ្ញុំសូមបដិសេធ។

**ស៖** មិនអីទេ លោកស្រី ខ្ញុំទុកម៉្ងសិនចុះ។ ឥឡូវនេះខ្ញុំបន្តទៅចំណុចមួយទៀត ទាក់ទងទៅនឹងខ្សែវីដេអូទី១ គឺជាការជជែកគ្នាជាមួយនឹងបងថ្លៃ គឺបងស្រីរបស់ប្តីទី១ លោកស្រីនោះ ឈ្មោះ <តាក់ សាត>។ ខ្ញុំចង់សួរថា ហេតុអ្វីបានជាលោកស្រីមានអារម្មណ៍ថា លោកស្រីត្រូវបានគេប្រមាថមើលងាយ ក្រោយពេលដែលជជែកគ្នាជាមួយបងថ្លៃរបស់លោកស្រីហើយនោះ?

[១០:៥១:១៩]

**ឆ៖** ខ្ញុំ ថ្ងៃដែលខ្ញុំបាននិយាយ ខ្ញុំដាក់ពាក្យបណ្តឹងនោះ ខ្ញុំបាននិយាយថា បើមិនទៅជួបគេ ល្អសោះ ដល់តែជួបគេ ខ្មាសគេកាន់តែច្រើន តូចចិត្តខ្លួនឯងកាន់តែច្រើន។ បើគេឆ្លើយថា អញមិនបានទៅសួរអ្អែងឲ្យប្អូនអញទេ អញមិនដឹងទេ អញដឹងតាមគេដែរ។ តាំងខ្ញុំសួរទៅ ឃើញថាមានចម្លើយនៅក្នុងហ្នឹងហើយ គេថា មីអ៊ុំ ប្រាប់អញ អញដឹងអ៊ីចឹង។ តើលោកប្រធានបានឮដែរឬអត់ នៅក្នុងហ្នឹងហើយ។

**ស៖** ខ្ញុំយល់ ប៉ុន្តែហេតុអ្វីបានជាលោកស្រីអៀនខ្មាស? ហេតុអ្វីក៏ -- តើមូលហេតុអីធ្វើឲ្យលោកស្រីមិនជឿទៅលើអ្វីដែលគាត់និយាយនោះ?

**ឆ៖** មូលហេតុជាខ្ញុំជាស្រីនារីខ្មែរដែរ ដល់ពេលទៅសួរគេ យើងជាស្រីទៅសួរគេ គេឆ្លើយអ៊ីចឹងមក យើងមានសិទ្ធិខ្មាសគេបាន។ តូចចិត្តក្នុងខ្លួនឯង មិនច្រឡំគេ ចង់ដឹងរឿងពិត គេប្រាប់រឿងពិតមក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យើងកាន់តែឆ្អែតថែមទៀត។

**ស៖** ខ្ញុំយល់ ប៉ុន្តែដែលលោកស្រីអៀនខ្មាសហ្នឹង ដោយសារតែគាត់និយាយកុហក ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** អាហ្នឹងជារឿងរបស់គាត់ ខ្ញុំមិនដឹងឆ្លើយប្រាប់លោកប្រធានថាម៉េចទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនអីទេ ខ្ញុំបន្តទៅមុខទៀត។ លោកប្រធាន ខ្ញុំសុំអនុញ្ញាតបង្ហាញនូវខ្សែអាត់វីដេអូទី៣ និងទី៤ គឺនៅនាទី<០៩:៤០>វិនាទី និងនាទី១១:៣០ គឺជាខ្សែវីដេអូ ដែលគាត់និយាយអំពីហេតុការណ៍មួយដែលកើតឡើងនៅក្នុង<យប់>អាពាហ៍ពិពាហ៍លើកទី១របស់គាត់។

[១០:៥៣:៣៥]

**ប្រធានអង្គជំនុំ៖**

ផ្នែកខាង អេ.វី ចាក់ផ្សាយនូវខ្សែវីដេអូឃ្លីបផ្នែកពាក់ព័ន្ធតាមសំណើសុំរបស់មេធាវី វ៉ិចទ័រ កូប៉េ លើអេក្រង់ទូរទស្សន៍។

[១០:៥៣:៥៦]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...គេឲ្យយើងរៀបការអ៊ីចឹងទៅ ដឹងវារៀបការដើម្បីស្អីវាទេ។ ហើយវាធ្វើបាបយើង យប់ទី១ វាចាប់យើងសម្រាតខោ សម្រាតអាវយើងអស់។ វាធ្វើបាបឲ្យស្លាប់ គេឲ្យឈ្លបលបមើលហើយ គេឲ្យយើងចងដៃយើងឡើងទៅក្រោយអ៊ីចឹង វាអត់មានធ្វើអីយើង -- យើងមានធ្វើអីវាកើត ហើយវាចាប់ហែកអាវ ហែកខោ កាលហ្នឹងអញ់ស្លៀកខោជល់តែពីរជាន់។ វាហែកខោ ហែកអាវយើងខ្ទេច ហែកខោ ហែកអាវយើងចោលអ៊ីចឹង វាចាប់បានខ្លួនយើង។ ដល់យប់ទី២ ដល់តែយប់ទី២ បានពូជួយយើងបានរួចមួយយប់ទៀត។ ប៉ុន្តែយើងនឹកឃើញនិយាយរឿងហ្នឹង អត់ចង់និយាយ ព្រោះកន្លែងហ្នឹង ស្អប់ខ្ពើមវាកន្លែងហ្នឹងតែម្តង ស្អប់ផ្ទះវាហ្នឹង ហើយមិននឹកឃើញថា ចង់និយាយ មិនដែលកូនចៅជំនាន់ហ្នឹងដឹងទេ តែយប់អ៊ីចេះ ចេះតែជំនុំគ្នាជជែកលេងអីអ៊ីចឹង។ កូនដេកលក់ស្ងាត់អស់អ៊ីចឹង យើងជជែកទៅភាពអាម៉ាស់កន្លែងវាឲ្យយើងទៅនៅ ដូចឋាននរក ឋានប្រេតអ៊ីចឹង វាដូចមិនស្មើខ្លួនយើង។ ដល់ពេលខ្លួនយើងពេញស្រឡាញ់ ពេញស្អាតទៅ គេធ្វើបាបចិត្តយើងទៅរៀបការជាមួយពួកនុ៎ង ហើយវាធ្វើបាបយើង។ ឈ្លបនុ៎ងហែកជញ្ជាំងលបមើលយើងអ៊ីចឹង។ អាណិតខ្លួនឯង កាលវាចាប់រៀបការហ្នឹងហើយ*

*ស្តាយណាស់ ឈាន អ្អើយ! អញប្តីក្រោយនេះ ក៏គេមិនដេញដោលសួរអញ ថាម៉េច អត់។ អញស្តាយខ្លួនអញ ជាងស្តាយអីទៀត មីឈាន អញស្អប់ណាណាស់។ ហើយដែណា! ដែលនឹកសម័យនុ៎ងវាប៉ះ បើសិនណាកុំឱ្យឈឺ អញអារគ្រវាត់ចោលអស់ហើយហង។ ហើយបើអញអត់លេបថ្នាំ អញដេកមិនលក់ទេ រាល់ថ្ងៃហ្នឹង អញដាក់អាថ្នាំសរសៃ...”*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:៥៥:៥៤]

**សួរដោយលោក វិុចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរពីរបីប៉ុណ្ណោះ ទាក់ទងទៅនឹងខ្សែវីដេអូនេះ ហើយសហការីខ្ញុំ គាត់នឹងសួរបន្ថែមទៀត។ គឺមានពីរចំណុចដែលខ្ញុំចង់សួរលោកស្រី នៅក្នុងខ្សែវីដេអូត្រង់ចំណុចនេះ យើងឃើញថា ប្តីរបស់លោកស្រី គឺជាអ្នកស្នើឱ្យឈ្លបមកតាមដាន តើប្តីរបស់លោកស្រីស្នើសុំឱ្យឈ្លបមកតាមដានមែនទេ?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** នោះសម័យនោះរបបផ្តាច់ការ ខ្ញុំ--

**លោក ពេជ អង្គ៖**

ឈប់! ឈប់! ឈប់សិន!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(គ្មានការបកប្រែ)*

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ ខ្ញុំមើលទាំងភាសាអង់គ្លេស ហើយនិងភាសា ស្តាប់ភាសាខ្មែរដូចជាមិនបាននិយាយថា ប្តីរបស់លោកស្រីជាអ្នកស្នើឱ្យឈ្លបមកតាមដានទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ពិនិត្យសំណួររបស់លោកឡើងវិញ ហើយសំណួរទំនងជាវាអាចដកស្រង់ខុស ព្រោះដូចជាមិនមានពាក្យ ដើមបណ្តឹងរដ្ឋប្បវេណីនេះស្នើថា -- ប្តីរបស់ខ្លួនស្នើសុំឈ្លបឱ្យតាមដានខ្លួននោះទេ។ បើសិនជាមានលោកអាចដកស្រង់នូវប្រតិចារឹក ឬក៏ចំណុចណាមួយដែលជាឯកសារពាក់ព័ន្ធយកមកបង្ហាញ។

[១០:៥៧:៤១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនអាចបញ្ជាក់បានទេ ប្រហែលជាមេធាវីដើមបណ្តឹងត្រឹមត្រូវ ប៉ុន្តែបើតាមភាសាអង់គ្លេស យើងឮសួរបែបនេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រសិនបើលោកចង់បញ្ជាក់ឲ្យច្បាស់ យើងអាចស្នើសុំឲ្យចាក់ឡើងវិញ។ <នេះជាមធ្យោបាយតែមួយគត់ ឬក៏លោកចង់បោះបង់សំណួរនោះចោល?>

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាលោកប្រធាន ខ្ញុំសូមអនុញ្ញាតឲ្យចាក់ឡើងវិញ គឺចាក់តែផ្នែកដើមដំបូងប្រហែលជា១នាទីដំបូងនៃខ្សែវីដេអូនុ៎ង ហើយបន្ទាប់មកទៀត ប្រហែលជាអ្នកបកប្រែ ក៏គាត់អាចស្តាប់ជាមួយយើងទាំងអស់គ្នាតែម្តងទៅ។

**ប្រធានអង្គជំនុំ៖**

ខាង អេ.វី ចាក់ផ្នែកពាក់ព័ន្ធទាំងអស់ឡើងវិញ អំមិញហ្នឹង អាទី៣ហ្នឹង ឲ្យពេញលេញតែម្តង ហើយចាក់តែម្តងទៀតទេ ពិនិត្យឲ្យបានហ្មត់ចត់។

[១០:៥៨:៤០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"....វាចេះតែឲ្យយើងរៀបការអ៊ីចឹងទៅ ដឹងវារៀបការដើម្បីស្អីវាទេ។ ហើយវាធ្វើបាបយើងហ្នឹង យប់ទី១ វាចាប់យើងសម្រាតខោ សម្រាតអាវយើងអស់។ វាធ្វើបាបឲ្យស្លាប់ គេឲ្យល្អបលបមើលហើយ គេឲ្យយើង ចងដៃយើងទៅឡើងទៅក្រោយអ៊ីចឹង វាអត់មានធ្វើអីយើង -- យើងមានធ្វើអីវាកើត ហើយវាចាប់ហែកអាវ ហែកខោបាត់ កាលហ្នឹងអញស្លៀកខោដល់តែពីរជាន់។ វាហែកខោ ហែកអាវយើងអស់ ហែកខោហែកអាវយើងចោលអ៊ីចឹង វាចាប់បានខ្លួនយើង។ ដល់យប់ទី២ ដល់ទៅយប់ទី២ បានពួជួយ យើងបានរួចមួយយប់ទៅទៀត ប្រសិនបើយើងនឹកឃើញ..."*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:៥៩:២៦]

**លោក វ៉ិចទ័រ កូប៉េ៖**

អ៊ីចឹងខ្ញុំសូមដកសំណួរអំមិញវិញ ដោយសារខ្ញុំយោងតែទៅលើចំណងជើងជាភាសាអង់គ្លេស

នោះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ឥឡូវខ្ញុំសួរពាក់ព័ន្ធទៅនឹងវីដេអូឃ្លីបនេះដដែល លោកស្រីនិយាយថា នៅយប់ទី១ ប្តីរបស់លោកស្រីហ្នឹង គឺថាចាប់លោកស្រី ហើយហែកសម្រាតខោអាវលោកស្រីមិនអាចរើខ្លួនបានទេ។ លោកស្រីនិយាយថា "គាត់ស្រាតខោអាវខ្ញុំចេញអស់ ហើយគាត់ក៏ចាប់ផ្តើមធ្វើឲ្យខ្ញុំមានការឈឺចាប់"។ ខ្ញុំយល់ឃើញវាមិនជា<សំណួរ>ងាយស្រួល<នោះទេ> តើលោកស្រីចង់និយាយថាម៉េចនេះ ជាដែលថាគាត់ -- ពេលហ្នឹងគឺថា គាត់អាចធ្វើឲ្យខ្ញុំឈឺចាប់បាន ចង់និយាយថាម៉េច?

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមសួរបញ្ជាក់ ដោយសារថា សម្រង់ដែលដកមកហ្នឹងមិនដឹងថា យោងទៅលើយប់ទី១ ឬក៏យប់ទី២ នោះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គាត់និយាយអំពីយប់ទី១ គឺថាគាត់ចាប់ខ្ញុំ ស្រាតខោអាវខ្ញុំ ហើយគាត់អាចចាត់ការគឺថា ធ្វើឲ្យខ្ញុំមានការឈឺចាប់បាន។ ជាភាសាអង់គ្លេសដាក់ថា គាត់អាចធ្វើឲ្យខ្ញុំឈឺចាប់បាន។ ចំណុចនេះលោកស្រីចង់និយាយថាម៉េចហ្នឹង នៅពេលដែលលោកស្រីនិយាយទៅជាមួយនឹងផលិតករភាពយន្តនោះ?

[១១:០១:១៤]

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចំណុចនោះដែលខ្ញុំនិយាយឈឺចាប់នោះ ព្រោះកាលខ្ញុំដាក់ពាក្យបណ្តឹងក៏យូរ ហើយដែលថតខ្សែវីដេអូនេះក៏យូរ។ អ៊ីចឹងខ្ញុំអត់មានប្រក្រតីនឹងចាំ និយាយយ៉ាងណា ព្រោះខ្ញុំគ្រាន់តែបររទេះទៅស្រុកគេ ទៅរកស៊ីស្រុកគេ ស្រុកថៃនោះឡើង២ឆ្នាំទៅហើយ គឺខ្ញុំវាភ្លេចមុខ ភ្លេចក្រោយអស់។ ខ្ញុំមិនចាំនឹងសម្តីដែលខ្ញុំនិយាយនោះចង់ប៉ោងថាយ៉ាងណាទេ គ្រាន់តែចង់ដាក់តែពាក្យបណ្តឹងតែប៉ុណ្ណោះ រកភាពយុត្តិធម៌ជូននាង ហើយនិងឲ្យក្មេងសាក្រោយឃើញថា យុត្តិធម៌ហ្នឹងវាយ៉ាងម៉េច។ ផ្តាច់របបផ្តាច់ការនោះយ៉ាងម៉េច តែដែលខ្ញុំដាក់ក្នុងវីដេអូឃ្លីប ដូចខ្ញុំនិយាយនៅក្នុងដើមបណ្តឹងរដ្ឋប្បវេណី គឺខ្ញុំចាំហ្នឹងវាតិច ភ្លេចនោះវាច្រើន ខួរក្បាលខ្ញុំថ្ងៃណាខ្ញុំគិតខ្លាំង ខ្ញុំនិយាយត្រង់នេះខុស ដើរភ្លេចនេះ ភ្លេចនោះ លុយកាក់ក៏ខ្ញុំសឹងតែចាំមិនបាន។ រាល់ថ្ងៃខ្ញុំឧស្សាហ៍លេបថ្នាំសរសៃប្រសាទរាល់យប់ លោកប្រធាន។ បើមិន

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

លេបគឺដេកអត់លក់ លេបទៅបានធាត់មានសាច់នឹងគេទៅ។ ខ្ញុំចាំមិនសូវច្បាស់ទេលោកប្រធាន អាចសួរកុំឲ្យពាក្យដែលមានច្រំដែល ព្រោះខ្ញុំឆ្លើយពីម្សិលមិញកន្លែងរៀបការហ្នឹងរួចអស់ហើយ។ ឥឡូវមកដល់កន្លែងរៀបការហ្នឹងទៀត ខ្ញុំអត់ចង់រំឭករឿងហ្នឹងសាជាថ្មីម្ដងទៀតទេលោកប្រធាន។

**ស៖** ខ្ញុំសូមសួរលោកស្រីឲ្យបានច្បាស់លាស់ តើលោកស្រីនិងប្ដីរបស់លោកស្រីមានបានរួមដំណេកជាមួយគ្នាដែរនៅយប់ទី១?

**ឆ៖** ចាស អត់បានទេ។ ក្រែងតែប្ដីបហ្នឹងដាក់ខុសរបស់ខ្ញុំយ៉ាងម៉េច គឺខ្ញុំនិយាយទៅវាភ្លេចច្រើន តែខ្ញុំដាក់នូវពាក្យបណ្ដឹង វាផ្សេង ខ្ញុំចាំ។ ដល់តែថតហ្នឹង គឺខ្ញុំអត់សូវបានចាំ ដល់មកឃើញអ៊ីចឹងក៏ខ្ញុំចាំទៅវាភ្លេច។

[១១:០៣:១៨]

**ស៖** ខ្ញុំនឹងងាកចេញពីប្រធានបទនេះ ហើយសហការីរបស់ខ្ញុំសួរតាមក្រោយខ្ញុំបន្ថែមច្រើនតទៅទៀត។ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ស្ត្រីម្នាក់ដែលលោកស្រីនិយាយនៅឃ្លីបចុងក្រោយហ្នឹង គឺ <មិត្តភក្ដិលោកស្រី>ឈ្មោះ <ឈាន> ហ្នឹងមែនទេ?

**ឆ៖** អត់ មិនមានឈ្មោះ ឈិន ទេ លោកប្រធាន ឈ្មោះ ឈាន។

**ស៖** សូមទោសដែលខ្ញុំអានឈ្មោះមិនបានច្បាស់ តើ ឈាន នេះជាមិត្តភក្ដិជិតដិតរបស់លោកស្រីមែនទេ នៅសម័យកម្ពុជាប្រជាធិបតេយ្យ? ហើយកូនៗរបស់លោកស្រីហ្នឹងក៏ហៅ ឈាន នេះថាម៉ែដែរ អ៊ីចឹងមែនទេ?

**ឆ៖** ចាស អង្កាល់របបផ្ដាច់ការគេបានលួចដំឡូងឲ្យខ្ញុំហូប អ៊ីចឹងខ្ញុំគេមិនស្លាយពីអាយុជីវិតគេទេ គេទៅលួចមក។ អ៊ីចឹងខ្ញុំស្រឡាញ់គេ ដោយសារដំឡូងមួយដុំ សូមគេជាមិត្តភក្ដិ តែគេបងខ្ញុំទេ តែសូមគ្នាជាមិត្តភក្ដិបាន។ នឹកឃើញកាលខ្ញុំឃ្លាន គេទៅលួចមកឲ្យខ្ញុំហូប។ ជាមិត្តភក្ដិខ្ញុំមែនលោកប្រធាន។

**ស៖** តើលោកស្រី និង ឈាន មានបាននិយាយគ្នាច្រើនទេអំពីអ្វីដែលបានកើតឡើងនៅទាំងយប់ទី១ យប់ទី២ នៃពេល ក្រោយពេលរៀបការរបស់លោកស្រីនោះទេ?

**ឆ៖** អត់បាននិយាយគ្នាច្រើនទេ គ្រាន់តែយប់ហ្នឹង ខ្ញុំនៅម្នាក់ឯង កូនចេញអស់ គេទៅដេកលេងមួយយប់ ក៏ខ្ញុំហ្នឹង អង្គុយនិយាយគ្នាលេងនៅមុខផ្ទះហ្នឹងទៅ ទម្រាំឡើងដេក លោកប្រធាន តែប៉ុណ្ណឹង ដូចក្នុងវីដេអូឃ្លីបហ្នឹងអ៊ីចឹងឯង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:០៥:៣១]

**ស៖** ដោយសារខ្ញុំអស់ពេលវេលាហើយ នេះសំណួរចុងក្រោយរបស់ខ្ញុំ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ តើមានអ្នកណាម្នាក់ដែលលោកស្រីធ្លាប់បានស្គាល់ នៅរស់រានមានជីវិតដល់សព្វថ្ងៃ អាចបញ្ជាក់អះអាងឲ្យស៊ីសង្វាក់គ្នា អំពីរឿងរ៉ាវរបស់លោកស្រីបានទេ? មានន័យថា អ្នកណាម្នាក់ក៏ដោយ គឺក្នុងចំណោមអ្នកដែលគេរៀបការទាំង១២គូ ឬក៏ថាអាចឈ្លបដែលសព្វថ្ងៃ នៅរស់រានមានជីវិត ឬក៏មិត្តភក្ដិណាម្នាក់របស់លោកស្រីនៅរស់រានមានជីវិត អាចបញ្ជាក់អះអាងស៊ីសង្វាក់ ឲ្យវាស៊ីសង្វាក់គ្នាចំពោះដំណើររឿងរបស់លោកស្រីនេះបានទេ?

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

គឺសូមការបញ្ជាក់មួយ។ លោកចង់និយាយថា ភស្តុតាងណាមួយក៏បាន នៅក្នុងវីដេអូនេះ ឬក៏យ៉ាងម៉េច? ដោយសារថា ក្នុងវីដេអូនេះ មានការពិភាក្សាគ្នាច្រើន ជាមួយមនុស្សដទៃៗទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមរៀបចំសំណួរឡើងវិញ តើមានអ្នកណាម្នាក់ ក្រៅពីអ្នកដែលចូលមកថតនៅក្នុងវីដេអូនេះ។ <ដូច្នេះខ្ញុំមិននិយាយអំពី> អ៊ុំ ឬ<ក៏បងស្រីនោះទេ ប៉ុន្តែ>អ្នកណាក៏ដោយ ដែល<>អាចបញ្ជាក់អះអាង<នូវអ្វីដែលបានកើតឡើងចំពោះ>លោកស្រី<>?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** កាលនោះមិនមានទេ លោកប្រធាន មានតែខ្លួនខ្ញុំ។ ព្រោះយើងមិនបានដឹងថា អ្នកណាគេស្រឡាញ់យើង គិតពីយើង កាលសម័យនោះ គឺគ្មានចងមិត្តភក្ដិបាន គ្មានចងបង ចងប្អូនបានទេ។ សម័យនេះអាចចងបាន បើសម័យនោះ ហៅបងតែមួយម៉ាត់ ក៏ដាច់កដែរ។

[១១:០៧:៥៦]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

តទៅនេះ ផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី ខៀវ សំផន ដើម្បីមានសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោក គង់ សំអុន៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរចង់បញ្ជាក់បន្ថែមទៅលើអាយុរបស់អ្នកស្រីនៅពេលរៀបការ។ អ្នកស្រីបានឆ្លើយពីម្សិលមិញហើយថា អ្នកស្រីបានរៀបការប្រហែលជាប្រាំប្រាំមួយខែ មុនពេលវៀតណាមចូល គឺឆ្នាំ៧៨។ អ្នកស្រីក៏បានបញ្ជាក់ផងដែរថា នៅពេលនោះអ្នកស្រីមានអាយុប្រហែល១៥ ទៅ១៦ឆ្នាំ។ ក៏ប៉ុន្តែភាពខុសគ្នានៅក្នុងឯកសារដាក់ពាក្យរបស់អ្នកស្រី គឺឯកសារ E3/6034a ថាអ្នកស្រីអាយុ១៤ឆ្នាំ គឺនៅក្នុងទំព័រ ERN 00579598 ជាភាសាខ្មែរ ហើយភាសាអង់គ្លេស 00891280, ភាសាបារាំង 00900952។ អ៊ីចឹងខ្ញុំចង់ដឹងថា តើភាពខុសគ្នានេះវាកើតឡើងយ៉ាងម៉េច បានជាមានភាពខុសគ្នាដូច្នេះ?

[១១:០៩:៤៣]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

សូមបញ្ជាក់ ERN <ចំពោះឯកសារ>ដែល<គាត់និយាយ>ថា សូមដកស្រង់ "ខ្ញុំត្រូវបានបង្ខំ<ឲ្យរៀបការ>នៅពេលដែលខ្ញុំមានអាយុ១៥ឆ្នាំ" សុំ ERN ជាភាសាអង់គ្លេសផង ត្រង់កន្លែង*ខ្លួត*មួយនេះ។

**លោក គង់ សំអុន៖**

ខ្ញុំ នេះស្ដាប់អត់យល់ច្បាស់ទេ ប៉ុន្តែលោកចង់ដឹងជាភាសាអង់គ្លេស ទំព័រជាភាសាអង់គ្លេស ឬមួយយ៉ាងម៉េច។ ភាសាអង់គ្លេសគឺ 00981280 នៅក្នុង ERN នៃឯកសារ E3/4779។ ហើយ--

*(សម្រាករយៈពេលខ្លី)*

នៅក្នុងឯកសារ E3/6034a គឺត្រង់ទំព័រ ERN 00579598។ នៅក្នុងទំព័រដំបូង អ៊ីចឹងខ្ញុំជឿថា នៅក្នុងភាសាបារាំង -- មានតែភាសាអង់គ្លេសទេ ភាសាបារាំងអាច -- សូមទោស ភាសាអង់គ្លេសអាចនៅទំព័រដំបូងដូចគ្នាបាទ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

ជាថ្មីម្ដងទៀត ERN ដែលខ្ញុំស្ដាប់ឮសួរថា មានលើកឯកសារមកបង្ហាញច្រើន <ប៉ុន្តែលេខឯកសារដែលខ្ញុំបានឮលោកយោង>ចុងក្រោយ<គឺ> E3/6034a ដែលត្រង់នេះ គឺថាគាត់ត្រូវបានបង្ខំឲ្យរៀបការគឺនៅអាយុ១៥ឆ្នាំ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក គង់ សំអុន៖**

បាទសូមថែមមួយទៀត ពីព្រោះវាមានពីរឯកសារ។ ឯកសារមួយទៀតជាភាសាខ្មែរដែរគឺ E3/6034b នៅក្នុងទំព័រទី១ ដូចគ្នា។ អ៊ីចឹងនៅក្នុងឯកសារនេះ ទំព័រ ERN ជាភាសាខ្មែរគឺ 01049457 ដែលមានកំណត់អាយុថា "នាងខ្ញុំបានរៀបការក្នុងអាយុ១៤ឆ្នាំ"។ អ៊ីចឹងនៅក្នុងឯកសារបីបួននេះយើងឃើញថា មាន១៤ មាន១៥ និងមាន១៦។

[១១:១២:៥១]

**សួរដោយលោក គង់ សំអុន៖**

**ស៖** អ៊ីចឹងបញ្ហាខ្ញុំចង់សួរពីភាពខុសគ្នាដែលមាននៅក្នុងឯកសារទាំងអស់នេះ ទាក់ទងនឹងអាយុពេលរៀបការ ហេតុអីបានជាខុសគ្នាដូច្នេះ?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ខ្ញុំអត់បានដាក់១៤ទេ ខ្ញុំដាក់តែ១៥ និង១៦។ បើ១៤ ខ្ញុំនិយាយ១៤គូ។ បើសិនតែនិយាយគឺ ១៤, ១២គូតែប៉ុណ្ណឹង តែខ្ញុំដាក់អាយុ១៤ គឺខ្ញុំអត់បានដាក់ទេ។ ១៤គឺខ្ញុំនៅជាមួយម្ដាយនៅឡើយទេ។

**ស៖** បើអ៊ីចឹងមានន័យថា អ្នកស្រីអត់ទទួលស្គាល់ឯកសារ E3/6034b ដែលជាទម្រង់បែបបទព័ត៌មានបន្ថែមរបស់លោកស្រីធ្វើនៅថ្ងៃទី២៩ ខែ៦ ឆ្នាំ២០១៣នេះទេ។ អ្នកស្រីបដិសេធអានេះ ឬមួយយ៉ាងម៉េច?

**ឆ៖** ពាក្យដែលថាខ្ញុំបដិសេធ ព្រោះខ្ញុំអត់បានដាក់១៤។ ១៤ ខ្ញុំនិយាយតែភាសាដែលដាក់ប្ដីងខ្ញុំដាក់ថ្ងៃការ ១៤គូ ឬ១២គូ កាលហ្នឹងខ្ញុំភ្លេចដែរ។ ទាល់តែបានខ្ញុំសួរគេទៅ ខ្ញុំចាំ តែអ្នកកត់ពីខ្ញុំ ក្រែងលោគាត់ច្រឡំ១៤, ១៥ឆ្នាំ។ រៀបការ១៤ ឬ១២គូតែប៉ុណ្ណឹង ដែលខ្ញុំនិយាយកាលនុំង ខ្ញុំនៅចាំបានអត់ភ្លេចទេ លោកប្រធាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកស្រីចេះអាន ចេះសរសេរដែរឬទេ?

[១១:១៤:២១]

**លោកស្រី ប៉ែន សុចាន់៖**

**ស៖** ខ្ញុំអត់ចេះទេ ហើយដែលដាក់ហើយ ក៏ខ្ញុំមិនដែលបានផ្ទៀងផ្ទាត់អ្វីមួយ ដែលច្បាស់លាស់ដែលសួត្រទៅ ខ្ញុំចាំបានទាំងអស់ តែ១៤, ១៣នេះ គឺខ្ញុំបាននិយាយជាមួយអ្នកដើមបណ្ដឹងមែន ប៉ុន្តែខ្ញុំ

និយាយ១៤គូ។ តែអាយុខ្ញុំដាក់១៥ ទៅ១៦ឆ្នាំ។ តែ១៤ អាយុ១៤ ខ្ញុំស្ថិតនៅជាមួយម្ដាយ ជម្លៀសមក អ៊ីចឹង ខ្ញុំបាននិយាយត្រង់ហ្នឹងមែន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ ប៉ុន្តែម្សិលមិញលោកស្រីមានប្រសាសន៍ជាមួយមេធាវីនាំមុខរបស់អ្នកស្រីហ្នឹងថា អ្នកស្រីរៀបការ១២គូ រួមទាំងអ្នកស្រីផង អ៊ីចឹងមិនមែនតួលេខ១៤ទេ។ អ៊ីចឹងមិនមែន មិនមានការច្រឡំ ទាក់ទងនឹងចំនួនគូដែលរៀបការទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំនិយាយមែន១២គូ ប៉ុន្តែខ្ញុំបាននិយាយនៅក្នុងកាលខ្ញុំពាក្យបណ្ដឹង ខ្ញុំបាននិយាយ១៤គូ យក១៤គូមកដាក់អាយុខ្ញុំ១៤ វាខុស ព្រោះអាយុខ្ញុំ១៥ ទៅ១៦ឆ្នាំ អ៊ីចឹងលោកប្រធានអាចបញ្ជាក់ឡើង វិញ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមចង់បញ្ជាក់អំពីពេលវេលាដែលអ្នកស្រីរស់នៅជាមួយគ្នា នឹងប្ដីទី១របស់អ្នកស្រី។ អ្នកស្រីអាចបញ្ជាក់បានទេថា--

[១១:១៦:០៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំអានឯកសាររកឃើញថា <គាត់និយាយ>នៅពេលមួយនោះ<ថា> "នៅពេលដែលខ្ញុំរៀបការ ខ្ញុំមានអាយុ១៦ឆ្នាំ" នេះ<គឺឯកសារ 1143726 *(ស៊ីក)* ឬក៏ខ្ញុំមានឯកសារខុសទេ?>

**លោក វ៉ិចទ័រ កូប៉េ៖**

គឺE3/6034b--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ចាស។>

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាគាត់បានឆ្លើយ<នៅក្នុងឯកសារជាភាសាអង់គ្លេស ERN 01143732> ថា គាត់អាយុតែ ១៤ឆ្នាំទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប៉ុន្តែខាងក្រោមនេះបន្តិច គឺគាត់និយាយថា គាត់អាយុ១៦ឆ្នាំវិញ។ <ដូច្នេះ ដូចខ្ញុំបាននិយាយ ហើយ នៅក្នុងឯកសារ 1143726*(ស៊ីក)*> គាត់បានរៀបរាប់អំពីដំណើររឿងរបស់គាត់ថា "ខ្ញុំមាន

អាយុ១៦ឆ្នាំកាលនោះពេលរៀបការ”។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ ខ្ញុំសូមតទៀតដោយសារពេលវេលា អ៊ីចឹងខ្ញុំសូមឱ្យលោកស្រីបញ្ជាក់អំពីពេលវេលាដែលលោកស្រីបានរស់នៅជាមួយប្ដីទី១របស់អ្នកស្រីនេះ អ្នកស្រីអាចបញ្ជាក់បានទេរយៈពេលប៉ុន្មានមុនពេលដែលលោកស្រីរត់ចេញពីគាត់?

[១១:១៧:១៤]

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** អាហ្នឹងខ្ញុំបាននិយាយពីម្សិលមិញរួចហើយ លោកប្រធាន។

**ស៖** លោកស្រីអាចបញ្ជាក់បានទេថារយៈពេលប៉ុន្មាន?

**ឆ៖** ខ្ញុំបាននិយាយពីម្សិលមិញរួចហើយ។ ហើយក្នុងឃ្លីបវីដេអូខ្ញុំ ក៏ខ្ញុំនិយាយរួចហើយ អ៊ីចឹងបើសួរខ្ញុំអ៊ីចឹង ខ្ញុំមិនដឹងថាអាណាមុនអាណាក្រោយទេ ព្រោះខ្ញុំមិនសូវចេះអក្សរ ហើយណាមួយខួរក្បាលខ្ញុំមិនសូវចងចាំ មិនប្រក្រតីចាស។ ដល់អ៊ីចឹងខ្ញុំ ៗគិតអត់ឃើញនឹងឆ្លើយនឹងសំណួរលោកទេ។

**ប្រធានអង្គជំនុំ៖**

គាត់គ្រាន់តែសួរបញ្ជាក់ពីការរស់នៅលោកស្រី ចាប់ពីរៀបការជាមួយនឹងប្ដីទី១របស់លោកស្រីហ្នឹង ហើយលោកស្រីរស់នៅជាមួយគាត់ រួមរស់ជាប្ដីប្រពន្ធហ្នឹងអស់រយៈពេលប៉ុន្មានបានបែកគ្នា បានចែកផ្លូវគ្នា? ពាក្យហ្នឹងសាមញ្ញទេ ហើយវាធម្មតាជាជីវភាពរស់នៅរបស់មនុស្ស គឺព្រឹត្តិការណ៍ដែលកើតឡើងពាក់ព័ន្ធនឹងខ្លួនឯង គឺវាដូចជាមិន១ពិបាកចងចាំទេ ព្រោះអានេះព្រឹត្តិការណ៍សំខាន់សម្រាប់ក្នុងជីវិតរបស់លោកស្រី។ លោកស្រីអាចឆ្លើយបញ្ជាក់បានទេ?

**លោកស្រី ប៉ែន សុចាន់៖**

**ស៖** ការហើយមិនបានរស់នៅជាមួយគ្នាទេ ចេញធ្វើការគេទៅខាងភ្នួរ ខ្ញុំទៅខាងរែកអាចម៍ ជីអាចម៍ និងអាចម៍គោដាក់ពាង។ គាត់ធ្វើផ្សេង គាត់ដេកផ្សេងអ៊ីចឹងទៅ កាលណាក៏គាត់មកកន្លែង គឺយើងអត់បានរស់នៅទេ រយៈតែ៣ថ្ងៃហ្នឹង គឺខ្ញុំអត់បាននៅធ្វើការនៅភូមិដើមរកាហ្នឹងតទៀតទេ។ ខ្ញុំបែកគ្នា មិនដែលឃើញមុខគ្នា តែពេលដែលចាប់បង្ខំហ្នឹង ខ្ញុំឃើញគ្នារយៈ៣ថ្ងៃ។

[១១:១៩:០៩]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់ពីពេលចាប់ផ្ដើមកាលបរិច្ឆេទ បើសិនជាអ្នកស្រីអាចចាំចាប់ ផ្ដើមបែកគ្នាដំបូងដែលអ្នកស្រីប្រាប់ថាអ្នកស្រីរត់ទៅផ្ទះរបស់អ្នកស្រី បានន័យថា ទៅជួបម្ដាយរបស់អ្នកស្រី អ្នកស្រីចាំៗបានទេ?

**ឆ៖** ចាសចាំបាន។ ខ្ញុំបានរត់ទៅរកម្ដាយមែន។

**ស៖** អ្នកស្រីចាំពេលវេលាជាក់លាក់ណាមួយដែលអាចបញ្ជាក់ពីកាលបរិច្ឆេទបានទេ?

**ឆ៖** ចាសចាំបាន។

**ស៖** អ៊ីចឹងអ្នកស្រីឆ្លើយទៅ?

**ឆ៖** ខ្ញុំចាំបានរត់ទៅរកម្ដាយ ឲ្យម្ដាយជួយ ដល់ពេលហើយខ្ញុំជួបគាត់ប្រហែលជាបីម៉ោងទេ ហើយខ្ញុំបានប្រាប់គាត់ថា ខ្ញុំធ្លាក់ឈាម--

**ស៖** អាហ្នឹងខ្ញុំបានស្ដាប់ហើយ អង្គជំនុំជម្រះបានស្ដាប់ហើយ ប៉ុន្តែខ្ញុំចង់ដឹងពីពេលវេលា បានន័យថា កាលបរិច្ឆេទជាក់លាក់ណាមួយដែលអាចកំណត់កាលបរិច្ឆេទច្បាស់ថា អ្នកស្រីចេញទៅរកម្ដាយនៅពេលណា ហើយដែលអ្នកស្រីបញ្ជាក់ថាជាពេលវេលា ចាប់ផ្ដើមបែកពីប្ដីទី១ របស់លោកស្រីដំបូង អ្នកស្រីដែលព្យាយាមរត់ចេញពីប្ដីអ្នកស្រីនោះ។

[១១:២០:៤១]

**ឆ៖** ចាស យប់ទី៤ លោកប្រធាន។

**ស៖** អ៊ីចឹងមានន័យថា យប់ទី៤ អ្នកស្រីចេញទៅរកម្ដាយរបស់អ្នកស្រី ហើយអ្នកស្រីត្រឡប់មកវិញ អ្នកស្រីទៅកន្លែងផ្ទះដើមរបស់អ្នកស្រី ឬអ្នកស្រីទៅកាន់កន្លែងណាផ្សេង?

**ឆ៖** ខ្ញុំអត់បានត្រឡប់មកកងដើមវិញទេ។ ខ្ញុំទៅ គេហៅ វាលប្រឡាយរំដេងហ្នឹងចាស។ ខ្ញុំទៅរក ឈាន ដែលធ្លាប់ធ្វើការជាមួយគ្នា នៅក្នុងឃ្លាំបហ្នឹងមានហើយ។

**ស៖** បាទ សូមអរគុណ។ ចុះអ្នកស្រីស្គាល់ព្រៃធំទេ? ជាអ្វីដែរ?

**ឆ៖** ព្រៃធំហ្នឹងគឺព្រៃធំ ប្រឡាយរំដេងហ្នឹង គឺឈ្មោះតែមួយ។ ហៅ "ព្រៃធំ"ក៏បាន ព្រោះកន្លែងហ្នឹងយើងទៅលើកប្រឡាយ១៧មេសាហ្នឹង គេលើកធំកាត់ភ្នំហ្នឹងអ៊ីចឹង ខ្លះក៏ហៅព្រៃធំ ខ្លះក៏ហៅប្រឡាយរំដេង។

**ស៖** ខ្ញុំអំមិញស្ដាប់អត់ទាន់ អ្នកស្រីទៅប្រឡាយរំដេងទៅជួបមិត្តភក្ដិ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ទៅរកមិត្តភក្ដិ។

**ស៖** បាទ សូមអរគុណ។ ប៉ុន្តែនៅក្នុងឯកសារ E3/4779 ក្នុង ERN ដូចគ្នានឹង ERN ដែលខ្ញុំជម្រាបមុននឹងដែរ គឺភាសាខ្មែរ00499825, ភាសាបារាំង00900952, ភាសាអង់គ្លេស 00891280។ លោកស្រីឆ្លើយថា សូមដកស្រង់៖ "បន្តទៅព្រៃធំ ទៅនៅជាមួយពូរបស់ខ្ញុំ ឈ្មោះ ខុម។ នៅទីនោះបានមួយរយៈ។" អ៊ីចឹងវាខុសគ្នាម៉េចដែលលោកស្រីឆ្លើយថា ទៅនៅជាមួយពូឈ្មោះ ខុម ហើយនិងទៅនៅជាមួយមិត្តភក្តិ?

[១១:២៣:៣៥]

**ឆ៖** ខ្ញុំដាក់ឈ្មោះ ខុម ហ្នឹងគឺខ្ញុំដាក់នៅភូមិដើមរកាដែលបានជួយខ្ញុំ នៅប្រឡាយរំដេង ខ្ញុំដូចថាវា មិនបានរៀបរាប់ថា ពូនៅប្រឡាយរំដេង លោកប្រធាន គ្រាន់តែខ្ញុំបានរត់ទៅមិត្តភក្តិ ដែលយប់ទី៤ គ្មានអ្នកណាជួយខ្ញុំបាន។

**ស៖** តទៅទៀត លោកស្រីមានពាក្យមួយដែលខ្ញុំឃើញថ្មី ពាក្យភូមិ "រុកពែក" អ្នកស្រីស្គាល់ទីតាំងនោះទេ? រុកពែក នៅក្នុងឯកសារដដែលមិញហ្នឹង តែមួយបន្ទាត់ចុះក្រោមទេ។

**ឆ៖** "រុកពែក" ហ្នឹងខ្ញុំមិនដែលដឹង ក៏ខ្ញុំដូចជាភ្លេច វាយូរពេកហើយ លោកប្រធាន។

**ស៖** ចុះអ្នកស្រីមានមីងឈ្មោះ អាន ទេ?

**ឆ៖** ចាស មាន មីងអាន – ពូខុមហ្នឹង ខ្ញុំដាក់មាននៅភូមិដើមរកា។ រុកពែក ខ្ញុំអត់ស្គាល់ ខ្ញុំអត់មានបានដាក់ទេ។

**ស៖** ព្រោះក្នុងចម្លើយអ្នកស្រីថា អ្នកស្រីទៅភូមិរុកពែកហ្នឹង ហើយបានជួបជាមួយម្ដាយមីងឈ្មោះ អាន ហើយស្នាក់នៅជាមួយគាត់បានមួយយប់។ អ្នកស្រីចាំថា អ្នកស្រីបានផ្ដល់សក្ខីកម្មបែបហ្នឹងទេ បានសរសេរក្នុងពាក្យរបស់អ្នកស្រីបែបហ្នឹងទេ?

**ឆ៖** ខ្ញុំចាំបានឈ្មោះមីង អាន ប៉ុន្តែខ្ញុំអត់ដែលបានទៅនៅរុកពែក ដែលបានដាក់ពាក្យបណ្ដឹងថារុកពែកហ្នឹងយ៉ាងណា តែមិនដឹងកត់នេះ ខ្ញុំយ៉ាងម៉េច ខ្ញុំអត់ដឹង លោកប្រធាន។

[១១:២៥:៤០]

**លោក គង់ សំអុន៖**

បាទ លោកប្រធាន សូមអស់សំណួរ។ សូមជូនសហភាគាបន្ត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីរបស់លោក ខៀវ

សំផន។ ខ្ញុំចោទសំណួរមួយចំនួនបន្ថែម។ <>លោកស្រីបាន<បញ្ជាក់ថា លោកស្រីបាន>បំពេញ<> ទម្រង់បែបបទជាច្រើន<ដង ដូច្នេះ ខ្ញុំចង់ពិភាក្សាជាមួយលោកស្រី អំពីពេលវេលាខុសៗគ្នាដែល> លោកស្រីបានបំពេញសំណុំបែបបទ ដើម្បីចូលរួមក្នុងដំណើរកិច្ចដំណើរការនីតិវិធីនេះ។ ឯកសារទី១ ចុះថ្ងៃទី២៦ សីហា ឆ្នាំ២០០៩ ឯកសារ E3/4779 ។ ឯកសារទី២ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១០ គឺ ឯកសារ E3/6034a។ ឯកសារ<មួយទៀត>ចុះនៅថ្ងៃទី២៩ មិថុនា ឆ្នាំ២០១៣ ឯកសារ E3/6034b ។ យើងមានឯកសារមួយទៀត ដែលលោកមេធាវី កូប៉េ បាននិយាយអំពីអម្បាញ់មិញនេះ ដែលជាកម្រងសក្ខីកម្មដែលមានសក្ខីកម្មរបស់លោកស្រីផងដែរ គឺឯកសារ<E305/13.23.5> ចុះ<>ខែ១០ ឆ្នាំ២០១២។ អ៊ីចឹងខ្ញុំសួរលោកស្រីថា តើលោកស្រីបានបំពេញទម្រង់បែបបទនៅឆ្នាំ២០០៩ ដែលមានព័ត៌មានបន្ថែមផងដែរនៅឆ្នាំ២០១០ ហើយនិង២០១៣ លោកស្រីមានបានបំពេញឯកសារទាំងបីហ្នឹងទេ? លោកស្រីចាំទេ?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** តើឯកសារនោះ ដឹងឯកសារអ្វី លោកស្រី?

[១១:២៧:៤៧]

**ស៖** ឯកសារនៅជាឆ្នាំ២០០៩ គឺជាទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ។ ឯកសារ<ទី២> ឆ្នាំ២០១០ គឺជាទម្រង់បែបបទព័ត៌មានបន្ថែម ហើយឯកសារទី៣ នៅថ្ងៃទី២៩ មិថុនា ឆ្នាំ២០១៣ គឺជាទម្រង់បែបបទព័ត៌មានបន្ថែមផងដែរ អ្នកស្រី។ តើលោកស្រីនឹកឃើញទេ?

**ឆ៖** ខ្ញុំបានដាក់ពាក្យបណ្តឹង គឺជាច្រើនច្បាប់ ប៉ុន្តែដឹងច្បាប់មួយណាយ៉ាងម៉េច ច្បាប់មួយណាយ៉ាងម៉េច គឺខ្ញុំបានដាក់មកមែន ប៉ុន្តែវាដូចអូសអន្លាយហ្នឹង វាវែងយូរឆ្នាំហើយ ខ្ញុំចាំមិនបាន។ អ៊ីចឹងដែលពាក្យខ្ញុំនៅក្នុងនោះយ៉ាងម៉េច ក៏ខ្ញុំអត់ដឹងដែរ។

**ស៖** ខ្ញុំយល់ថា លោកស្រីមិនអាចចាំច្បាស់លាស់អំពីអ្វីដែលលោកស្រីបាននិយាយទេ តើលោកស្រីនៅចាំអំពីហេតុការណ៍នៃជីវិតរបស់លោកស្រីដែរឬទេ? ហើយលោកស្រីនៅចាំទេ អំពីមូលហេតុដែលនាំឲ្យលោកស្រីមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅទីនេះនេះ?

**ឆ៖** ចាស ខ្ញុំចាំបានដែលខ្ញុំដាក់ពាក្យបណ្តឹង គឺខ្ញុំចាំបាន។ ហើយដែលមកធ្វើសក្ខីកម្មនេះ ក៏តាមរយៈតែមេធាវីកោះអញ្ជើញមកដែរ។

**ស៖** នេះជាចំណុចមួយដែលខ្ញុំចង់ចោទសំណួរទៅកាន់លោកស្រី។ <ពេលដែលលោកស្រី

ដាក់>ពាក្យបណ្ដឹងទី១ <ដូច>លោកស្រី<បាននិយាយហើយ នៅចំពោះមុខអង្គជំនុំជម្រះនេះ តើ> កាលនោះ មានមេធាវី<>របស់លោកស្រី<ទេ> ឬក៏កាលនោះលោកស្រីបំពេញទម្រង់បែបបទហ្នឹង ដោយខ្លួនឯង មិនមានជំនួយពីមេធាវីទេ<នៅឆ្នាំ២០០៩នោះ>?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ជាភាសាអង់គ្លេស គឺថាគឺបំពេញដោយខ្លួនឯង ហើយសាក្សីឆ្លើយថា គាត់មិនអាចចេះសរសេរ អាន ចេះសរសេរបានទេ។

[១១:៣០:១៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំចោទសំណួរម្ដងទៀត។ លោកស្រីបាននិយាយថា លោកស្រីបានប្ដឹងមកតុលាការយើង នេះ តាមរយៈមេធាវីរបស់លោកស្រី។ អ៊ីចឹងសំណួរខ្ញុំចង់សួរថា នៅពេលដែលលោកស្រីបំពេញពាក្យ បណ្ដឹងទី១ហ្នឹង តើលោកស្រីបានបំពេញពាក្យបណ្ដឹងហ្នឹង ដោយមានជំនួយពីមេធាវីរបស់លោកស្រីដែរ ឬទេ ឬក៏ដោយមេធាវីលោកស្រីហ្នឹង ជួយលោកស្រីដែរឬទេ ឬក៏លោកស្រីបំពេញដោយខ្លួនឯង?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ខ្ញុំមានមេធាវីមែន ប៉ុន្តែសរសេរឯកសារដែលទឹកចិត្តពីខ្ញុំ គឺកូនប្រុសពៅរបស់ខ្ញុំ អ្នក សរសេរឲ្យចាស។ គាត់អ្នកបំពេញឲ្យ មាននៅក្នុងឃ្លីបហ្នឹងស្រាប់។ ខ្ញុំក៏ចាប់ផ្ដើមនិយាយប្រាប់កូនពី ប្រវត្តិ ជីវប្រវត្តិរបស់ខ្ញុំ។

**ស៖** តើក្នុងដំណើរការហ្នឹង តើគាត់មានបានអានទម្រង់បែបបទដែលកូនលោកស្រីជួយបំពេញ លោកស្រីហ្នឹងដែរឬទេ? គាត់មានអានឡើងវិញឲ្យលោកស្រីស្ដាប់ទេ?

**ឆ៖** សរសេរហើយខ្លះ ក៏កូនបានអានឲ្យស្ដាប់ ខ្លះក៏អត់បានអានស្ដាប់ទេ លោកប្រធាន។ គ្រាន់តែខ្ញុំបានដាក់ពាក្យបណ្ដឹងផ្ញើមកតាមកូន មកសាលាត្រពាំងជង ផ្ញើតាមឡានក្រុងមកឲ្យមេធាវី។

**ស៖** លោកស្រីបាននិយាយថា គាត់បានជួយអានផ្នែកខ្លះៗ។ អ៊ីចឹងតើគាត់មានអានផ្នែកដែល ពាក់ព័ន្ធទៅនឹងរាត្រីទី១ ក្រោយពីពេលដែលលោកស្រីរៀបការហ្នឹងដែរឬទេ ហើយនិងរាត្រីបន្តបន្ទាប់ មកទៀតហ្នឹង? អ៊ីចឹងគាត់មានអានចំណុចហ្នឹងឲ្យលោកស្រីស្ដាប់ឡើងវិញទេ?

[១១:៣២:២២]

**ឆ៖** កាលនុំងបានអានដែរ ប៉ុន្តែដល់វាយូរពេកអ៊ីចឹងទៅ ខ្ញុំភ្លេចអស់ដែរ ក៏មិនដឹងថាអានត្រង់

ណា ជាទំព័រមួយណា ដែលក្រដាសមួយណា ដែលលោកស្រីគិតមើល កើតក្តី សាលាក្តីខ្មែរក្រហមមិនមែនតិចឆ្នាំទេ ហើយខ្ញុំទៅថៃនោះ បរិច្ចាគស្រុកគេ ខួរក្បាល ខ្ញុំលែងចាំនឹងរឿងខ្ញុំនិយាយអស់ហើយ។ វា២ឆ្នាំនៅប្រទេសគេ។ បើខ្ញុំមិនទៅគ្មានអីហូប ដល់ពេលដែលខ្ញុំចេញមកកាលភ្នំនេះ បានមេធាវីដឹងលេខ គាត់ក៏មកអញ្ជើញ មកផ្តល់សក្ខីកម្មនេះ ពេលភ្នំនេះបានខ្ញុំដឹងថា ខ្ញុំចូលសក្ខីកម្ម។ ខ្ញុំមិនបានត្រៀមទុកមុនទេ ព្រោះខ្ញុំទៅរកស៊ីស្រុកគេ ដើម្បីចិញ្ចឹមជីវិត។ ខ្ញុំអត់បានផ្ទៀងផ្ទាត់នឹងពាក្យបណ្តឹង គឺខ្ញុំដាក់មកហើយ ខ្ញុំអាងនៅលើតុលាការ និងមេធាវីហើយ។ ខ្ញុំចាំពាក្យខ្ញុំមិនអស់ទេ។

**ស៖** ខ្ញុំចោទសំណួរនេះទៅលោកស្រីហ្នឹង ព្រោះថា នៅក្នុងឯកសារទី១ ចុះឆ្នាំ២០០៩ហ្នឹង គឺឯកសារ E3/4779 គឺមានសរសេរដូចតទៅនេះ ទាក់ទងទៅនឹងរាត្រីទី១ ហ្នឹង ខ្ញុំសូមដកស្រង់ ERNជាភាសាបារាំងគឺ <009009501> សូមទោស<00900951>, ERN ជាភាសាអង់គ្លេសគឺ 00891281 -- 80 សូមទោស, ជាភាសាខ្មែរគឺ 00499825។ ទំព័រ -- "រាត្រីទី១ ខ្ញុំមិនព្រមរួមដំណេកជាមួយគាត់ទេ។ ខ្ញុំសូមអង្វរគាត់ កុំឲ្យគាត់ធ្វើបាបខ្ញុំ យប់ហ្នឹងគាត់អត់បានបង្ខំខ្ញុំទេ។ ក៏ប៉ុន្តែមានឈ្លបមកយាមមកលបមើលយើង ហើយចង់ដឹងថា មានអ្នកណាជំទាស់នឹងការរៀបការដែលរៀបចំឡើយដោយអង្គការនេះដែរឬក៏អត់។ ហើយបន្ទាប់មករាត្រីទី២ គេបានកោះប្តីខ្ញុំទៅប្រជុំ បន្ទាប់មកវិញ ពេលគាត់ត្រឡប់មកវិញ គាត់មកបង្ខំខ្ញុំ ហើយទះកំផ្លៀងខ្ញុំ ពេលដែលខ្ញុំប្រកែកជាមួយនឹងគាត់ ហើយបន្ទាប់មកគាត់បង្ខំខ្ញុំ ហើយខ្ញុំបម្រះរួច ហើយខ្ញុំរត់ទៅឲ្យពូខ្ញុំជួយ ពូខ្ញុំរស់នៅក្បែរនុំងដែរ។" សូមបញ្ចប់ការដកស្រង់។

[១១:៣៤:៤៥]

ទាក់ទងទៅនឹងយប់ទី២ ដំបូងនោះនៅក្នុងឯកសារឆ្នាំ២០០៩ហ្នឹង លោកស្រីបាននិយាយថា យប់ទី១ គាត់មិនធ្វើអីលោកស្រីទេ ព្រោះលោកស្រីអង្វរគាត់ ហើយទី២ យប់ទី២ ហ្នឹងគឺពូរបស់លោកស្រី ជួយលោកស្រី។ នៅចំពោះមុខតុលាការនេះ លោកស្រីបានជម្រាបជូនចៅក្រមថា យប់ទី១ហ្នឹងគាត់បានចងដៃលោកស្រី ហើយបាន<ធ្វើបាបលោកស្រី។ គាត់បានទាំង>រំលោកស្រី<ផង> ក៏ប៉ុន្តែមិនបានរំលោភលោកស្រីទេនៅយប់នុំង <នេះបើតាមអ្វីដែលលោកស្រីបាននិយាយ>។ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើហេតុការណ៍ណាដែលជាហេតុការណ៍ត្រឹមត្រូវ?

**ឆ៖** ចាស ខ្ញុំបានដាក់មែននៅក្នុងហ្នឹង គឺខ្ញុំអត់បានដាក់យប់ទី២ ចងខ្ញុំទេ យប់ទី៣ ចាស។

**ស៖** អ៊ីចឹងគឺថា យប់ទី១ហ្នឹងគាត់មិនបាន ប្តីរបស់លោកស្រីមិនបានចងលោកស្រីទេ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ព្រោះថ្ងៃនុំងភ្លៀងធំ ហើយក៏កៀកម៉ោងធ្វើការដែរ។

**ស៖** អ៊ីចឹងនៅត្រង់ចំណុចហ្នឹងគឺថា ខ្ញុំមានសំណួរមួយទាក់ទងទៅនឹងពេលចេញទៅធ្វើការ ព្រោះថានៅពេលដែលលោកស្រីឆ្លើយទៅនឹងលោកមេធាវី លោកស្រីបានឆ្លើយថា ៣ថ្ងៃហ្នឹងគេអត់ឱ្យទៅធ្វើការទេ។ ហើយម្សិលមិញនៅពេលដែលលោកស្រីនិយាយពីយប់ទី១ហ្នឹង លោកស្រីថានៅម៉ោងពីរព្រឹកហ្នឹងគឺឮគេផ្លុំកញ្ចែ ហើយលោកស្រីត្រូវចូលជួរនឹងគេដើម្បីទៅធ្វើការ។ អ៊ីចឹងលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេថារយៈពេល៣ថ្ងៃក្រោយពីពេលរៀបការហ្នឹង លោកស្រីត្រូវទៅធ្វើការឬក៏យ៉ាងម៉េច?

**ឆ៖** ឱ្យខ្ញុំឆ្លើយមែនពីម្សិលមិញ គឺអត់មានឈប់ធ្វើការទេចាស។

[១១:៣៧:០១]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

អញ្ជើញលោកមេធាវី!

**លោក ពេជ អង្គ៖**

អ្វីដែលខ្ញុំស្តាប់ជាភាសាខ្មែរដែលលោកស្រីមេធាវីបានលើកអម្បាញ់មិញគឺនិយាយថា លោកស្រីបានឆ្លើយនឹងខ្ញុំ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយនឹងខ្ញុំថា ៣ថ្ងៃហ្នឹងមិនបានទៅធ្វើការទេ។ ខ្ញុំប្រហែល -- ខ្ញុំមិនបានចាំថាគាត់បានឆ្លើយយ៉ាងដូច្នេះទេ។ ហើយប្រសិនបើថា លោកស្រី អង់តា ហ្គីសសេ អាចលើកជា*ត្រេនស្គ្រីប*ដែលបានឆ្លើយពីម្សិលមិញបាន វាអាចជួយឱ្យផ្ទៀងផ្ទាត់អំពីបញ្ហានេះបាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ម្សិលមិញនៅម៉ោង<០២:៣៣:៥៤> <នាទី លោកស្រីបាននិយាយថា> "ខ្ញុំបានអង្វរគាត់ទៅ គាត់ក៏ដេកលក់ទៅ។ ម៉ោងពីរភ្លឺខ្ញុំឮគេផ្លុំកញ្ចែ ខ្ញុំក៏ចូលជួរ<ជាមួយគេ>"។ អ៊ីចឹងលោកស្រីអាចបញ្ជាក់បានដែរឬទេ នៅពេលដែលលោកស្រីនិយាយថា លោកស្រីដើរទៅតម្រង់ជួរហ្នឹង ខ្ញុំសួរលោកស្រីថា តម្រង់ជួរហ្នឹង<នៅកន្លែងណា ហើយ>ដើម្បីទៅធ្វើអីដែរ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមកាត់រំខាន អ្វីដែលមេធាវីចង់បានគឺឯកសារយោង ពីព្រោះអាចលោក កូប៉េ ឬក៏អ្នកណាម្នាក់និយាយថា គាត់<មិន>បានទៅធ្វើការក្នុងរយៈពេល៣ថ្ងៃនេះ<ទេ>។

[១១:៣៨:៣៥]

**កញ្ញា អង់តា ហ្គីសសេ៖**

<សេចក្ដីយោងនោះគឺអ្វីដែលគាត់បាននិយាយនៅថ្ងៃនេះ ដូច្នេះ>ខ្ញុំអត់មានយោង អត់មានប្រតិចារឹកព្រាងនៅថ្ងៃនេះទេ។ តែខ្ញុំគ្រាន់តែចង់ប្រាប់ថានៅថ្ងៃនេះ ខ្ញុំឮគាត់និយាយថ្ងៃនេះថា គាត់មិនត្រូវទៅធ្វើការអីទេក្នុងរយៈពេល៣ថ្ងៃហ្នឹងនោះ។ <ដូច្នេះ ខ្ញុំយោងទៅប្រតិចារឹកកាលពីម្សិលមិញនៅម៉ោង ០២:៣៣:៥៤ រសៀល> គាត់និយាយថា ម៉ោងពីរភ្លឺហ្នឹងគាត់ឮស្គររគេផ្គុំកញ្ចែ ហើយអ៊ីចឹងគាត់ចូលទៅតម្រង់ជួរ <ព្រោះវាមានន័យថា គាត់ត្រូវចាប់ផ្ដើម>ធ្វើការ។ អ៊ីចឹងខ្ញុំសួរបញ្ជាក់គាត់ ថាតើទៅតម្រង់ជួរហ្នឹងដើម្បីទៅណាដែរ? ទៅធ្វើការ ឬក៏ទៅធ្វើអី?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន តាំងពីម្សិលមិញក្ដី ឬក៏ថ្ងៃនេះក្ដី ខ្ញុំមិនបានឮដើមបណ្ដឹងរដ្ឋប្បវេណីនិយាយថា គាត់មិនត្រូវទៅធ្វើការ៣ថ្ងៃហ្នឹងទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសួរទៀតលោកស្រីមេធាវី កុំរំខាន មិនដូចជា ដូចមិនរំខាន មិនជំទាស់ មិនអីទេ ជាការស្ដាប់សក្ខីកម្មទាំងអស់គ្នា ហើយមិនចាំទាំងអស់គ្នា។ ឥឡូវគាត់សួរបញ្ជាក់ អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

[១១:៣៩:៥៩]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងនៅក្នុងកំណត់ត្រារបស់ខ្ញុំនោះ ថ្ងៃនេះ ខ្ញុំឮលោកស្រីនិយាយថា ៣ថ្ងៃហ្នឹង លោកស្រីមិនត្រូវធ្វើការអីទេ។ អ៊ីចឹងសំណួរខ្ញុំសួរ ៗលោកស្រីថាតើលោកស្រីមានធ្វើការអត់ក្នុងរយៈពេល៣ថ្ងៃហ្នឹង?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ខ្ញុំអាចឆ្លើយជូនបាន ខ្ញុំអត់បានឆ្លើយថា ៣ថ្ងៃអត់ទៅធ្វើការទេ ខ្ញុំបានឆ្លើយថាម៉ោងពីរ គេផ្លុំកញ្ចែ ខ្ញុំឈរតម្រង់ជួរ ចេញទៅលើកភ្លឺ និងរែកដីអាចម៍បន្ដចាស។ ពាក្យដែលៗថា អត់បានធ្វើការ គឺខ្ញុំអត់បានឮ ទើបឮ ៗនឹងពេលនេះ។ ពេលដែលខ្ញុំនិយាយតាំងពីម្សិលមកដល់ថ្ងៃនេះ ខ្ញុំអត់បានដាក់ថាអត់បានទៅធ្វើការទេ ខ្ញុំបានឮម៉ោងពីរ ឮស្គររកញ្ចែគេផ្លុំ ខ្ញុំទៅឈរតម្រង់ជួរ ខ្ញុំចេញទៅធ្វើការ។ សូម

សាឡើងម្តងទៀត មើលឲ្យច្បាស់ចាស។

**ស៖** លោកស្រីបានឆ្លើយថា គេអប់រំលោកស្រី អប់រំកែប្រែលោកស្រី ដោយប្រធានកងរបស់លោកស្រីបន្ទាប់ពីយប់ដំបូងបានកន្លងផុតទៅ។ តើត្រឹមត្រូវដែរឬទេ គេយកលោកស្រីទៅអប់រំកែប្រែ?

**ឆ៖** ចាស មាន ថ្ងៃយប់នុំង។

**ស៖** នៅក្នុងចម្លើយ<ទី១>របស់លោកស្រីនៅឆ្នាំ២០០៩ ដែលខ្ញុំបានលើកអម្បាញ់មិញហ្នឹង គឺឯកសារ E3/4779 <លោកស្រីមិនបាននិយាយអំពីវគ្គអប់រំណាមួយទេ។ ប៉ុន្តែ>លោកស្រីបាននិយាយពីកិច្ចប្រជុំ<> ដែលគេកោះហៅប្តីលោកស្រីទៅចូលរួម។ តើលោកស្រីមានចាំដែរឬទេថា នៅពេលណាមួយនោះ នៅក្នុងចម្លើយពីមុនរបស់លោកស្រីមកហ្នឹង គឺថាតើ<លោកស្រីមាននិយាយថា>គេ<>យកលោកស្រីទៅកសាងដែរឬទេ?

[១១:៤២:១៤]

**ឆ៖** ពេលនោះខ្ញុំបាននិយាយ មានតែរឿងគេកសាងខ្ញុំ បើរឿងគេកោះប្តី ហៅប្តី ខ្ញុំបានឆ្លើយបញ្ជាក់រួចហើយ ថាខ្ញុំនៅផ្សេង គេនៅផ្សេង ចម្ងាយជា៣គីឡូពីគ្នា។ ដឹងគេហៅគាត់ ឬកសាងគាត់ ខ្ញុំមិនដឹងទេ តែរូបខ្ញុំ គេកសាងគ្រប់២ថ្ងៃហើយ។

**ស៖** នៅក្នុងឯកសារ E3/4779 ឬក៏ឯកសារ E3/6034a និងឯកសារ <E3/6034> <ដែលជាព័ត៌មានបន្ថែមរបស់>លោកស្រី ក្នុងឯកសារទាំងអស់នេះហ្នឹង លោកស្រីមិនបាននិយាយអំពីការកសាងលោកស្រីនោះទេ។ តើលោកស្រីមានបាន<និយាយពីរឿង>នេះទេ <ហើយប្រហែលជាអ្នកសរសេររបាយការណ៍នេះ> គាត់ភ្លេចបញ្ជាក់ពីចំណុចហ្នឹង ចំណុចដែលគេយកលោកស្រីទៅកសាងហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំបានឆ្លើយតាំងពីម្សិលមិញរហូតដល់ថ្ងៃនេះ ថាខ្ញុំមិនដឹងថាគេយ៉ាងម៉េច ហើយគេកសាងប្រុស ឬស្រីហ្នឹង គឺខ្ញុំឆ្លើយតែដដែលៗហ្នឹង ថាខ្ញុំអត់ដឹងទេ។

**ស៖** ពេលវេលាខ្ញុំនោះវាមានកំណត់ អ៊ីចឹងខ្ញុំត្រូវបន្តទៅមុខទៀត។ លោកស្រីមានចាំថាបានចូលរួមនៅក្នុងការសរសេរសៀវភៅមួយ <ដែលបោះពុម្ពនៅខែតុលា ឆ្នាំ២០១២> គឺថា ចំណងជើង <"អតីត និងបច្ចុប្បន្នភាពរបស់ជនរងគ្រោះពីការបង្ខំឲ្យរៀបការ" តើ>លោកស្រី<ចាំថាមាន>បានសម្ភាសជាមួយ<អ្នកណា>ម្នាក់<ទេ> ហើយលោក<ស្រី>បានរៀបរាប់រឿងរ៉ាវពីជីវិតរបស់លោកស្រី<ហើយគេបោះពុម្ពផ្សាយ>នៅក្នុងស្នាដៃមួយ សៀវភៅមួយដែលសរសេររួមគ្នា។ លោកស្រីមានចាំ

ទេ?

**ឆ៖** តែសៀវភៅហ្នឹងមក សូមសួរ សូមទោសមេធាវី តើសៀវភៅហ្នឹងមកពីខាងណាវិញ?

[១១:៤៤:៤៦]

**ស៖** យើងបានទទួលឯកសារហ្នឹងនៅក្នុងសំណុំរឿងរបស់យើង គឺមានឈ្មោះលោកស្រីនេះ <ប៉ែន សុចាន់> មានអាយុ៥១ឆ្នាំ ជាភាសាអង់គ្លេសគឺ 00992330ហ្នឹង គឺឯកសារ E305/13.23.5 ដែលគេនិយាយពីលោកស្រីដែលមានអាយុ៥១ឆ្នាំ នៅភូមិបឹងឈូក <ឃុំខ្នារទទឹង> នៅស្រុកបាកាន ខេត្តពោធិ៍សាត់ <>នាងគឺជាស្ត្រីមេម៉ាយ<ក្រីក្រ> មានកូនប្រាំមួយនាក់ ស្រី<ប្រាំនាក់> ប្រុស<ម្នាក់ជាកូនពៅ>។ ខ្ញុំសូមអភ័យទោសដែលអត់បានប្រាប់អ្នកបកប្រែថា ខ្ញុំដូរភាសាអម្បាញ់មិញ។ គឺឯក-សារនេះដាក់ចូលទៅក្នុងសំណុំរឿងហើយ។ <ខ្ញុំមិនដឹងថាតើវាមាននៅក្នុងបញ្ជីរបស់សហមេធាវីនាំមុខដែរឬក៏អត់ទេ។ ប៉ុន្តែក្នុងករណីណាក៏ដោយ វាជាសៀវភៅមួយដែលបានបោះពុម្ពនៅខែតុលា ឆ្នាំ២០១២។ ដូច្នេះ>តើលោកស្រីមានបានចាំថា ចូលរួមក្នុងការធ្វើសៀវភៅហ្នឹងដែរឬទេ <ឬក៏>លោកស្រីបានរៀបរាប់ពីជីវិតរបស់លោកស្រីពាក់ព័ន្ធនឹងការរៀបការដោយបង្ខំហ្នឹង ទៅប្រាប់គេដើម្បីចងក្រងចេញជាសៀវភៅ<ដែលនិយាយអំពីការរៀបការដោយបង្ខំ>ហ្នឹងមក លោកស្រីមានចាំទេ?

**ឆ៖** ខ្ញុំចាំបាន ប៉ុន្តែខុសត្រង់ពាក្យកូនប្រុសប្រាំមួយនាក់ ខ្ញុំអត់មានទេ។ មានៗកូនប្រាំមួយនាក់ ស្រីប្រាំ ប្រុសមួយ ខ្ញុំបានដាក់ ឃើញខុសកូនបាត់ហើយ។ កូនខ្ញុំស្រីប្រាំ ប្រុសមួយ ពៅចាស។

**ស៖** ប្រហែលជាមានបញ្ហាក្នុងការបកប្រែមិនដឹង ខ្ញុំប្រហែលជាខ្ញុំនិយាយខុសក៏មិនដឹង ប៉ុន្តែ <ការសរសេរនេះ>ថាកូនស្រីប្រាំ កូនប្រុសម្នាក់ ក៏ប៉ុន្តែនៅក្នុងឯកសារហ្នឹងគេនិយាយដូចតទៅនេះ ខ្ញុំសូមអានជាភាសាអង់គ្លេស។ ដំបូងនោះត្រូវមានសរសេរបញ្ជាក់ថា នៅពេលដែលគេរៀបការលោកស្រីហ្នឹង គឺលោកស្រីក្មេងជាងគេ។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា តើនៅពេលដែលគេរៀបការលោកស្រីហ្នឹង គឺលោកស្រីក្មេងជាងគេទាំងអស់ ឬក៏យ៉ាងម៉េច?

[១១:៤៧:១០]

**ឆ៖** ចាស លោកស្រី កាលហ្នឹងខ្ញុំក្មេងជាងគេ។

**ស៖** លោកស្រីដឹងថានារីៗផ្សេងទៀតហ្នឹងដែលរៀបការជាមួយលោកស្រីដែរ ថ្ងៃនោះហ្នឹងគាត់មានអាយុប៉ុន្មានដែរ?

**ឆ៖** ចាស លោកស្រី ខ្ញុំអត់បានដឹងថាអាយុប៉ុនណាប៉ុនណី ខ្ញុំអត់ចេះគិតអត់ចេះរាប់ទេសម័យ

នោះ គ្មានថ្ងៃខែឲ្យយើងមើលទេចាស ខ្ញុំអត់ដឹងដែរ។

**ស៖** ខ្ញុំប្រហែលអស់ពេលឥឡូវហើយ ឥឡូវខ្ញុំសូមចូលទៅនិយាយអំពីឯកសារមួយទៀត។ លោកស្រីបាននិយាយនៅក្នុងចម្លើយរបស់លោកស្រីថ្ងៃទី២៩ មិថុនា <២០១០> គឺឯកសារ E3/6034a គេបង្ខំឲ្យលោកស្រីរៀបការនៅឆ្នាំ៧៧ <ហើយនៅពេលនោះលោកស្រីមានអាយុទើបតែ១៥ឆ្នាំ។ ដូច្នេះ តើនេះជាកាលបរិច្ឆេទដែលលោកស្រីបានប្រាប់គេ ឬក៏ជាការច្រឡំរបស់មេធាវីលោកស្រី ឬក៏ជាការច្រឡំរបស់អ្នកដែលជួយសរសេរចម្លើយលោកស្រីនោះ>?

**ឆ៖** ចាសលោកស្រី កាលសម័យហ្នឹងខ្ញុំអត់បានដឹងថា ឆ្នាំចិតប៉ុន្មាន ខែប៉ុន្មានទេ ខ្ញុំអត់ដឹងទេ។ ខ្ញុំនៅចាំបានតែខ្ញុំនៅរៀបការមុនវៀតណាមចូលប្រហែលជា៥ខែ ទៅ៦ខែប៉ុណ្ណោះ ព្រោះយើងអត់ដឹងគិតឆ្នាំខែទេ ថ្ងៃនោះគ្មានអ្នកចេះដឹងថា នៅឈរគិតខែប្រាប់យើងទេលោកស្រី អត់ចាំ ខ្ញុំភ្លេចដែរ។

**ស៖** ខ្ញុំសូមការបំភ្លឺពីលោកស្រីត្រង់ចំណុចមួយ។ <>លោកស្រីបានកែប្រែចម្លើយរបស់លោកស្រីដែលលោកស្រីបានឆ្លើយកាលពីម្សិលមិញ គឺថាលោកស្រីបាននិយាយ<នៅថ្ងៃនេះ>ថា ទាល់តែយប់ទី៣ ហើយបានប្ដីរបស់លោកស្រីចងលោកស្រី។ អ៊ីចឹងសំណួររបស់ខ្ញុំនោះ ខ្ញុំចង់សួរលោកស្រីថា តើនៅក្នុងបន្ទប់ហ្នឹង លោកស្រីមានតែលោកស្រីហើយនិងប្ដីលោកស្រីទេ ឬក៏មានអ្នកផ្សេងទៀតដែរ?

**ឆ៖** ចាស ថ្ងៃនុំងមានឈ្លបប្រាំនាក់ ខ្ញុំដាក់ថាមានឈ្លបប្រាំនាក់ពីម្សិលមិញ បានឈរមើលខ្ញុំ ហើយគេស្រែកថា "ហ្នឹងហើយធ្វើកូនជូនអង្គការ" ខ្ញុំនិយាយអ៊ីចឹងមែនម្សិលមិញចាស។

[១១:៤៩:៥០]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ ខ្ញុំមិនបានស្ដាប់ឮពីម្សិលមិញថា លោកស្រីថា ខ្លួនគាត់បានត្រូវបានចងពីថ្ងៃផ្សេង ហើយកែប្រែមក ត្រូវបានចងនៅថ្ងៃទី៣ទេ បើសិនថា លោកស្រីមេធាវីអាចផ្ដល់ជា*ត្រេនស្គ្រីប*បាន ក៏ជាការល្អ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិននិយាយម្សិលមិញទេ។ <ខ្ញុំនិយាយ>ថា អម្បាញ់មិញនេះ នៅពេលដែលគាត់ឆ្លើយនឹងសំណួរខ្ញុំ ខ្ញុំឲ្យគាត់មើលធៀបទៅនឹងចម្លើយពីមុនរបស់គាត់នោះ។ <ហើយថ្ងៃនេះគាត់បានកែខ្លួនគាត់វិញ។> គាត់ឆ្លើយថា មិនមែន<យប់>ថ្ងៃទី១ទេ ដែលប្ដីគាត់ចងគាត់នោះ គឺ<យប់>ថ្ងៃទី៣ ដែលគេចងគាត់។ គាត់មិនមែននិយាយពីម្សិលមិញទេ និយាយអម្បាញ់មិញហ្នឹងតែម្ដង និយាយថាថ្ងៃទី៣។ ពេល

វេលាខ្ញុំមានខ្លី អ៊ីចឹងខ្ញុំសូមបញ្ចប់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** បើខ្ញុំយល់ចម្លើយលោកស្រីមិនខុសទេ គឺថានៅថ្ងៃទី៣ ហ្នឹងនៅពេលដែលប្ដីលោកស្រីចង លោកស្រីហ្នឹង ឈ្លបហ្នឹងនៅក្នុងបន្ទប់ហ្នឹងជាមួយលោកស្រីដែរ ជាមួយប្ដីលោកស្រី និងលោកស្រីដែរ អ៊ីចឹងមែនទេ?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ចាស គេឈរនៅខាងមុខ។

[១១:៥១:១៥]

**ប្រធានអង្គជំនុំ៖**

ចាំស្ដាប់សំណួរឲ្យបាន ពាក្យថា "នៅក្នុងបន្ទប់" នៅក្នុងបន្ទប់ជាមួយគ្នា។ យើងកំពុងតែដេក អ្នកឯងកំពុងដេក ប្ដីដេកជាមួយអ្នកឯងហ្នឹង គឺឈ្លបវានៅក្នុងបន្ទប់ហ្នឹង។ បន្ទប់ទំហំប៉ុនណាទៅ បានឈ្លបនៅក្នុងបន្ទប់ជាមួយ ឬក៏គេនៅខាងក្រៅទេ? គ្រាន់គេមើលមកក្នុងបន្ទប់ដែលលោកស្រី និងប្ដីលោកស្រីដេក ផ្ទំដំណេកនោះ? ដេករួមភេទជាមួយគ្នានោះ?

**លោកស្រី ប៉ែន សុចាន់៖**

**ឆ៖** ខ្ញុំបានបញ្ជាក់ហើយលោកប្រធាន ខ្ញុំថាឈ្លបនៅខាងមុខ ពីម្សិលក៏ខ្ញុំបាននិយាយដែរ អត់បាននៅក្នុងបន្ទប់ជាមួយខ្ញុំទេ ព្រោះគ្រែហ្នឹងវាតូច។ ខ្ញុំបានបញ្ជាក់ហើយ ទើបតែឮគាត់សួរខ្ញុំ។ អ៊ីចឹងបានខ្ញុំបកស្រាយថា នៅខាងមុខ ខាងមុខខ្ទមខ្ញុំ។ ខ្ញុំអត់បានថា នៅក្នុងបន្ទប់ទេ ទើបតែឮសួរអំមិញ ចាសលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** តាមរយៈការបកប្រែ ខ្ញុំយល់ខុសពីហ្នឹង។ អ៊ីចឹងខ្ញុំសួរលោកស្រីឲ្យច្បាស់តែម្ដង ថាបើធៀបនឹងខ្ទម និងលោកស្រីហ្នឹង គាត់នៅ -- លោកស្រីអំមិញ លោកស្រីនិយាយថា នៅពីមុខ អ៊ីចឹងចង់និយាយថា នៅមុខកន្លែងណា មុខហ្នឹង មុខអីគេ?

[១១:៥២:៣៩]

**ឆ៖** ចាស មុខខ្ទម មុខផ្លូវចូលខ្ទមចាស។ ផ្លូវចូលផ្ទះ ក្រែងគាត់អត់យល់ភាសាខ្មែរ ផ្លូវចូលក្នុងផ្ទះហ្នឹងគឺគេឈរខាងមុខហ្នឹង។ នេះផ្លូវទ្វារអ៊ីចឹងទៅ គេឈរខាងមុខ ខ្ញុំនៅខាងក្នុងខាងនេះ គេឈរខាង

នេះ តែជញ្ជាំងមិនបានជិតទេ ស្បូវ ហើយរនាបនេះដូចឈើបង្កង់នេះអ៊ីចឹងឯង។ ហ្នឹងខ្ញុំបញ្ជាក់ជូនលោកស្រីឲ្យច្បាស់ មិនមែនខាងមុខហ្នឹង មុខអីទេ ខាងមុខខ្ទម ផ្លូវចូលក្នុងខ្ទម។

**ស៖** ឥឡូវមើលទៅខ្ញុំអស់ពេលហើយ។ ឥឡូវសំណួរចុងក្រោយតែម្ដង ព្រោះខ្ញុំមិនអាចធ្វើអីខុសពីហ្នឹងទេ។ <ខ្ញុំសួរសំណួរនេះទៅលោកស្រី ដោយសារ>នៅក្នុងឯកសារ<របស់លោកស្រី គឺ> E3/4779 ERN ជាភាសាបារាំងគឺ 00900952, ERN ជាភាសាអង់គ្លេសគឺ 00891280, ERN ជាភាសាខ្មែរ 00499825។ មានសរសេរដូចតទៅនេះ៖ "គាត់បានចាប់ដៃខ្ញុំ ហើយគាត់រំលោភខ្ញុំបាន ខ្ញុំខំប្រឹងបម្រះ ប៉ុន្តែរើមិនរួច។ ហើយឈ្លបនៅក្រោមផ្ទះដើម្បីលបស្ដាប់យើង យាមយើង។" អ៊ីចឹងតើលោកស្រីនឹកឃើញទេ ថាអាចជម្រាបជូនតុលាការបានដែរឬទេថា ឈ្លបហ្នឹងនៅក្រោមផ្ទះ ឬក៏នៅមុខផ្ទះ នៅច្រកចូលផ្ទះ?

**ឆ៖** ចាស ខ្ញុំនិយាយតាំងពីម្សិល ក្រោមហ្នឹងចូលអត់រួចទេ គឺទាប នៅឈរនឹងមាត់ទ្វារខាងមុខ។

**ស៖** អ៊ីចឹងគឺបានន័យថា ជាមានកំហុសនៅក្នុងឯកសារទី១ ដែលខ្ញុំទើបតែនឹងដកស្រង់អម្បាញ់មិញ គឺឯកសារដែលលោកស្រីបានបំពេញនៅឆ្នាំ២០០៨ហើយអ៊ីចឹង មែនទេ?

**ឆ៖** ចាស ខ្ញុំបានបំពេញ ឧទាហរណ៍ថា កូនអំមិញអ៊ីចឹង កូនខ្ញុំស្រីប្រាំ ប្រុសមួយ ទៅដាក់កូនខ្ញុំប្រុសប្រាំមួយ ស្រីមួយ។ ឃើញថាខុសពាក្យរបស់ខ្ញុំបាត់ហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅសហព្រះរាជអាជ្ញារងអន្តរជាតិ?

[១១:៥៥:៣៣]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

បាទ លោកប្រធាន បន្ថែមពីលើនេះ ឥឡូវនេះយើងលើសពេល១០នាទីទៅនឹងអ្វីដែលលោកប្រធានបានផ្ដល់ឲ្យហើយ។ ដូច្នេះខ្ញុំ<>ចង់លើកឡើងពីចំណុចនេះមួយ។ ហើយមួយទៀត វាមានបញ្ហាខុសគ្នាក្នុងការបកប្រែ នៅពេលដែលខ្ញុំស្ដាប់ឮភាសា ការបកប្រែជាភាសាអង់គ្លេស គឺថាវាខុសពីភាសាបារាំង <ដែលនិយាយថា "នៅក្រោមផ្ទះ" ហើយការបកប្រែជាភាសាអង់គ្លេសនៃ>ឯកសារដូចគ្នា គឺសរសេរថា "នៅជាន់ផ្ទាល់ដី"។ <ដូច្នេះវាមិនច្បាស់ទេ ការបកប្រែដែលមេធាវីយោងនោះ ដែលអាចមានការភ័ន្តច្រឡំពាក់ព័ន្ធនឹងភាពត្រឹមត្រូវ>។

**កញ្ញា អង់តា ហ្គីសសេ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សហភាតារបស់ខ្ញុំ ជនជាតិខ្មែរ គាត់ប្រាប់ថា ជាភាសាខ្មែរហ្នឹងគឺថានៅក្រោមផ្ទះ។ អ៊ីចឹងយើងត្រូវតែផ្តល់តម្លៃទៅឯកសារជាភាសាខ្មែរ។ លោកប្រធាន ខ្ញុំសូមអរគុណដែលបានផ្តល់ពេលវេលាបន្ថែមឲ្យខ្ញុំ ឲ្យខ្ញុំសួរសំណួរចប់ លោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាចុងក្រោយនេះ លោកស្រី ប៉ែន សុចាន់ លោកស្រីអាចថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកស្រីទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលមានការពាក់ព័ន្ធនឹងការចោទប្រកាន់ទៅលើជនជាប់ចោទ នួន ជា និង ខៀវ សំផន ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

[១១:៥៧:២១]

**លោកស្រី ប៉ែន សុចាន់៖**

ចាស កាលសម័យនោះ ខ្ញុំមានទុក្ខលំបាកជាច្រើនកើតមកជាកូនខ្មែរ កើតមកជាស្រីនឹងគេដែរ តែមិនបានពេញលក្ខណៈរៀបការត្រឹមត្រូវ មានតែគេចាប់បង្ខំ។ របួសរាងកាយខ្ញុំ គេរំលោភហើយ ផ្អាក់ឈាមមួយខែជាង ហើយគេវាយដំធ្វើបាប បម្រើ ក្បាលត្បូងតប គឺមាននៅសព្វថ្ងៃ។ ជើងដៃរបស់នាងខ្ញុំគ្មានសាច់ដែលម៉ែបង្កើតទេ។ គឺនៅពេលនោះ ខ្ញុំហើម ខ្ញុំហើមដើរទៅធ្វើការមិនរួច។ គេជិះសេះវាយខ្ញុំពីក្រោយ ខ្ញុំក៏ដួលផ្កាប់មុខទៅចូលក្នុងទឹកទៅ។ ក្រឡេកមកឃើញខ្លួនឯងវេទនាដូច្នេះ បានខ្ញុំខំដាក់ពាក្យបណ្តឹងរកយុត្តិធម៌ពីជនជាប់ចោទ ឲ្យបានក្មេងសាក្រោយដឹង តើគេធ្វើអ៊ីចឹងដើម្បីអ្វីទៅ។ ងាកមកដល់ម្តាយ មើលទៅម្តាយ រត់ទៅរកម្តាយ ប្អូនទាំងប្អូនហើមនៅលើគ្រែ គ្មានងើបរួច ឪពុកក៏បាត់។ ក្បាលខ្ញុំបែក លេបថ្នាំសរសៃប្រសាទរាល់ថ្ងៃ បានភី.ភី.អូ ជួយ គឺគេអត់ឲ្យខ្ញុំដាច់ថ្នាំនោះទេ លោកប្រធាន។ ពេលគេបើកថ្នាំឲ្យ គេអត់ឲ្យខ្ញុំកាន់ទេ។ សម័យផ្តាច់ការ ខ្ញុំលំបាកអស់ហើយ មកសម័យនេះ ក៏ខ្ញុំជួបនឹងប្តីខ្ញុំទៀត។ បាត់បងបងប្អូន យាយតា គេសម្លាប់អស់ ដូចចាញ់ឃោសនាវាថា ស្លៀកពាក់ខោអាវទៅទៅធ្វើទាហានវិញ ស្លៀកពាក់ខោអាវទៅ ៗឡើងឡានទៅ ទៅធ្វើការក្នុងរោងវិញ ទៅបាត់សព្វថ្ងៃ អត់បានឃើញមុខគាត់ទេ។ ឪពុកខ្ញុំ ខ្ញុំស្រឡាញ់ណាស់ មិនដែលវាយខ្ញុំទេ។ គេយកគាត់ទៅសម្លាប់ទីណា ក៏ខ្ញុំមិនដឹង។ ចំណែកបងប្អូនជីដូនមួយ សុទ្ធតែអ្នកចេះដឹង គេសម្លាប់ចោលអស់។ តើប្រទេសផ្តាច់ការនោះធ្វើអ៊ីចឹងដើម្បីអ្វី? មិនមានរងគ្រោះតែខ្ញុំទេ បងប្អូនណាក៏រងគ្រោះដូចខ្ញុំ អង្គរមួយកំប៉ុង៣០នាក់ លោកប្រធាន ជួយគិតមើល៎ តើយើងឆ្អែតដើម្បីអ្វី?

[១២:០០:២៧]

បងប្អូនបាត់បង់អស់ដីស្រែ ផ្ទះសម្បែង។ ម្តាយទៀតរងទុក្ខ ហើមវេទនាសម័យខ្មែរក្រហម អស់ចិត្ត ដល់ស្រុកគេស្រួលគាត់ស្លាប់ចោលខ្ញុំទៀត។ ខ្ញុំជាស្រីមេម៉ាយ មានកូនប្រាំមួយនាក់ សព្វថ្ងៃខ្ញុំនៅរស់ស៊ីស្រុកគេទេ។ ខ្ញុំទើបនឹងមកភ្នំផ្នាំនេះម្តង ខ្ញុំបានទៅរកគេ ស្រុកគេ២ឆ្នាំហើយ។ ខ្ញុំវេទនា គ្មានផ្ទះ គ្មានសម្បែង កូន។ មកនេះមកផ្ទះកូន បានមេធាវីគាត់កោះអញ្ជើញខ្ញុំមក ហើយខ្ញុំក៏អត់មានរៀបរាប់អ្វីទៀត តែខ្ញុំមានសំណួរមួយសួរទៅខាងជនជាប់ចោទ តាមរយៈលោកប្រធាន។ ខាងជនជាប់ចោទ ខ្ញុំសូមសួរគាត់សំណួរទី១ ហេតុអ្វីបានគេរៀបការមិនមនុស្សដែលមិនស្គាល់មុខ ចាប់បង្ខំឲ្យខ្ញុំរៀបការ ធ្វើបាបខ្ញុំ? តើសង្គមនោះធ្វើអ៊ីចឹងដើម្បីអ្វី? ទី២ ហេតុអីបានប្រើមនុស្សហួសកម្លាំង សម្លាប់មនុស្សដែលមិនរើសមុខ អ្នកចេះដឹង សម្លាប់អស់? ខ្ញុំសួរទៅតាមរយៈលោកប្រធាន ទៅអ៊ំជាប់ចោទ តើគាត់ធ្វើអ៊ីចឹងដើម្បីអ្វី?

ខ្ញុំអស់ជាយោបល់ ចាស។ ខ្ញុំសូមទាមទារសំណងដូចជា វត្តអារាម សាលារៀន ឲ្យកូនក្មេងសាក្រោយចេះដឹង កុំឲ្យល្ងិតល្ងង់ដូចខ្ញុំ វ័យខ្ញុំកំពុងសិក្សា ហេតុអ្វីបានខ្ញុំល្ងង់ ដោយសារគាត់របបផ្តាច់ការរបស់គាត់ តើគាត់ធ្វើអ៊ីចឹងដើម្បីអ្វី? ខ្ញុំអស់យោបល់ហើយលោកប្រធាន។ ខ្ញុំសួរទៅគាត់ខាងជនជាប់ចោទ ទៅតាមរយៈលោកប្រធាន ចាស។

[១២:០២:៤៤]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនលោកស្រី ប៉ែន សុចាន់ ថានៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់នូវជនជាប់ចោទទាំងពីរនាក់ ឆ្លើយបញ្ជាក់អំពីពួកគាត់ រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់នៅតែរក្សាជំហររបស់ខ្លួន បន្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែរហូតដល់ពេលណា ដែលអង្គជំនុំជម្រះទទួលបានព័ត៌មានជាក់ច្បាស់ពីជនជាប់ចោទ ឬក៏ពីសហមេធាវីការពារក្តីជនជាប់ចោទ។ ហើយនៅក្នុងសវនាការថ្ងៃនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ ឬសហមេធាវីការពារក្តីជនជាប់ចោទ មានការទទួលខុសត្រូវជូនដំណឹងមកអង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទបានសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយព្រមឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធនៅដំណាក់កាលណាមួយនៃកិច្ច

ដំណើរការនីតិវិធី។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្ដូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ទេ ហើយពីការសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតបមកជាការឆ្លើយតបនោះ។ ហើយនៅក្នុងវិធានច្បាប់ជាតិ និងច្បាប់អន្តរជាតិ គឺអង្គជំនុំជម្រះមិនមានសិទ្ធិនៅក្នុងការបង្ខំឱ្យជនជាប់ចោទ ឆ្លើយតបទៅនឹងសំណួរទេ ប្រសិនបើជនជាប់ចោទបានប្រកាន់ជំហររក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប សូមលោកស្រីជ្រាប។

ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រី ប៉ែន សុចាន់ សវនាការស្ដាប់សក្ខីកម្ម និងថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មក្នុងឋានៈលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយដល់ពេលនេះ បានដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ហើយនៅពេលនេះ វត្តមានរបស់លោកស្រីលែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ ហើយសូមលោកស្រីជួបតែសំណាងល្អ មានសុខភាពល្អ ហើយបានសេចក្ដីសុខ សេចក្ដីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយបញ្ជាក់ថា នៅរសៀលនេះ អង្គជំនុំជម្រះនឹងផ្ដើមធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-960 ហើយសាក្សីរូបនេះ នឹងមានមេធាវីប្រឹក្សា គឺលោកស្រី សុក សុជាតា សូមភាគីជ្រាប។

ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ ហើយនិងឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឱ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-960។ ប៉ុន្តែមុននឹងស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះចេញសេចក្តីសម្រេចផ្ទាល់មាត់លើបញ្ហាមួយចំនួន លើសំណើសុំរបស់ភាគី ហើយនិងស្តាប់សារណាផ្ទាល់មាត់ពីភាគី ពាក់ព័ន្ធនឹងសំណើសុំរបស់សហមេធាវីការពារក្តីលោក នួន ជា។

ទី១ សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សូមឲ្យទទួលយកឯកសារពីសំណុំរឿង០០៣, ០៤ អនុលោមតាមវិធី៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E319/52 និង E319/58)។ អង្គជំនុំជម្រះទទួលការជូនដំណឹងតាមរយៈអ៊ីម៉ែលនៅថ្ងៃទី១០, ១២ ខែតុលា ឆ្នាំ ២០១៦ ថាសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងប្រើប្រាស់ចម្លើយនានា ដែលមាននៅក្នុងឯកសារ E319/52.3.1, E319/52.3.3 និង E319/58.2.4 នៅក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-960 ដែលត្រូវបានកំណត់ពេលមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ។

[១៣:៣៣:៤៩]

ឯកសារទាំងនេះនឹងគឺជាកម្មវត្ថុនៃសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុងគឺឯកសារ E319/52 ដែលបានដាក់កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៦ គឺឯកសារ E319/58 ដែលបានដាក់នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦។ នាពេលនេះ -- នាពេលថ្មីនេះ អង្គជំនុំជម្រះសាលាដំបូងពុំទាន់បានសម្រេចទៅលើសំណើសុំទាំងនេះនៅឡើយទេ ដោយហេតុថាសាក្សី 2-TCW-960 នឹងចូលមកផ្តល់សក្ខីកម្មនៅរសៀលនេះ អង្គជំនុំជម្រះនឹងសម្រេចលើការទទួលយកឯកសារទាំងបីនេះនាពេលនេះ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីការពារក្តី ខៀវ សំផន

បានដាក់ចម្លើយតបទៅនឹងឯកសារ E319/52 នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ដោយបានជំទាស់មិនឲ្យទទួលយកឯកសារ E319/52.3.1 និង E319/52.3.3។

អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ចម្លើយតបរួមរបស់មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន ទៅនឹងសំណើរសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E319/56 និង E319/58) បានដាក់នៅថ្ងៃចន្ទ ទី១០ ខែតុលា ឆ្នាំ២០១៦ ដែលនៅក្នុងចម្លើយតបរួមនោះ ពួកគាត់ជំទាស់ទៅនឹងការទទួលយកឯកសារ E319/58.2.4។ ការទទួលយកឯកសារ E319/52.3.1, E319/52.3.3 និង E319/58.2.4 ធ្វើជាឯកសារភស្តុតាង ត្រូវបានជំទាស់ដោយសំអាងលើភាពយឺតយ៉ាវ និងភាពមិនជាប់ពាក់ព័ន្ធ។

[១៣:៣៥:៥៥]

បន្ទាប់ពីបានពិចារណាលើសេចក្តីសន្និដ្ឋានរបស់ភាគី និងដោយបានកត់សម្គាល់ពីលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសម្រេចទទួលយកឯកសារខាងក្រោមនេះធ្វើជាឯកសារភស្តុតាង និងដាក់លេខសម្គាល់ឯកសារទាំងនេះនៅក្នុងវង្វង់ក្រចក គឺឯកសារ E319/52.3.1 មានលេខសម្គាល់ E3/10682 និងឯកសារភ្ជាប់ E319/52.3.1a មានលេខសម្គាល់ E3/10682a, ឯកសារ E19/52.3.3 មានលេខសម្គាល់ E3/10683, ឯកសារ E319/58.2.4 មានលេខសម្គាល់ E3/10684។ សំអាងហេតុជាលាយលក្ខណ៍អក្សរនឹងចេញនៅពេលសមស្របខាងមុខនេះ។

អង្គជំនុំជម្រះសាលាដំបូងបានផ្តួចផ្តើមគំនិត មានបំណងទទួលយកឯកសារ E319/52.2.17 បន្ថែមទៀត ដែលឯកសារនេះគឺជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី 2-TCW-960។ ឯកសារ E319/52.2.17 នេះរួមមានឯកសារភ្ជាប់ចំនួនប្រាំ ដែលឯកសារភ្ជាប់ទាំងនោះគឺរូបថត ដែលមានឯក-សារលេខ E319/52.2.17.1 ដល់ E319/52.2.17.5។ អង្គជំនុំជម្រះរំឭកអំពីទម្លាប់អនុវត្តរបស់ខ្លួនក្នុងការទទួលយកឯកសារភស្តុតាង នូវចម្លើយពីមុនៗទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីដែលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន៨៧(៣) និងវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ដូច្នេះដើម្បីជាប្រយោជន៍នៃយុត្តិធម៌ អង្គជំនុំជម្រះទទួលយកឯកសារE319/52.2.17 និងឯកសារចំនួនប្រាំទៀតធ្វើជាឯកសារភស្តុតាង និងដាក់លេខសម្គាល់ឯកសារទាំងនេះជាឯកសារ E3/10681, E3/10681.1 រហូតដល់ E3/10681.5។

[១៣:៣៩:០៤]

សេចក្តីសម្រេចទី២ លើសំណើសុំរបស់សហមេធាវីនាំមុខ ស្នើសុំរយៈពេលបន្ថែមមួយថ្ងៃ សម្រាប់សវនាការលើសេចក្តីថ្លែងទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលសារណាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់បញ្ជីឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវមកផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើសេចក្តីថ្លែងទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មសម្រាប់វគ្គសវនាការទី៥ក្នុងសំណុំរឿង០០២/០២ សំណើដែលមានលេខឯកសារ E315/1/7 ដែលនៅក្នុងនោះសហមេធាវីនាំមុខបានស្នើសុំរយៈពេលបន្ថែមមួយថ្ងៃសម្រាប់សវនាការនេះ ដោយហេតុថា អង្គជំនុំជម្រះនឹងមិនស្តាប់សក្ខីកម្មដើមបណ្តឹរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-264 ហើយថាសំណើនេះនឹងមិនប៉ះពាល់ដល់ភាគីណាមួយឡើយ។

មេធាវីការពារក្តី ខៀវ សំផន បានដាក់សារណាឆ្លើយតបនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ដោយជំទាស់ទៅនឹងសំណើនេះ។ អង្គជំនុំជម្រះរំឭកថា កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់ថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលបានរយៈពេលមួយថ្ងៃ ជំនួសឲ្យរយៈពេលពីរថ្ងៃ សម្រាប់សវនាការលើសេចក្តីថ្លែងទុក្ខសោកវេទនា និងព្យសនកម្មសម្រាប់ប្រធានបទសវនាការស្តីពីការចេញបទបញ្ជារៀបអាពាហ៍ពិពាហ៍ ដោយបានកត់សម្គាល់អំពីចំនួនដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលត្រូវបានជ្រើសរើសឲ្យមកផ្តល់សក្ខីកម្ម (ឯកសារ E421)។

[១៣:៤០:៤៥]

ទោះបីជាអង្គជំនុំជម្រះកត់សម្គាល់អំពីសារណារបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលថាដើមបណ្តឹងរដ្ឋប្បវេណី2-CCP-264 ត្រូវកំណត់ថាពុំមានសម្បទាគ្រប់គ្រាន់ក្នុងការផ្តល់សក្ខីកម្មដោយសារតែបញ្ហាសុខភាព ហើយត្រូវបានដកឈ្មោះចេញពីបញ្ជីឈ្មោះបុគ្គលដែលត្រូវផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងប្រធានបទសវនាការស្តីពីចេញបទបញ្ជារៀបអាពាហ៍ពិពាហ៍ នៅក្នុងឯកសារ E29/493/2 ក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះបានជ្រើសរើសបន្ថែមដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-283 និង 2-TCCP-1064 នៅក្នុងបញ្ជីឈ្មោះរបស់ខ្លួនរួចហើយ។ សរុបមក ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៦បានផ្តល់សក្ខីកម្មរួចហើយ ឬ/និងផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២ ទៅលើប្រធានបទនេះ។ ហើយក្នុងចំណោមអ្នកទាំងនោះ មានដើម

បណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំបួននាក់ ផ្ដល់សក្ខីកម្មនៅក្នុងអំឡុងប្រធានបទសវនាការស្ដីពីចេញបទបញ្ជារៀបអាពាហ៍ពិពាហ៍។

ដូច្នេះអង្គជំនុំជម្រះយល់ឃើញថាសម្អាងហេតុពីដំបូងរបស់អង្គជំនុំជម្រះ ដែលផ្ដល់រយៈពេលមួយថ្ងៃ សម្រាប់សវនាការនេះនៅតែមានសុពលភាពដដែល។ ហើយអង្គជំនុំជម្រះច្រានចោលសំណើរបស់សហមេធាវីនាំមុខដែលបានស្នើសុំរយៈពេលបន្ថែមមួយថ្ងៃទៀត។ អង្គជំនុំជម្រះបង្គាប់ឱ្យសហមេធាវីនាំមុខដាក់សារណាកែសម្រួលបញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី ដែលនឹងត្រូវមកផ្ដល់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើសេចក្ដីថ្លែងទុក្ខសោកវេទនា និងព្យសនកម្មដែលបានទទួលរងសម្រាប់វគ្គជំនុំជម្រះទី៥ ហើយឱ្យកំណត់រយៈពេលមួយថ្ងៃសម្រាប់ការផ្ដល់សក្ខីកម្មនេះ។

[១៣:៤២:៣៧]

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះមានបំណងធ្វើសវនាការស្ដាប់សារណាភាគីលើសំណើសុំរបស់សហមេធាវីការពារក្ដី នួន ជា ដែលអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះបានទទួលសំណើរបស់មេធាវីការពារក្ដី នួន ជា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង សូមឱ្យទទួលយកឯកសារចំនួនប្រាំបី និងសំណើអនុលោមតាមវិធាន៩៣ ពាក់ព័ន្ធនឹងឯកសារចំនួនពីរ គឺទាក់ទងទៅនឹងអ្នកជំនាញ E អ្នកជំនាញ 2-TCE-98 ដែលបានដាក់កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ហើយសំណើដែលមានលេខឯកសារ E445/1។ តាមកាលវិភាគសវនាការដែលបានកំណត់ អង្គជំនុំជម្រះគ្រោងនឹងស្ដាប់សក្ខីកម្មអ្នកជំនាញ E អ្នកជំនាញ 2-TCE-98 នៅសប្ដាហ៍ក្រោយ។

កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានទទួលដំណឹង បានជូនដំណឹងដល់ភាគីថាខ្លួនមានបំណងស្ដាប់សារណាឆ្លើយតបផ្ទាល់មាត់របស់ភាគីនានា ទៅនឹងសំណើដែលមានលេខឯកសារ E445/1 នៅថ្ងៃនេះ បន្ទាប់ពីបញ្ចប់ការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់។

នាពេលនេះអង្គជំនុំជម្រះនឹងស្ដាប់ចម្លើយតប ឬក៏កត់សម្គាល់ផ្ទាល់មាត់របស់ភាគីនានាទៅនឹងសំណើនេះ។ ហើយដំបូងនេះផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី ខៀវ សំផន ឆ្លើយតប ឬក៏កត់សម្គាល់លើសំណើសុំរបស់មេធាវីការពារក្ដី នួន ជា ប្រសិនបើមានសូមអញ្ជើញ។

[១៣:៤៤:២៥]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជាគោលការណ៍ យើងមិនជំទាស់អ្វីទៅនឹងសំណើរបស់មេធាវី

ការពារក្តីលោក នួន ជា ទេ។ ឯកសារដែលគាត់ចង់ដាក់ជាភស្តុតាងនេះ មានភាពពាក់ព័ន្ធសម្រាប់សក្ខីកម្មរបស់អ្នកជំនាញដែលនឹងមកនៅពេលខាងមុខនេះ។ ពាក់ព័ន្ធនឹងពេលវេលា ក៏យើងមិនមានការ<លំបាកអ្វីទេ> ពីព្រោះ<យើងបានដឹងហើយ>ថា អង្គជំនុំជម្រះ<បាន>កំណត់កាលវិភាគសម្រាប់សាក្សីនេះ<រួចហើយ>។

ដូច្នេះ<អ្វីដែល>យើងខ្ញុំ<ត្រូវ>ធ្វើ<គឺត្រូវធ្វើសារណា>បន្ថែមទៅលើឯកសារលេខ៨ ដែលវាមានវិវាទ ពីព្រោះថាវាជាសុន្ទរកថារបស់ព្រះបរម<រតន>កោដ្ឋ នរោត្តម សីហនុ ហើយដែលមានសំណើតាមវិធាន៨៧(៤)ហើយ <ដែលបានធ្វើ>នៅពេលដែលស្តាប់សក្ខីកម្មអ្នកជំនាញ ហ៊ីនតុនហើយលោក អង្គជំនុំជម្រះបានបដិសេធមិនទទួលយកដោយអះអាងថា ឯកសារនេះវាក្រោយឆ្នាំ១៩៧៩ អ៊ីចឹងវាមិនមានភាពពាក់ព័ន្ធនោះទេ។ <ពាក់ព័ន្ធនឹងកាលវិភាគសម្រាប់ធ្វើសក្ខីកម្ម>អ្នកជំនាញ<>ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ជាពិសេសពាក់ព័ន្ធនឹងបរិបទភូមិសាស្ត្រនយោបាយ ដែលមានទំនាក់ទំនងជាមួយនឹងវៀតណាមនេះ <ហើយ>ចំពោះឯកសារសំខាន់មួយនេះ យើងគាំទ្រទៅលើសំណើតាមវិធាន៨៧(៤)។ យើងខ្ញុំគិតថា ការពិភាក្សា<ជាមួយអ្នកជំនាញអាច>មានសារៈសំខាន់<ពាក់ព័ន្ធទៅនឹង>សុន្ទរកថា<>របស់សម្តេច នរោត្តម សីហនុ ពាក់ព័ន្ធទៅនឹងគោលជំហររបស់វៀតណាម <ជាទូទៅហើយនិងជំហរខុសៗគ្នាដែលទ្រង់មាននៅពេលក្រោយមកទៀត>។ ហើយទោះបីជាសំបុត្ររបស់សម្តេច ព្រះនរោត្តម សីហនុ <មានកាលបរិច្ឆេទក្រោយឆ្នាំ១៩៧៩ គឺ>កើតក្រោយហេតុការណ៍ក៏ដោយក៏វាបង្ហាញអំពីការទំនាក់ទំនងរវាងកម្ពុជាវៀតណាម ដែលវាពាក់ព័ន្ធទៅនឹងរយៈកាលដែលវាពាក់ព័ន្ធទៅនឹងសំណុំរឿងរបស់យើង។ ហើយនៅក្នុងការពិភាក្សាទូទៅអំពីភូមិសាស្ត្រនយោបាយ នៃតួអង្គដែលពាក់ព័ន្ធ ហើយនិងបញ្ហាប្រឈមនានានៅសម័យនោះ ក៏ដូចជាយុត្តិសាស្ត្ររបស់ប្រទេសទាំងពីរ។ អ៊ីចឹងខ្ញុំគិតថាឯកសារនេះ មានសារៈសំខាន់ខ្លាំងណាស់ ហើយវាមានភាពពាក់ព័ន្ធទៅដល់ការពិភាក្សាគ្នាជាមួយនឹងអ្នកជំនាញនាពេលខាងមុខនេះ ពីព្រោះថាគាត់បានធ្វើការទៅលើឯកសារចាស់ៗរបស់សូវៀត ហើយគាត់ផ្តោតទៅលើតួអង្គសំខាន់ៗនៅក្នុងសម័យនោះ ហើយអង្គសម្តេច នរោត្តម សីហនុ ក៏មានភាពពាក់ព័ន្ធនៅក្នុងនោះដែរ។

[១៣:៤៧:១១]

ដូច្នេះឯកសារទាំងអស់នោះ ទោះបីជាកើតមុនក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក្រោយក៏ដោយ ក៏វាមានសារៈសំខាន់ផងដែរ។ ហើយនៅក្នុងឯកសារនោះ ក៏មាននិយាយអំពីពាក្យថា “យួន”។

ហើយអង្គជំនុំជម្រះមិនបានសម្រេចថាមានភាពពាក់ព័ន្ធទេ នៅពេលដែលយើងពិភាក្សាជាមួយនឹងអ្នកជំនាញ ហ៊ីនតុន នោះ។ ក៏ប៉ុន្តែក្នុងក្របខ័ណ្ឌនៃការសួរដេញដោលអ្នកជំនាញខាងមុខនេះ យើងគិតថាឯកសារនេះមានសារៈសំខាន់ ដើម្បីឲ្យយើងអាចសួរដេញដោល និងពិភាក្សាជាមួយគាត់។

ដូច្នេះខាងមេធាវីការពារក្តីលោក ខៀវ សំផន យល់ឃើញថាឯកសារមួយនេះមានសារៈសំខាន់ណាស់<មានភាពពាក់ព័ន្ធ>។ នេះជាខ្លឹមសារនៃការកត់សម្គាល់របស់ខ្ញុំទៅលើឯកសារលេខរៀងទី៨ ដែលពាក់ព័ន្ធទៅនឹងព្រះបរម<រតន>កោដ្ឋ នរោត្តម សីហនុ។

ហើយចំពោះឯកសារផ្សេងៗទៀតនោះ ខ្ញុំគោរពទៅតាម -- ខ្ញុំគាំទ្រទៅនឹងការលើកឡើងរបស់មេធាវីការពារក្តីលោក នួន ជា។ ហើយដល់អ៊ីចឹង យើងពិចារណាផងដែរទៅលើការកំណត់កាលវិភាគថ្មីៗក្នុងការកោះហៅអ្នកជំនាញនេះ អ៊ីចឹងគ្មានមូលហេតុអ្វីដែលអង្គជំនុំជម្រះបដិសេធនូវសំណើរបស់មេធាវី នួន ជា នោះទេ។

[១៣:៤៨:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងតំណាងសហព្រះរាជអាជ្ញាដើម្បីឆ្លើយតបទៅនឹងសំណើ -- បាទ សហព្រះរាជអាជ្ញា អញ្ជើញឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ជាដំបូងយើងសូមឆ្លើយតបចំពោះ<លក្ខខណ្ឌនេះថា> យើងមិនទាន់មានឱកាសបានពិនិត្យមើលទៅលើឯកសារនេះ<ឲ្យលម្អិត>នៅឡើយ<ទេ។ ខ្ញុំគិតថា ឯកសារនេះទើបតែត្រូវបានទទួលយកចូលក្នុងសំណុំរឿង>ប្រហែលជាមួយថ្ងៃ ពីរថ្ងៃប៉ុណ្ណោះ គឺយើងទទួលបាននៅថ្ងៃ១១ ហើយវាមាន ឯកសារនេះមានប្រហែលជា៣០០ទំព័រ។ ប៉ុន្តែជាទូទៅ យើងសង្កេតឃើញការអនុវត្តរបស់អង្គជំនុំជម្រះទាក់ទងសំណើតាមវិធាន៨៧(៤) <ចំពោះ>ឯកសារ<ដែលអាចរកបាន> មុនពេលសវនាការ<ចាប់ផ្តើម>។ ប៉ុន្តែយើងកត់សម្គាល់ឃើញថាឯកសារនេះ វាមានភាពពាក់ព័ន្ធខ្លះ ប៉ុន្តែ<ទស្សនៈរបស់>យើង<គឺ>ថា ឯកសារនេះមិនមែនជាឯកសារដោះបន្ទុកនោះឡើយ។ <នេះជាកត្តាមួយដែលលោកចៅក្រមត្រូវពិចារណា។> ភាគច្រើននៃឯកសារនេះ គឺសរសេរដោយអ្នកជំនាញដែលនឹងត្រូវមកផ្តល់សក្ខីកម្ម ហើយស្របទៅនឹងការអនុវត្ត<ទូទៅចំពោះសាក្សី> យើងមិនជំទាស់ទៅ

នឹងការស្នើសុំឱ្យទទួលយកឯកសារដែលនិពន្ធដោយអ្នកជំនាញបែបនេះឡើយ។ដូច្នេះខ្ញុំគិតថា ឧបសម្ព័ន្ធ ទី១ ទី២ ទី៣ <ទី៦>។ យើងសូមជំទាស់ចំពោះឯកសារដទៃទៀត ដោយសារតែមិនមានភាពពាក់ព័ន្ធ ពិតប្រាកដ លើកលែងតែឯកសារចុងក្រោយ គឺឯកសារទី៨ ដែលមេធាវី <ខៀវ សំផន> ទើបតែលើកឡើង គឺជាលិខិត<ជាច្រើន>របស់សម្ដេចព្រះបរមរតនកោដ្ឋ ដែលនិយាយអំពីរដ្ឋាភិបាលវៀតណាម។

[១៣:៥០:២៣]

ឯកសារនេះវាមានភាពពាក់ព័ន្ធ ប៉ុន្តែយើងស្នើសុំផងដែរថា ប្រសិនបើទទួលយកឯកសារនេះ ស្របទៅនឹងការសម្រេចកន្លងមក<របស់លោកចៅក្រម ចំពោះភស្តុតាងបដិសេធ>គឺ ខ្ញុំសូមពិចារណា សូមដាក់អង្គជំនុំជម្រះពិចារណាផងដែរថា នៅពេលដែលមានភស្តុតាងថ្មី គឺយើងបានផ្ញើនូវឯកសារ ចំនួនបី តាមរយៈអ៊ីម៉ែល ដោយសារតែយើងគិតថា វាជាឯកសារសំខាន់ដើម្បីបង្ហាញពីទស្សនៈរបស់ សម្ដេចព្រះបរមរតនកោដ្ឋ គឺជាទស្សនៈជារួម មិនមែនជាប្រយោល ឬដោយចំពោះណាមួយនោះ ឡើយ។ គឺថាយើងចង់ឱ្យបង្ហាញ ឱ្យឃើញពីទិដ្ឋភាពច្បាស់លាស់ និងទិដ្ឋភាពជារួមរបស់សម្ដេចព្រះ បរមរតនកោដ្ឋ អំពីរបបកម្ពុជា<ប្រជាធិបតេយ្យ>នៅពេលនោះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹង រដ្ឋប្បវេណី ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីរបស់មេធាវីការពារក្ដីលោក នួន ជា។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមអរគុណចំពោះរាល់មតិយោបល់របស់ភាគីលើ ពិភាក្សាលើបញ្ហានេះ។ អង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិភាក្សា និងចេញសេចក្ដីសម្រេច – សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ។

[១៣:៥១:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ហើយសូមអភ័យទោសដែលខ្ញុំត្រូវងើបឡើងដើម្បីកាត់បែបនេះ។ ការឆ្លើយតប--

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ការធ្វើសំណើសុំការឆ្លើយតប។ ខ្ញុំគិតថា យើងគួរតែផ្តល់-->

**លោក វ៉ិចទ័រ កូប៉េ៖**

<បាទ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<-- វេទិកា --ទៅឲ្យភាគីផងដែរ។>

**លោក វ៉ិចទ័រ កូប៉េ៖**

<បាទ បាទ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<--ទៅឲ្យភាគីផងដែរ។>

**លោក វ៉ិចទ័រ កូប៉េ៖**

<បាទ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ដូច្នេះ លោកនិយាយពីបញ្ហានោះទៅ។>

**លោក វ៉ិចទ័រ កូប៉េ៖**

សំណើដែលផ្ញើតាមសារអេឡិចត្រូនិកនៅថ្ងៃនេះ គឺស្នើនូវភស្តុតាងដែលបដិសេធ ឬក៏ច្រានចោលមួយទៀត។ <ខ្ញុំគិតថា ចំណុចនេះថ្មី>នៅក្នុងតុលាការនេះ។ គឺថាយើងមានចម្លើយតបផ្លូវការពីរ។ ទី១ អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទយ៉ាងតឹងរ៉ឹងសម្រាប់ការដាក់ឯកសារ ឬក៏ដាក់ឯកសារថ្មីៗ អនុលោមតាមវិធាន<៨៧> ដែលកំណត់<កាលបរិច្ឆេទចុងក្រោយ>គឺនៅថ្ងៃអង្គារនេះ។ <ដូចលោក លោកស្រីបានសង្កេតមក>ហើយ យើង<បាន>គោរពទៅតាមកាលបរិច្ឆេទកំណត់<នោះយ៉ាង>ហ្មត់ចត់។ ប៉ុន្តែព្រះរាជអាជ្ញា មិនបានគោរពនោះទេ។ <ពេលនេះ ការហៅភស្តុតាងនោះថា>ជាភស្តុតាងប្រឆាំង ឬក៏ជំទាស់ <គឺមិនអាចដោះស្រាយអ្វីបាននោះទេ ព្រោះថានេះជាការពិភាក្សាគ្នាដែលមានជាយូរមកហើយនៅក្នុងតុលាការនេះ។ ជាការពិត ពួកគេគួរតែដឹងថា លោក ម៉ូរីស បានពិភាក្សាយ៉ាងច្រើនអំពី>ជំហររបស់សម្តេច ព្រះបរមរតនកោដ្ឋ<>។

[១៣:៥៣:៣៥]

ការពិតគឺថា ព្រះរាជអាជ្ញាគាត់ដាក់សំណើនេះយឺតពេលវេលា។ ហើយទី២ ឯកសារទាំងបីនេះគឺជាសារព័ត៌មានរបស់សារព័ត៌មានវ៉ាស៊ីនតោនប៉ុស្តិ៍ ដែលសរសេរដោយ អេលីហ្សាបេ៊ត បេកយ័រ នៅខែមករា ៧៩។ ទោះបីថាយើងឃើញមានភាពពាក់ព័ន្ធមួយចំនួនរបស់ឯកសារនេះក៏ដោយ <ខ្ញុំសូមរំឭកដល់អង្គជំនុំជម្រះថា> ក្នុងពេលថ្មីៗនេះ យើងបានដាក់នូវសំណើតាមវិធាន៨៧ ចំនួនពីរ ទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធជាមួយវៀតណាម ស្នើសុំឲ្យទទួលយកឯកសារចំនួន២៨។ ប៉ុន្តែយើងមិនទាន់ទទួលបានសម្អាងហេតុពីអង្គជំនុំជម្រះនៅឡើយ <-- វាជាសេចក្តីសម្រេចផ្ទាល់មាត់ -->។ ដូច្នេះខ្ញុំសូមរំឭកដល់អង្គជំនុំជម្រះផងដែរថា ឯកសារបោះពុម្ពរបស់អ្នកជំនាញមួយរូបទៀតគឺ ណាយ៉ាន់ ចាន់ដា នៅក្នុងទស្សនាវដ្តី *ហ្វារអ៊ីសស្ទើន អេកូណូមិក រីវីយូ* គឺវាមានប្រភេទ ឬក៏វាមានលក្ខណៈប្រហាក់ប្រហែលគ្នា វាជាអត្ថបទប្រហាក់ប្រហែលគ្នា។

ទោះយ៉ាងណាក៏ដោយ សំណើរបស់យើងទាក់ទងទៅនឹងឯកសារនេះ ត្រូវបានបដិសេធដោយអង្គជំនុំជម្រះ ព្រោះថាឯកសារនេះ វាមានតាំងពីយូរណាស់មកហើយ ហើយមេធាវីការពារក្តីគួរតែដាក់ពីមុន ប៉ុន្តែយើងដាក់យឺត ទើបបដិសេធ។ ហេតុដូច្នេះហើយខ្ញុំគិតថា អង្គជំនុំជម្រះគួរតែបដិសេធអត្ថបទរបស់ អេលីហ្សាបេ៊ត បេកយ័រ ដែលបានស្នើ ដោយសារមូលហេតុដូចគ្នា។

[១៣:៥៥:៣៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ទាក់ទងទៅនឹងភស្តុតាងបដិសេធ ខ្ញុំមិនចង់និយាយលម្អិតច្រើនទេ ប៉ុន្តែខ្ញុំចង់ឲ្យមេធាវីការពារក្តីមើលទៅលើសេចក្តីសម្រេចកន្លងមករបស់អង្គជំនុំជម្រះ គឺឯកសារ E421/4 <ដែលយើងអនុញ្ញាតឲ្យទទួលយកក្នុងកាលៈទេសៈចាំបាច់មួយចំនួន>។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយខ្លីទៅលើសំណើរបស់សហព្រះរាជអាជ្ញា។ ដូចដែលខ្ញុំបានជម្រាបមុននេះអ៊ីចឹង បញ្ហានៃលិខិត និងគោលជំហររបស់ព្រះបរមរតនកោដ្ឋនោះ ត្រូវបានលើកឡើងដោយមេធាវីការពារក្តីតាំងពីមុនមកហើយ ហើយប្រសិនបើសហព្រះរាជអាជ្ញាយល់ឃើញថា គោលជំហររបស់ព្រះបរម<រតន>កោដ្ឋមានសារៈសំខាន់ គាត់គួរតែធ្វើតាំងពីមុន ប៉ុន្តែគាត់មិនបានធ្វើទេ។ ហើយខ្ញុំមិនដឹង ថាតើអង្គជំនុំជម្រះនឹងផ្តល់តម្លៃជាភស្តុតាងទៅលើឯកសារនោះ ឬក៏អត់នោះទេ ប៉ុន្តែឯកសារដែលមេធាវី នួន ជា សុំដាក់ចូលនៅក្នុងភស្តុតាងហ្នឹង គឺសុទ្ធតែជាឯកសារ

ដែលចេញមកពីព្រះបរមរតនកោដ្ឋ នរោត្តម សីហនុដោយផ្ទាល់។ ហើយរបស់សហព្រះរាជអាជ្ញាវិញនេះ គឺសុទ្ធតែជាអត្ថបទ និងមតិយោបល់របស់ អេលីហ្សាប៊ែត បេកឃ័រ ទៅលើគោលជំហររបស់ព្រះបរមរតនកោដ្ឋ។

អ៊ីចឹង<តាមទស្សនៈរបស់ក្រុមការពារក្ដី យើងពិតជាផ្ដល់សារៈសំខាន់ទៅដល់>ឯកសារដែលចេញមកពី<ភាគី>ផ្ទាល់។ អង្គជំនុំជម្រះនឹងវាយតម្លៃទៅលើបញ្ហានេះ។ <ប៉ុន្តែនេះជាប្រធានបទដែលមានសារៈសំខាន់សម្រាប់>សហព្រះរាជអាជ្ញា <ដែលពីមុនមក គឺមិនដូច្នោះ>ទេ។ ហើយនៅពេលដែលខ្ញុំ<ពិនិត្យមើលការឆ្លើយតប ដែលបានឆ្លើយមកយើង នៅពេលដែលយើងបានដាក់សំណើ>សុំឲ្យដាក់ព្រះរាជសុន្ទរកថា <និងការឆ្លើយឆ្លងគ្នា>របស់ព្រះបរមរតនកោដ្ឋនោះ សហព្រះរាជអាជ្ញាយល់ឃើញថា មិនមានភាពពាក់ព័ន្ធទេ។ ដូច្នេះហើយ ខ្ញុំចង់ឲ្យអង្គជំនុំជម្រះពិចារណាទៅលើគោលជំហរពីអតីកាលរបស់សហព្រះរាជអាជ្ញានេះផងដែរ។

[១៣:៥៧:៤៥]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំងើបឈរឡើងលឿនបន្តិចហ្នឹង ដោយសារតែខ្ញុំចង់ឆ្លើយតបទៅនឹងចៅក្រម ហ្វេនស៍។ <តាមការចងចាំ>របស់យើងខ្ញុំ គឺ<ថា>សម្រេចរបស់អង្គជំនុំជម្រះ <គឺច្បាស់ណាស់ បាន>អនុញ្ញាតឲ្យយើងដាក់សំណើតាមវិធាន៨៧(៤) <ក្រោយពីថ្ងៃទី០១ ខែកញ្ញា ថាមានតែភស្តុតាងបដិសេធប៉ុណ្ណោះដែលត្រូវទទួលយកជាភស្តុតាងថ្មី>។ ហើយតាមការយល់ឃើញរបស់យើងខ្ញុំ គឺថាវាមិនត្រឹមតែជាបទអត្ថាធិប្បាយរបស់ អេលីហ្សាប៊ែត បេកឃ័រ ប៉ុណ្ណោះទេ ប៉ុន្តែវាមានសម្រង់ផងដែរ ដកស្រង់ចេញពីសម្ដីរបស់សម្ដេចព្រះ នរោត្តម សីហនុ អំពីអ្វីដែលគាត់យល់ឃើញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះខ្ញុំគិតថា<ដើម្បីឲ្យ>អង្គជំនុំជម្រះ<មាន>នូវទិដ្ឋភាពជារួមមួយ<នៃទស្សនៈរបស់ព្រះទ្រង់ ហើយដើម្បីជា>ប្រយោជន៍<នៃការស្វែងរកការពិត អង្គជំនុំជម្រះគួរតែទទួលយកឯកសារទាំងនេះ បន្ថែមទៅលើលិខិតនេះ>។ សូមអរគុណ។

**កញ្ញា អង់តា ហ្គីសេះ៖**

លោកប្រធាន នេះមិនមែនជាការឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាទេ គ្រាន់តែជា<ការស្នើសុំ។> ខ្ញុំមិនដឹងថា តើគោលជំហររបស់អង្គជំនុំជម្រះយ៉ាងម៉េច ទៅលើឯកសារថ្មីដែលបង្ហាញដោយសហព្រះរាជអាជ្ញា<នោះទេ>។ ក៏ប៉ុន្តែបើសិនបើអង្គជំនុំជម្រះសម្រេចទទួលយកនោះ ខ្ញុំមានសំណើ

មួយទៀតទៅសហព្រះរាជអាជ្ញា។ នៅក្នុងអត្ថបទទាំងបីដែលបានផ្ញើជូនមកខាងយើងខ្ញុំ ខ្ញុំឃើញថា នៅទំព័រដំបូងនៃឯកសារនីមួយៗ គឺ<មានចំណារ>មួយនៅក្នុង<នោះ គឺមួយក្នុងចំណោម>ឯកសារទាំង២៧។ ខ្ញុំ<យល់តាមរយៈការ>អានអត្ថបទសង្ខេបនៃអត្ថបទទាំងបីហ្នឹង គឺ<វាជាអត្ថបទជាឈុតបន្តបន្ទាប់គ្នា>របស់ អេលីហ្សាប៊ែត បេកយ័រ ទៅលើគោលជំហររបស់ព្រះបរមរតនកោដ្ឋ។ អ៊ីចឹងវាមានអត្ថបទច្រើនទៅលើប្រធានបទមួយនេះ។ ហើយប្រសិនបើអង្គជំនុំជម្រះទទួលយកអត្ថបទទាំងអស់នេះ ហើយយើងខ្ញុំមិន<អាចរក>ឯកសារទាំងអស់ហ្នឹង<ឃើញ>ទេ <តាមរយៈអនឡាននៅ>ពេលឈប់សម្រាកទទួលទានអាហារថ្ងៃត្រង់នោះ។ <ប៉ុន្តែអត្ថបទជាឈុតបន្តបន្ទាប់នេះ អាចនឹងត្រូវ>ពិនិត្យមើល <ដើម្បីឱ្យដឹង>ថាតើមាន<បញ្ហា>ណាផ្សេងទៀតដែល<ត្រូវបានលើកឡើងនៅក្នុងសម្រង់នានា>របស់សម្តេចព្រះ នរោត្តម សីហនុនោះ<ដែររទេ>។ <ខ្ញុំមិនដឹងថាតើខ្ញុំនិយាយនេះច្បាស់លាស់គ្រប់គ្រាន់ឬយ៉ាងណានោះទេ។ នៅពេលព្រះរាជអាជ្ញាផ្តល់>ឯកសារ<>នោះ <យើងឃើញឯកសារ>ដូចជាឧទាហរណ៍ដូចជា លេខរៀងទី៩ លេខរៀងទី៧ ឯកសារលេខរៀងទី១០ ក្នុងចំណោមឯកសារទាំង២៧ហ្នឹង គឺដូចជាមានអត្ថបទផ្សេងៗទៀត ដែល<បញ្ជាក់ថា អាចនឹងមានអត្ថបទមួយទៀតលើ>ប្រធានបទតែមួយ ហើយក៏ប៉ុន្តែសំណុំរឿងហ្នឹងក្នុង*ហ្វាយឡេប*ហ្នឹង ខ្ញុំមិនបានរកមើលឃើញទេ។ <ដូច្នេះនេះជាសំណើសុំបន្ថែម ដែលខ្ញុំសូមលើកឡើង បើសិនជាចាំបាច់។>

[១៤:០០:២៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមិនច្បាស់ថាតើមានសំណើអ្វីខ្លះ<នោះទេ ប្រហែលជាយើងទទួលយកបន្តិចម្តងៗ។ លោកនិយាយថា ក្នុងករណីដែល>អង្គជំនុំជម្រះបានចេញសេចក្តីសម្រេច<ជាក់លាក់ ដូច្នេះប្រហែលជាយើងត្រូវរង់ចាំ>សំណើ<សុំសេចក្តីសម្រេចពីអង្គជំនុំជម្រះហើយ>។ អ៊ីចឹងតើយ៉ាងម៉េចដែរ?

**លោក នីកូឡាស គូមជែន៖**

ប្រហែលជាខ្ញុំអាចជួយបន្តិចបាន តាមការយល់ឃើញរបស់ខ្ញុំ ក្នុងចំណោម -- ប្រសិនបើយើងចូលទៅដល់ ចូលគេហទំព័រវ៉ាស៊ីនតោនប៉ុស្តិ៍ ហើយយើង*ស៊ើច*រកពាក្យហ្នឹងទៅ ប្រហែលជាយើងទទួលបានឯកសារទាំង២៧នេះហើយ។ <ខ្ញុំមិនដឹងថាតើពាក្យថា*ស៊ើច*ហ្នឹងជាអ្វីជាក់លាក់នោះទេ ហើយទាំងអស់នេះគឺជាឯកសារបី ក្នុងចំណោមឯកសារទាំង២៧នោះ។> ឯកសារប្រាំបី ដែលមេធាវីបានស្នើសុំហើយ គឺឯកសារE396/4 ដែលត្រូវបានបដិសេធរួចមកហើយ <ហើយឯកសារនេះក៏កំពុងដាក់ស្នើសុំ

ឡើងវិញផងដែរ>។ ហើយសំណើរបស់យើងបានស្នើ<ឲ្យទទួលយក>នូវ<>ឯកសារ<បី គឺគ្រាន់តែជាការផ្តល់នូវថា ពាក្យស្នើសុំរបស់មេធាវីការពារក្តី ដើម្បី>ឲ្យទទួលយក<ឯកសារចុងក្រោយរបស់ខ្លួនរួមទាំងលិខិតរបស់ព្រះបរមរតនកោដ្ឋនោះ គឺត្រូវបានទទួលយក>។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះនឹងយកបញ្ហានេះ ទៅពិនិត្យពិចារណា ពិភាក្សាសម្រេចក្នុងពេលឆាប់ៗខាងមុខនេះ។

អង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី និងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៤:០២:៤៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការបញ្ជាក់មួយជូនទៅភាគី មុននឹងយើងចាប់ផ្តើមស្តាប់សក្ខីកម្មរបស់សាក្សីនាពេលបន្តិចទៀតនេះ។ អង្គជំនុំជម្រះទើបតែប្រកាសទទួលយកកំណត់ហេតុស្តាប់ចម្លើយ E3/10683 និង E3/10684។ អ្នកដែលត្រូវបានស្តាប់សក្ខីកម្មនៅក្នុងឯកសារនេះ ទទួលបានវិធានការការពារ ដោយសហចៅក្រមស៊ើបអង្កេត។ ដូច្នេះប្រសិនបើភាគីចង់និយាយសំដៅទៅដល់អត្តសញ្ញាណរបស់បុគ្គលរូបនេះ គួរតែប្រើរហស្សនាមរបស់គាត់គឺ 2-TCW-1066។ ហើយប្រសិនបើភាគីចង់អានសម្រង់នៃកំណត់ហេតុស្តាប់ចម្លើយនេះ ភាគីត្រូវតែអានក្នុងសវនាការជាអសាធារណៈ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក ជាល ជឿន៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ ជាល ជឿន។

**ស៖** អរគុណលោក ជាល ជឿន។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** ខ្ញុំនៅកើតនៅថ្ងៃ២៧ ខែសីហា ឆ្នាំ៥២។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**ស៖** អរគុណ។ ហើយលោក ជាល ជឿន មានទីកន្លែងកំណើតនៅកន្លែងណា ស្រុកកំណើតរបស់លោក?

[១៤:០៤:៤៩]

**ឆ៖** ខ្ញុំនៅភូមិប្រាសាទដូនអន ឃុំស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** អរគុណ។ ចុះទីលំនៅសព្វថ្ងៃ តើលោករស់នៅទីកន្លែងណា?

**ឆ៖** បាទ សព្វថ្ងៃខ្ញុំរស់នៅភូមិរបោះរាំង ឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** លោកប្រកបមុខរបរអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** បាទ ខ្ញុំធ្វើស្រែ។

**ស៖** បាទ អរគុណ។ ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះ ជាល, ម្ដាយឈ្មោះ ប៊ិល កេង។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ សុខ សាង មានកូនប្រាំពីរនាក់។

**ស៖** អរគុណលោក ជាល ជឿន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ហើយភាគីទាំងឡាយដែលត្រូវទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើរបាយការណ៍នេះពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិត។

**ស៖** តើលោកបានធ្វើសម្បថរួចហើយឬនៅ មុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** បាទ ខ្ញុំសម្បថរួចហើយ។

[១៤:០៦:៥៥]

**ស៖** តទៅនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិលោក ជាល ជឿន ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោក

អត្ថាធិប្បាយរៀបរាប់ណា ដែលនាំដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សីត្រូវតែផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យការចម្លើយតប ឬសេចក្ដីធ្វើអត្ថាធិប្បាយរបស់លោកនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិអម្បាញ់មិញនេះរួចហើយ។

ហើយក្នុងនាមលោកជាសាក្សី ត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏មានបទពិសោធន៍ផ្ទាល់ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក ជាល ធឿន តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក នេះដែរឬទេ រយៈពេលកន្លងមក? ប្រសិនបើមានធ្វើបានប៉ុន្មានដង?

[១៤:០៨:១៩]

**ធ៖** បាទ បានម្ដង។

**ស៖** អង្កាល់ពីធ្វើនោះធ្វើនៅកន្លែងណាដែរ? លោកមកផ្ដល់សក្ខីកម្មនៅចំពោះមុខអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនៅកន្លែងណាដែរ?

**ធ៖** បាទ ខ្ញុំមកដល់កន្លែងហ្នឹង ប៉ុន្តែខ្ញុំមិនដែលចូលកន្លែងត្រង់ហ្នឹងទេ វានៅកន្លែងចៅក្រមតែម្ដង។

**ស៖** បាទ អរគុណ។ ហើយមុននឹងចូលមកដល់នៅចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្ដល់កិច្ចសម្ភាសន៍កាលពីលើកមុនដើម្បីរំឭកការចងចាំដែរឬទេ?

**ធ៖** បាទ ខ្ញុំបានអានមើលដែរ។

**ស៖** អរគុណ។ តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបាន ថាតើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុដែលលោកស្ដាប់ចម្លើយដែលអាន លោក -- កំណត់ហេតុដែលលោកផ្ដល់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺវាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងខ្លឹម

សារដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីមុននោះដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១៤:០៩:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោក ជាល ជឿន នៅចំពោះមុខសវនាការនាពេលនេះ លោកបានទទួលជំនួយមេធាវីប្រឹក្សាដែលអង្គជំនុំជម្រះបានផ្តល់ឲ្យលោក តាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញតាមសំណើរបស់លោកហើយ គឺលោកស្រីមេធាវី សុក សុជាតា។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីតាំងសំណួរដេញដោលចំពោះសាក្សី។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកនៅថ្ងៃរសៀលនេះ។ លោកសាក្សី លោកអាចជម្រាបអង្គជំនុំជម្រះបានទេ ថាតើក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ តើលោកជាកងទ័ព ឬជាទាហាននៅក្នុងកងទ័ពបដិវត្តន៍កម្ពុជាមែនទេ? លោកជាទាហាន មែនទេ?

**លោក ជាល ជឿន៖**

**ឆ៖** បាទ កាលនោះ ខ្ញុំមិនជាពេញសិទ្ធិជាទាហានអីទេ ព្រោះខ្ញុំបួសតាំងពីឆ្នាំ៧០ រហូតដល់ឆ្នាំ៧៥។

[១៤:១១:២៤]

**ស៖** ខ្ញុំនឹងត្រឡប់មកចំណុចនេះនៅពេលបន្តិចទៀតនេះ ទៅលើអតីតកាលរបស់លោកជាព្រះសង្ឃ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចាប់អារម្មណ៍ថាតើ<លោកពិតជាទាហាន ឬក៏អត់ទេ ហើយថាតើ>ពេលណាដែលលោកក្លាយទៅជាទាហាន? ហើយលោកធ្វើជាទាហានហ្នឹងទៅដល់ឆ្នាំណា? ហើយលោកមានមុខងារអ្វីខ្លះ? មានឋានន្តរសក្តិអ្វីខ្លះក្នុងពេលដែលលោកធ្វើជាទាហានហ្នឹង? ខ្ញុំចង់ដឹងថា សកម្មភាពលោកក្នុងឋានៈលោកជាទាហានហ្នឹង លោកធ្វើអ្វីខ្លះ?

**ឆ៖** អាពេលឆ្នាំ៧៥ ដល់ពេលខ្ញុំសឹកពីបួសទៅ ខ្ញុំរស់នៅក្នុងស្រុកកំណើតខ្ញុំ វាលំបាកពេក ខ្ញុំរត់គេចទៅបាត់ដំបង។ ដល់ពេលទៅដល់នោះ ជួបគេនៅអូរស្រឡៅហ្នឹង គេឲ្យ ខ្ញុំធ្លាប់ស្គាល់គេ គេឲ្យខ្ញុំកាក់ឲ្យខ្ញុំនៅជាមួយគេហ្នឹង កាលហ្នឹងក្រោយសន្តិភាពហើយ។ ដល់ពេលខ្ញុំនៅជាមួយគេហ្នឹងបាន ខ្ញុំមិនដឹងថាគេឲ្យធ្វើអីផង ប៉ុនដល់ទៅនៅជាមួយគេ គេកាក់មិនឲ្យទៅណាអ៊ីចឹងទៅ ក៏គេយកស្នែកឡើង គេយកអាវុធមួយដើមមកឲ្យខ្ញុំកាន់ ហើយនិងទូសៀគ្រាប់ និងមុងនោះមួយ។

**ស៖** ពេលដែលគេប្រគល់អាវុធ ហើយនិងមុង<>ឲ្យលោកហ្នឹង លោកដឹងថាលោក<បានចូលរួម>នៅក្នុងអង្គភាពយោធា មែនទេ? ហើយសិនជាអ៊ីចឹងមែននោះ តើលោកស្ថិតនៅក្នុងអង្គភាពយោធាមួយណា?

**ឆ៖** បាទ ដល់ពេលខ្ញុំនៅហ្នឹងទៅ ខ្ញុំគ្រាន់តែដឹងថានៅក្នុងកង៣៥ វរៈ១៨។

**ស៖** លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថានៅក្នុង<វរសេនាតូច>១៨ហ្នឹងមានមនុស្សប៉ុន្មាននាក់? ហើយ<វរសេនាតូច>១៨ហ្នឹង ស្ថិតនៅចំណុះឲ្យវរសេនាធំណា កងពលណា?

[១៤:១៣:៥៦]

**ឆ៖** អាដល់វរសេនាធំ និងកងពល ខ្ញុំអត់ដឹង ព្រោះខ្ញុំចូលហ្នឹង វារយៈពេលខ្លះដែរ។ ពីមុនមកខ្ញុំមិនដែលនៅជាមួយគេផង ទើបពេលគេកាក់ខ្ញុំឲ្យរស់នៅជាមួយគេហ្នឹង បានដឹងថានៅកងហ្នឹង កង៣៥ហ្នឹង និងវរៈ១៨ហ្នឹង តែដល់វរសេនាធំ កងពលអី ខ្ញុំអត់ដឹង អត់ដឹងថាកងពលលេខប៉ុន្មានអីប៉ុន្មានទេ។

**ស៖** ចុះមេកងអនុសេនាធំលោកនោះឈ្មោះអី? ហើយកង៣៥របស់លោកហ្នឹង ស្ថិតនៅចំណុះឲ្យឃុំ ស្រុក ភូមិភាគ ឬក៏តំបន់?

**ឆ៖** កង៣៥ហ្នឹងចំណុះឲ្យភូមិភាគ។ អនុសេនាធំហ្នឹង ខ្ញុំមិនដឹងជាអនុសេនាធំលេខប៉ុន្មានទេ ខ្ញុំស្គាល់តែថាអនុសេនាធំនោះឈ្មោះ រឿត ខ្ញុំស្គាល់តែប៉ុណ្ណឹង។

**ស៖** លោកថាកងរបស់លោកចំណុះឲ្យភូមិភាគ លោកសំដៅលើភូមិភាគពាយ័ព្យឬ? ហើយម៉េចក៏លោកដឹងថា កងរបស់លោកហ្នឹងចំណុះឲ្យភូមិភាគ?

**ឆ៖** បានខ្ញុំដឹងគេថាទ័ពភាគ ដល់គេថាអ៊ីចឹង ខ្ញុំដឹងថាចំណុះឲ្យភូមិភាគ។

**ស៖** លោកដូចជាទើបតែឆ្លើយថា ប្រធានកងអនុសេនាធំឈ្មោះ <រឿន> ក៏ប៉ុន្តែនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ E3/10681 លោកនិយាយអំពីឈ្មោះ រឿត។ អ៊ីចឹងសូមលោកបញ្ជាក់

ឲ្យបានច្បាស់មើលថា ឈ្មោះមេបញ្ជាការអនុសេនាធំរបស់លោកហ្នឹងឈ្មោះ វឿត ឬក៏ឈ្មោះ <វឿន>?

**ផ៖** បាទ ឈ្មោះ វឿត។

[១៤:១៦:៥៩]

**ស៖** លោកចាំឈ្មោះមេផ្សេងៗរបស់លោកទៀតទេ ក្រៅពីឈ្មោះ វឿត នេះ?

**ផ៖** ខ្ញុំអត់ចាំផង។ ខ្ញុំចាំតែកងអនុសេនាតូចដែលគេកាក់ខ្ញុំឲ្យនៅហ្នឹង ឈ្មោះ ឌឿន។

**ស៖** លោកនៅក្នុងកង៣៥នេះ អស់រយៈពេលប៉ុន្មានដែរ?

**ផ៖** ខ្ញុំនៅរយៈពេលប្រហែលជា១ខែ។

**ស៖** ក្នុងអំឡុងដែលលោកនៅកង៣៥ រយៈពេល១ខែហ្នឹង តើមានហេតុការណ៍អ្វីកើតឡើងខ្លះ?

**ផ៖** បាទ ពេលហ្នឹងគេ ៗប្រាប់ឲ្យទៅការពារទាហាន ទទួលសម្ដេច។

**ស៖** លោកសំដៅទៅហេតុការណ៍ដែលកើតឡើងនៅភ្នំធិបតីមែនទេ?

**ផ៖** បាទ។

**ស៖** ខ្ញុំនឹងត្រលប់មកនិយាយអំពីហេតុការណ៍នៅភ្នំធិបតីនេះនៅពេលក្រោយ។ ឥឡូវនេះខ្ញុំចង់សួរលោកថា អ្នកណាជាអ្នកបញ្ជាលោកឲ្យជូនទាហានទាំងអស់ហ្នឹង? ហើយលោកជួបមេហ្នឹង ជួបអ្នកណាខ្លះ?

**ផ៖** ទេ កាលនុ៎ងកូនទាហានកងទ័ពហ្នឹងគេឈ្មោះ ឌឿន ហ្នឹង គេមេកងហ្នឹងគេប្រាប់ឲ្យរៀបចំទៅការពារ។

**ស៖** នៅកន្លែងនោះតើលោកមានជួបឈ្មោះ សារឿន ហៅ <រ៉េន> ទេ?

**ផ៖** បាទ ពេលនោះខ្ញុំអត់បានឃើញគេទេ បើឮគេឯងផ្សេងទៀតថា តែឲ្យឃើញផ្ទាល់ខ្លួនឯងនឹងភ្នែក អត់។

**ស៖** អ៊ីចឹងពេលដែលលោកនៅកន្លែងនោះ តើលោកស្ដាប់ឮអ្វីខ្លះពាក់ព័ន្ធនឹងឈ្មោះ សារឿន ហៅ <រ៉េន> នេះ?

[១៤:២០:២៧]

**ផ៖** បាទ ពេលនោះ ដល់ពេលទាហានហ្នឹងទៅដល់ ខ្ញុំឮស្គរផ្ទុះអាវុធ ហើយបានឮអ្នកដែលនៅជាមួយនឹងគេថា សារឿន ហៅ រ៉េន ហ្នឹងបាញ់ពីក្រោយមកហើយ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីរឿងហ្នឹងនៅពេលក្រោយ។ អ៊ីចឹងពេលនេះខ្ញុំចង់ដឹងថា តើ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

សារឿន ហៅ រ៉េន ហ្នឹង គាត់មានមុខងារអ្វី? លោកដឹងពីឋានៈគាត់ទេ ឋានន្តរសក្តិគាត់? ក្នុងកំណត់ហេតុរបស់លោកហ្នឹង លោកថាគាត់ជាមេបញ្ជាការកងពល លោកអាចបញ្ជាក់មុខងាររបស់គាត់ម្តងទៀតបានទេ គាត់ធ្វើអ្វីដែរ?

**ឆ៖** បាទ ពេលនោះ ខ្ញុំឮសួរកងទ័ពទាំងអស់ដែលនៅក្នុងហ្នឹង គេថាគាត់ហ្នឹងកងពល។

**ស៖** លោកដឹងថា គាត់មេបញ្ជាការកងពលលេខប៉ុន្មានទេ? ហើយគាត់ជាមេផ្ទាល់តែម្តង ឬក៏មានភូមិភាគ ឬក៏ -- មានតំបន់ ឬភូមិភាគដែលជាមេបន្តពីលើគាត់ទៀត?

**ឆ៖** អាត្រង់ហ្នឹងខ្ញុំអត់ដឹងដែរ មិនដឹងជាមានពីលើគាត់ទៀត អីក៏អីអាម៉េច អាហ្នឹងខ្ញុំអត់ដឹង។

**ស៖** លោកដឹងថា សារឿន នេះ គាត់នៅរស់ទេសព្វថ្ងៃហ្នឹង?

**ឆ៖** ទេ កាលពីសម័យ៣ឆ្នាំហ្នឹង ខ្ញុំឮតែគេឯងនិយាយថា គេយកគាត់ទៅបាត់ហើយ មិនដឹងយកទៅណាផង។

**ស៖** តើលោកមានព័ត៌មានច្រើនទេ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធានៅក្នុងភូមិភាគពាយ័ព្យ? ឧទាហរណ៍ដូចជា លោកដឹងទេថានៅភូមិភាគពាយ័ព្យមានកងពលធំប៉ុន្មាន? មានវរសេនាធំប៉ុន្មានដែលឈរជើងនៅទីនោះនោះ?

**ឆ៖** បាទ ខ្ញុំអត់ដឹងនោះ ព្រោះ--

[១៤:២៣:២៥]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់! កុំទាល់ទាន់!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។ ដើម្បីប្រតិចារិក ខ្ញុំយល់ឃើញថាវាចាំបាច់ណាស់ដែលយើងខ្ញុំជំទាស់ទៅនឹងសំណួរដែលសួរដោយលោកចៅក្រម ឡាវ៉ែន៍។ អនុញ្ញាតឲ្យខ្ញុំពន្យល់ចំពោះការជំទាស់នេះ យើងខ្ញុំជំទាស់ ដោយសារតែហេតុផល ថានឹងអាចមានការប្តឹងសាទុក្ខនៅក្នុងសំណុំរឿង០០ -- ជំទាស់ទៅនឹងសំណុំរឿង០២/០២នេះក្នុងករណីនេះ។ <មូលហេតុគឺមានដូចតទៅ> រយៈពេលមួយខែគិតពីពេលនេះទៅ គឺអង្គជំនុំជម្រះតុលាការនឹងចេញសាលដីកាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ។ ហើយយើងទាំងអស់គ្នាដឹងហើយថា ទួលពោធិ៍ជ្រៃជាបញ្ហាស្នូលនៅក្នុងសំណុំរឿង

០២/០១។ <ទួលពោធិ៍ជ្រៃ គឺត្រូវបានលើកឡើង>នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ<របស់គាត់> នៅក្នុងសំណុំរឿង០២/០១ យើងនិយាយពីទួលពោធិ៍ជ្រៃ ហើយក៏និយាយអំពីរចនាសម្ព័ន្ធបញ្ជានៅភូមិភាគពាយ័ព្យនាពេលនោះផងដែរ។ ឥឡូវនេះ បើសិនណាជាយើងបន្តធ្វើតាមទិសដៅនេះទៀត ប្រហែលជាយើងត្រូវពន្យារពេលកាត់សំណុំរឿង០២/០១ ឡើងវិញ។

[១៤:២៥:១៦]

ខ្ញុំក៏សូមរំឭកដល់អង្គជំនុំជម្រះផងដែរថា ការជំទាស់ដែលយើងខ្ញុំលើក -- ដោយមេធាវីការពារក្តីក្នុង<ពេលសវនាការ> នៅថ្ងៃទី០២ និងទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦នេះ គឺយើងខ្ញុំបានសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយដែលនៅពេលនោះ លោកប្រធាននៅថ្ងៃទី០៣ ខែកុម្ភៈ នៅប្រហែលជាម៉ោង១០:៥៦នាទី បាន<ប្រាប់>ទៅសហមេធាវីនាំមុខ<ថា "មេធាវីនាំមុខ ជាការពិត>សំណួរ<របស់លោក លោកស្រី អាចពាក់ព័ន្ធនឹង>វិសាលភាពសំណុំរឿង ០២/០១ ដែលបានបញ្ចប់រួចទៅហើយ។" នៅទីនេះយើងមានវិសាលភាពខុសគ្នា<ចំពោះ>សំណុំរឿង ០២/០២<ដែលកំពុងតែដំណើរការនេះ ហើយវាអាចជាការចំណាយពេលឥតប្រយោជន៍។ មានតែសំណួរមួយចំនួនតូចប៉ុណ្ណោះ ដែលយើង>អនុញ្ញាតឲ្យសួរ<ពាក់ព័ន្ធទៅនឹង>វិសាលភាព <ហើយដូចលោក លោកស្រីបានសង្កេតមកហើយ គឺមាន>ការជំទាស់<ជាច្រើន>ពីភាគីដទៃទៀត ឬពីអង្គជំនុំជម្រះ ទាក់ទងទៅនឹងសំណួរដែលស្ថិតនៅខាងក្រៅវិសាលភាពសំណុំរឿង០២/០២។ <នោះគឺលោកប្រធាន។> ការជំទាស់ពីខាងដើម ពីសំណាក់សហព្រះរាជអាជ្ញានៅថ្ងៃទី០២ ខែកុម្ភៈ ហើយចៅក្រមហ្វេនស៍ ក៏បាន<>រំឭកមកដល់ខ្ញុំថា <"លោកមេធាវី ខ្ញុំគិតថា>ភាពច្របូកច្របល់ គឺ<ដោយសារ> បើសិនណាជា<លោកបន្តសំណួរ>អំពីការជម្លៀសប្រជាជនស៊ីវិល គឺថាវានៅក្រៅវិសាលភាពហើយ។"

ដូច្នេះ ចម្លើយហ្នឹងគួរតែនិយាយអំពីការធ្វើបាបទៅដល់ទាហានលន់នល់ ការប្រព្រឹត្តមកលើទាហានលន់នល់ គោលនយោបាយពាក់ព័ន្ធទៅលើទាហានលន់នល់ នេះ<បើយោងតាមការពិភាក្សាប៉ុន្តែវា>ជាសេចក្តីសម្រេចកន្លងមករបស់អង្គជំនុំជម្រះ។ ឥឡូវនេះយើងជិតមកដល់ការអនុវត្តនូវបទដ្ឋានមួយនេះហើយគឺ ដែលស្ថិតនៅក្រោមសាលដីការបស់តុលាការកំពូល។ <ដូច្នេះ វាមិនមែនដោយសារថា>យើងប្រហែលជាមាននិយាយអំពីទួលពោធិ៍ជ្រៃ <វាជា>អ្វី<ដែលបាន>កើតឡើង<យ៉ាងពិតប្រាកដ>នៅ<ខែ> មេសា ៧៥ នៅភូមិភាគពាយ័ព្យ។ តើ<អ្វីជា>រចនាសម្ព័ន្ធបញ្ជា<របស់>វា <តើវាជាកម្មវត្ថុនៃសាលដីកាលើបណ្តឹងសាទុក្ខឬទេ>។

អ៊ីចឹង<នៅពេលនេះ ការព្យាយាមធ្វើបែបនេះ>នៅក្នុងបន្ទប់សវនាការនេះ<គឺជាអ្វីដែលយើងចាំបាច់ត្រូវតែជំទាស់ ដើម្បីមូលហេតុធ្វើបណ្តឹងសាទុក្ខនៅពេលក្រោយ>។ ទោះបីសាក្សីរូបនេះ ផ្តល់សក្ខីកម្មអំពីជោគវាសនារបស់ទាហានលន់ នល់ ក៏ដោយ មិនចាំបាច់ថា តែទួលពោធិ៍ជ្រៃទេ គឺថាវាជាប់ទាក់ទងគ្នាយ៉ាងជិតដិតបំផុតនូវអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានវិនិច្ឆ័យសេចក្តីរួចទៅហើយនៅក្នុងសំណុំរឿង០២/០១។ ហេតុដូច្នេះឯង សំណួរបែបនេះ គឺថាមិនត្រូវអនុញ្ញាតឲ្យសួរទេ យើងខ្ញុំសូមជំទាស់។

[១៤:២៨:៤២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមការបញ្ជាក់។ តើសំណួរដែលខ្ញុំសួរហ្នឹង គឺមានកើតពាក់ព័ន្ធនឹងហេតុការណ៍នៅទួលពោធិ៍ជ្រៃ ឬក៏អត់? អត់ទេ។ ខ្ញុំអត់បានសួរសំណួរពាក់ព័ន្ធនឹងទួលពោធិជ្រៃទេ។ ហើយខ្ញុំសួរពាក់ព័ន្ធនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញទេ? អត់ទេ។ លើកលែងតែលោកស្តាប់ឮផ្សេងមិនដឹងទេ។ ខ្ញុំអត់បានសួរអ៊ីចឹងទេ។ ខ្ញុំសួរទៅសាក្សីរូបនេះ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធាដែលមាននៅភូមិភាគពាយ័ព្យ នៅពេលដែលគាត់ធ្វើជាទាហាន។ អ៊ីចឹងខ្ញុំមិនយល់ពីការជំទាស់របស់លោកមេធាវីទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកចៅក្រមបានសួរសំណួរដែលឈានទៅដល់ព្រឹត្តិការណ៍ វាហាក់ដូចទួលពោធិ៍ជ្រៃទៅហើយ។ អ៊ីចឹងហើយបានជាមានវត្តមានសាក្សីនៅទីនេះ។ ដូច្នេះ<គាត់អាចបន្ថែម>ភស្តុតាង<ថ្មី> ថាតើមានអ្វីកើតឡើងក្រោយថ្ងៃរំដោះនោះ នៅឯភូមិភាគពាយ័ព្យ។ <ហើយលោកអាចពិនិត្យមើលវាក្នុងរូបភាពចង្អៀត> ខ្ញុំមិននិយាយអំពីទួលពោធិ៍ជ្រៃឲ្យចំតែម្តងទេ។ អ៊ីចឹង គួរតែយល់ឃើញថា នៅក្នុងលក្ខណៈមួយទូលំទូលាយ មិនត្រឹមតែទួលពោធិ៍ជ្រៃទេ <ឬក៏អ្វីដែលគាត់នឹងផ្តល់សក្ខីកម្មនោះ>គឺវាមានទាំងពីរចនាសម្ព័ន្ធនៅភូមិភាគពាយ័ព្យ ថាតើភូមិភាគពាយ័ព្យនេះ ជាប់ពាក់ព័ន្ធទៅនឹងមជ្ឈិមបក្សដោយរបៀបណា។ ហើយអ៊ីចឹងឯង គឺចំណុចនេះ ដែលតុលាការកំពូលនឹងចេញសេចក្តីមួយខែទៀតនេះ។

[១៤:៣០:១១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើអ្វីដែលកំពុងនិយាយគ្នានៅពេលនេះ វាប៉ះពាល់ទៅដល់សាលដីកាតុលាការកំពូលដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ត្រឹមត្រូវហើយ ពិតហើយមានការប៉ះពាល់។ ខ្ញុំសូមរំឭកដល់អង្គជំនុំជម្រះថា ចៅក្រម មីឡាត បានសួរទៅលោក <ទាត់>នូវសំណួរមួយចំនួន<អំពី>ព្រឹត្តិការណ៍ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទួលពោធិ៍ជ្រៃ។ អ៊ីចឹងរចនាសម្ព័ន្ធបញ្ហាព្រឹត្តិការណ៍ទួលពោធិ៍ជ្រៃ រចនាសម្ព័ន្ធបញ្ហានៅភូមិភាគ<ពាយ័ព្យ គឺជាអ្វីដែលយើងកំពុងធ្វើមុនការធ្វើសេចក្ដីសម្រេចលើរឿងនេះ>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ្វីដែលលោកនិយាយ គឺលោកជំទាស់ទៅនឹងការសួរសំណួរនៅក្នុងសវនាការមួយ ដោយសារវាអាចប៉ះពាល់ទៅដល់សាល<បណ្ដឹងសាទុក្ខដែលមិនទាន់បានសម្រេច> អ៊ីចឹងមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

វាស្ថិតក្រៅវិសាលភាព ហើយយើងបាន<>ព្យាយាម <បញ្ហានេះ នូវ>អ្វីដែលកើតឡើងនៅភូមិភាគពាយ័ព្យនោះ គឺ<ជាកម្មវត្ថុនៃសំណុំរឿង០០២/០១>។ អ៊ីចឹងហើយបានជាខ្ញុំ<យោងទៅលើព្រឹត្តិការណ៍ពីខាងដើម ក្នុងការផ្ដល់សក្ខីកម្មរបស់> មាស សារឿន ដែលបានពិភាក្សា<ព្រឹត្តិការណ៍ប្រហាក់ប្រហែលគ្នានេះ ប៉ុន្តែបន្ទាប់មក>ពាក់ព័ន្ធទៅដល់នឹងការជម្លៀស <ហើយនិងអ្វីដែលបានកើតឡើងចំពោះ>ជនស៊ីវិល<ក្នុងពេលជម្លៀស>នោះផងដែរ។

[១៤:៣១:៣៨]

**លោក នីកូឡាស គូមជែន៖**

ឆ្លើយតបទៅនឹងមេធាវីការពារក្ដី ដែលថាហេតុផលដែលសាក្សីនេះមានវត្តមាននៅទីនេះ គឺដោយសារតែការសម្លាប់រង្គាលដែលគាត់នឹងលើកឡើង ពាក់ព័ន្ធទៅនឹងទាហានលន់នល់។ គាត់មានវត្តមាននៅទីនេះ ដោយសារមេធាវីការពារក្ដី នួន ជា បានស្នើសុំឲ្យគាត់មានវត្តមាននៅទីនេះ <ហើយទើបតែដកសំណើ>សុំកាលពីថ្ងៃចន្ទ។ សាក្សីនិយាយពីចំណុចពីរបី។ <ទី១ ដូច>មេធាវីការពារក្ដីទទួលស្គាល់ហើយ ភស្តុតាងនោះ ពាក់ព័ន្ធទៅនឹងគោលនយោបាយ កំណត់គោលដៅទៅលើទាហានលន់នល់ គឺវាស្ថិតនៅក្នុងវិសាលភាពសំណុំរឿង០២/០២។ គាត់ក៏និយាយអំពីបទបញ្ជាក្នុងការរៀបការ ហើយគាត់ក៏និយាយអំពីការធ្វើទុក្ខបុកម្នេញមកលើព្រះពុទ្ធសាសនាផងដែរ។ អ៊ីចឹងវាមានការពាក់ព័ន្ធគ្នាហើយ។

កំណត់ហេតុស្ដាប់ចម្លើយ គឺប្រាកដណាស់ថា សាក្សីបានប្រាប់ថា គាត់មិនមានវត្តមាននៅទួលពោធិ៍ជ្រៃទេ។ ខ្ញុំសូមសន្យាថា សហព្រះរាជអាជ្ញាមិនទទួលយកសាក្សីនេះ សួរពាក់ព័ន្ធទៅនឹងអ្វីដែលប្ដឹងសាទុក្ខនៅក្នុងសំណុំរឿង០០២/០២នោះទេ ដែលនឹងត្រូវចេញមួយខែខាងមុខទៀតនេះ។ យើងនឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនមានធ្វើអ្វីឲ្យមានការប៉ះពាល់ ឬក៏ខូចខាតព្យសនកម្មអ្វីដល់មេធាវីការពារក្តីទេ។ <ហើយការជាប់ពាក់ព័ន្ធដែលចៅក្រមនឹងទទួលឥទ្ធិពលពីសក្ខីកម្មនោះ មិនមែនជាផ្នែកនៃប្រតិចារឹកទេ> មេធាវីការពារក្តីលើកតែសក្ខីកម្មរបស់សាក្សីរូបនេះ <ដែល>មានប្តឹងសាទុក្ខ<>។ ប៉ុន្តែវាថា វាមាននៅក្នុងផ្នែកមួយនៃ<កំណត់ត្រាបណ្តឹងសាទុក្ខ។ ភស្តុតាងក្នុង>សំណុំរឿង០០២/០២ មិនពាក់ព័ន្ធទៅនឹង<កំណត់ត្រាបណ្តឹងសាទុក្ខ>នោះទេ។ <ហើយគ្មានហេតុផលដែលត្រូវជឿថា> ចៅក្រមនៅតុលាការកំពូល<នឹងពិចារណាទៅលើភស្តុតាងដែលនៅក្រៅកំណត់ត្រានោះទេ ដែលច្បាស់ណាស់ថាមិនសមរម្យឲ្យពួកគាត់ធ្វើដូច្នោះទេ>។

[១៤:៣៣:៣៨]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមឆ្លើយតបខ្លីទេ។ <គេ>បានផ្តល់កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីរូបនេះ<ទៅដល់តុលាការកំពូលហើយ> ដោយសារថា កាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាដែលត្រូវបង្ហាញជូនទៅតុលាការកំពូល។ ដូច្នេះនៅក្រោមកាតព្វកិច្ចដូចគ្នានេះ <លោកអាចសន្យាអ្វីក៏បានដែរ តាមដែលលោកចង់ ប៉ុន្តែ>គឺថាលោកត្រូវតែផ្តល់ទៅជូនទៅតុលាការកំពូលនូវបញ្ហាទាំងអស់នេះ។

**លោក នីកូឡាស គូមជែន៖**

<>ខ្ញុំអាចយល់ច្រឡំ <ប្រហែលមេធាវីការពារក្តីអាចប្រាប់ខ្ញុំបានថា នៅពេលណាដែលយើងបានធ្វើដូច្នោះ> ពីព្រោះដូចថា វាមិនបានបំពេញលក្ខណៈវិនិច្ឆ័យឲ្យបានគ្រប់គ្រាន់ទេ តាមខ្ញុំយល់។ <ខ្ញុំពិតជាមិនបានស្បថ ឬសន្យាធ្វើដូច្នោះទេ។> ប្រហែលជាមេធាវីការពារក្តី<បានសន្យាធ្វើដូច្នោះ ប៉ុន្តែវា>មិនបានបំពេញលក្ខខណ្ឌនៅក្នុងការបង្ហាញឯកសារ ដូចការបង្គាប់របស់តុលាការកំពូលនោះទេ <>។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំធ្វើការកត់សម្គាល់ខ្លីមួយ។ ខ្ញុំមិនយល់អំពីការជំទាស់របស់មេធាវី កូប៉េ នោះទេ ប៉ុន្តែខ្ញុំសូមរំឭក ព្រោះវាជាការមើលឃើញច្បាស់ទាំងអស់គ្នាហើយ គឺថាការបណ្តឹងសាទុក្ខនៅតុលាការកំពូលនោះ វាបិទហើយ។ អ៊ីចឹងម៉េចក៏គាត់ជំទាស់អី ខ្ញុំអត់យល់ទាល់តែសោះ អំពីការជំទាស់របស់គាត់នេះ។

[១៤:៣៥:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៦:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធចោលនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា គឺលោកមេធាវី វ៉ិចទ័រ កូប៉េ ដោយសេចក្ដីជំទាស់នេះ គឺមិនមានមូលហេតុ មានសុពលភាពតាមផ្លូវច្បាប់នោះទេ។ លោកចៅក្រម ហ្សង់ម៉ាក បន្តសំណួរតទៅទៀត។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមបំភ្លឺបន្តិច ខ្ញុំ<មិនច្បាស់ថា>ការបកប្រែជាភាសាបារាំងហ្នឹងច្បាស់<លាស់ទេ> គឺថាការជំទាស់របស់លោកមេធាវី កូប៉េ ហ្នឹងមិនមានមូលដ្ឋានច្បាស់លាស់ទេ<សម្រាប់ហេតុផលនេះ។> អ៊ីចឹងហើយអង្គជំនុំជម្រះបដិសេធចោលការជំទាស់នេះ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី ខ្ញុំអានកំណត់ហេតុនៃ<កំណត់ហេតុ>ទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ គឺឯកសារ E3/216 ហើយចុះថ្ងៃទី២០ដល់២៤ សីហា ឆ្នាំ១៩៧៥។ ERN ពាក់ព័ន្ធមានដូចតទៅ ជាភាសាបារាំងគឺ 00343375, ជាភាសាខ្មែរគឺ 00008486, ជាភាសាអង់គ្លេសគឺ 00850974។ មានសរសេរដូចតទៅនេះ៖ “កងទ័ពភូមិភាគបែងចែកចេញជាកងពលតូចពីរ កងពលតូចមួយនៅព្រំដែន ហើយមួយទៀតនៅស៊ីសុផុន មួយទៀតនៅខាងក្រោយ។ នៅក្នុងកងពលតូចនុ៎ងមានកងវរសេនាតូច១០ ហើយកងវរសេនាតូចមួយហ្នឹងមានទាហាន៣៥០នាក់។ នៅតំបន់ជិតព្រំដែនមាន ត-១, ត-៣, ត-៥ មានរៀបចំឲ្យមានវរសេនាតូចពីរ <មានមនុស្សពី>៥០០ ទៅ៦០០នាក់នៅក្នុងវរសេនាតូច នៅក្នុងស្រុកមួយ (ជាភាសាបារាំងខ្ញុំអានអត់ដាច់) ជាភាសាអង់គ្លេសគេសរសេរ មានកងវរសេនាធំមួយ -- អនុសេនាធំមួយ<ក្នុងមួយស្រុក ខណៈដែលតំបន់នៅខាងក្នុងមាន> កងវរសេនាតូចមួយ។” អ៊ីចឹងអ្វីដែលខ្ញុំអានជូនលោកស្ដាប់នេះ តើវាត្រូវគ្នានឹងអ្វីដែលលោកបានឃើញ ដែលលោកបានដឹង ទាក់ទងទៅនឹងរចនាសម្ព័ន្ធយោធានៅភូមិភាគពាយ័ព្យនុ៎ងដែរឬទេ?

**លោក ជាល ជឿន៖**

**ឆ៖** អាកន្លែងហ្នឹង ខ្ញុំមិនអាចដឹងដល់ប៉ុណ្ណឹង ព្រោះខ្ញុំវា ពេលគេហៅចូលហ្នឹង វារយៈពេលខ្លីពេក ប្រហែលជា១ខែ គេឲ្យទៅធ្វើកម្មកររទេះភ្លើងទៅ។

[១៤:៣៩:៤៧]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** យើងនឹងត្រឡប់មកនិយាយអំពីភារកិច្ចរបស់លោកនៅខាងផ្លូវដែកហ្នឹង។ អ៊ីចឹងលោកបាននិយាយថា លោកទៅធ្វើក្រោមចំណុះភូមិភាគ។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកស្គាល់មេដឹកនាំនៅភូមិភាគពាយ័ព្យហ្នឹងដែរឬទេ?

**ផៈ** បាទ មេដឹកនាំនៅភូមិភាគហ្នឹង ខ្ញុំស្គាល់តែឈ្មោះ រស់ ញឹម មិនដែលបានជួបមុខ ជួបមាត់គាត់ផង ឮតែឈ្មោះ។

**សៈ** តើមុខតំណែងលោកដែលខ្ពស់ជាងនៅក្នុងកងទ័ពហ្នឹងជាមុខតំណែងអីដែរ? ដូចជាលោកជាប្រធានអនុសេនាតូច ឬក៏ប្រធានអង្គភាពណាមួយដែលខ្ពស់ជាងហ្នឹងទៀតនោះ មុខតំណែងខ្ពស់ជាងគេរបស់លោក ស័ក្តិប៉ុន្មានដែរលោក?

**ផៈ** ខ្ញុំអត់យល់ ដឹងសួរពីខ្ញុំ ឬក៏សួរពីអ្នកណា ត្រង់ហ្នឹង។

**សៈ** លោកសាក្សី ខ្ញុំនិយាយពីលោកហ្នឹងហើយ។ តើលោកគ្រាន់តែជាកូនទាហានកំប៉ិកកំប៉ុកទេ ឬក៏លោកមានឋានន្តរសក្តិអីដែរនៅក្នុងកងទ័ពហ្នឹង? អ៊ីចឹងបើសិនជាលោកមានឋានន្តរសក្តិហ្នឹង លោកមានឋានន្តរសក្តិអីដែរ ដែលវាខ្ពស់ជាងគេនោះ កាលនៅសម័យនោះ?

**ផៈ** បាទខ្ញុំគ្រាន់តែជាកូនទាហានកំប៉ិកកំប៉ុកហ្នឹង មិនដែលបានទទួលតំណែងអីផង ព្រោះរយៈពេលមួយខែ គេមិនដែលឲ្យយើងធ្វើមេគេទេ។

[១៤:៤២:០៦]

**សៈ** លោកបាននិយាយថា លោកមិនដែលឃើញ រស់ ញឹម ទេ<> ក៏ប៉ុន្តែ<តើ>លោក<ធ្លាប់>បានទទួលបញ្ជាពីគាត់ដែរ<>ទេ?

**ផៈ** ខ្ញុំមិនដែលបានទទួលបញ្ជាអីពីគាត់ផង។ គ្រាន់តែនៅក្រោមការគ្រប់គ្រងរបស់គេនៅក្នុងភូមិភាគពាយ័ព្យហ្នឹង។

**សៈ** នៅក្នុងការងាររបស់លោកជាយោធាហ្នឹង តើលោកធ្លាប់ចូលរួមដឹកជញ្ជូនអាវុធ ឬគ្រឿងរំសេវដើម្បីទៅទុកក្នុងឃ្លាំងដែរឬទេ?

**ផៈ** បាទ ខ្ញុំអត់ដែលផង។

**សៈ** ក៏ប៉ុន្តែលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺឯកសារ E3/10681 លោកនិយាយថា នៅពេលដែលលោកធ្វើការនៅខាងផ្លូវរទេះភ្លើង លោកនិយាយថា កាលណោះលោកនៅជាយោធានៅឡើយទេ នៅចម្លើយ៧៦។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ "<នៅទីនោះ ខ្ញុំនៅតែ

ជាទាហាន។> ក្រោយពីខ្ញុំទៅដល់<ស្ថានីយផ្លូវ>រទេះភ្លើងបាន១ខែ គេឲ្យខ្ញុំយកកាំភ្លើងទៅដាក់ក្នុងឃ្លាំង។ សំណួរ៖ តើពេលណាគេចាត់តាំងឲ្យលោក យកអាវុធទៅដាក់នៅក្នុងឃ្លាំង? នៅពេលហ្នឹងតើលោកនៅទទួលបញ្ជាពីខាងយោធាមកដដែលឬ? ឆ្លើយ៖ អត់ទេ ខ្ញុំមិនមានសិទ្ធិទទួលបញ្ជាពីអ្នកណាម្នាក់ទេ។” តើចម្លើយទាំងអស់ហ្នឹងធ្វើឲ្យលោកនឹកឃើញទេ? ហើយបើនឹកឃើញនោះ តើលោកអាចបញ្ជាក់អំពីអ្វីដែលលោកឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយលោកហ្នឹងបានទេ ត្រង់ចំណុចហ្នឹង?

[១៤:៤៥:០២]

**ឆ៖** បាទ ពេលខ្ញុំទៅដល់ គេដកទុកកម្មកររទេះភ្លើងហ្នឹង ទៅដល់ហ្នឹងគេអ្នកគ្រប់គ្រងនៅផ្ទាល់នឹងកន្លែងហ្នឹង គេឲ្យយកអាវុធទៅដាក់ឃ្លាំង ប៉ុន្តែមិនមែនយកទៅដល់ឃ្លាំងទេ គ្រាន់អាវុធហ្នឹងយកទៅប្រគល់ឲ្យគេនៅនឹងកន្លែងហ្នឹង ហើយមិនដឹងជាគេយកទៅទុកឯណា ដាក់ឯណាអាហ្នឹងខ្ញុំអត់ដឹង។ គ្រាន់តែយកតែពីខ្លួនឯងទៅឲ្យគេកន្លែងផ្ទះគេហ្នឹងទៅ គេប្រមូលយកទៅណាទៅណីទៀត អាហ្នឹងខ្ញុំអត់ដែលបានដឹងទេ។

**ស៖** ហើយជាក់លាក់តែម្តងហ្នឹង លោកបានដឹកអាវុធទាំងអស់ហ្នឹងពីណាដល់ណាដែរ? បើសិនជាខ្ញុំយល់មិនច្រឡំទេ តើកាលហ្នឹងគឺលោកបានធ្វើនៅឆ្នាំ១៩៧៥ មែនទេ?

**ឆ៖** បាទ ទេអាវុធហ្នឹង គ្រាន់តែយកតែពីផ្ទះរបស់ខ្លួនទៅដាក់នៅផ្ទះ ឈ្មោះ ភាព ហ្នឹងយកទៅដាក់នៅត្រឹមផ្ទះគេហ្នឹង ហើយត្រង់គេយកទៅណាទៀតខ្ញុំអត់ដឹង។ ព្រោះគេប្រាប់ឲ្យប្រមូលយកទៅដាក់ត្រឹមហ្នឹង។ ហើយខ្ញុំហ្នឹងក៏យកអាវុធដែលកាន់ខ្លួនឯងទៅដាក់ឲ្យគេហ្នឹងទាំងអស់ ប្រគល់ឲ្យគេទៅនៅតែខ្លួនទៅ។

**ស៖** ហើយ ភាព ហ្នឹងអ្នកណា ជាអ្នកណាដែរ? ខ្ញុំសួរលោកថា ភាព ហ្នឹងជាអ្នកណាដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីឮទេ? ឮៗទេ? បញ្ហាអស់ថ្មទេដឹង?

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី លោកស្តាប់ខ្ញុំឮទេ?

**លោក ជាល ជឿន៖**

**ឆ៖** ឮហើយ។

[១៤:៤៨:៣០]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** បាទ អម្បាញ់មិញនោះលោកបាននិយាយអំពីមនុស្សម្នាក់ឈ្មោះ ភាព។ អ៊ីចឹងខ្ញុំសួរលោកថាតើ ភាព ហ្នឹងជាអ្នកណា? ហើយលោកយកអាវុធពីណា? ហើយដឹកទៅណាដែរ នៅបាត់ដំបង ឬក៏នៅកន្លែងណាផ្សេង?

**ឆ៖** ពេលដែលគេបញ្ជូនខ្ញុំឱ្យទៅកម្មកររទេះភ្លើងហ្នឹង ភាព ហ្នឹងគាត់ទទួលខុសត្រូវ ហើយដល់ពេលគាត់ប្រាប់ឱ្យប្រមូលអាវុធដាក់ឃ្លាំង ហើយដល់អ៊ីចឹងអ្នកដែលមានអាវុធហ្នឹង គឺប្រមូលយកទៅឱ្យគាត់ទាំងអស់ នៅផ្ទះគាត់ហ្នឹង ជិតគ្នា នៅហ្នឹងរ៉ារទេះភ្លើង។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី និងប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី និងប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៩ នាទី ដល់ម៉ោង ១៥:០៨ នាទី)*

[១៥:០៨:០១]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ សូមអរគុណលោកប្រធាន។ លោកសាក្សី លោកទើបតែនឹងនិយាយប្រាប់ខ្ញុំ

អម្បាញ់មិញថាឈ្មោះ ភាព នោះបានបញ្ជាឱ្យលោកទៅ<រកមើល>អាវុធ និងគ្រាប់រំសេវផ្សេងៗយកទៅដាក់នៅក្នុងឃ្លាំងមួយ។ បើខ្ញុំយល់មិនច្រឡំទេគឺថា ភាព ជាអ្នកទទួលខុសត្រូវខាងផ្លូវរទេះភ្លើងដែលលោកធ្វើការនៅទីនោះ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើគេដឹកអាវុធ និងគ្រឿងរំសេវទាំងអស់នោះទៅណាដែរ ទៅណា ហើយក្នុងបំណងអ្វីដែរ?

**លោក ជាល ជឿន៖**

**ឆ៖** បាទ ពេលនោះខ្ញុំអត់ដឹងគេយកអាវុធហ្នឹងទៅណាផង ហើយក៏អត់ដឹងគោលបំណងគេយ៉ាងម៉េចដែរ ព្រោះគេគ្រាន់តែប្រាប់ថាយើងធ្វើកម្មករអត់មានអាវុធមានអីទេ ព្រោះយើងចូលជាកម្មករហើយ មិនមែនជាយោធាទៀតទេ។ ហ្នឹងគេគ្រាន់តែប្រាប់ប៉ុណ្ណឹង។

[១៥:១០:០៦]

**ស៖** អ៊ីចឹងអាវុធទាំងអស់ហ្នឹង គឺជាអាវុធដែលយោធាគេកាន់ ហើយក្រោយមក គេដកអាវុធចេញពីយោធាទាំងអស់ហ្នឹង ដោយសារគេឱ្យយោធាហ្នឹងទៅធ្វើការងារខាងស៊ីវិលវិញ។ អ៊ីចឹងដោយសារការងារថ្មីហ្នឹងជាការងារស៊ីវិល អ៊ីចឹងគេអត់ឱ្យ គេមិនតម្រូវឱ្យមានអាវុធ ឱ្យគាត់កាន់អាវុធទៀតទេ។ តើអាវុធហ្នឹង គេដកចេញពីអតីតយោធា ឬក៏យ៉ាងម៉េច?

**ឆ៖** អាវុធហ្នឹង គេដកតែពីអតីតយោធាដែលគេបញ្ជូនទៅឱ្យធ្វើកម្មករហ្នឹង។

**ស៖** បាទ សូមអរគុណ។ នៅពេលណាមួយនោះ នៅពេលដែលលោកជាយោធា ហើយនិងពេលដែលលោកធ្វើការនៅខាងផ្លូវរទេះភ្លើង <ឬក៏នៅពេលក្រោយមកទៀត> តើលោកមានបានធ្លាប់ឮអំពីផែនការបះបោរដែរឬទេ ដែលមានកម្មាភិបាលនៅភូមិភាគពាយ័ព្យមួយចំនួនហ្នឹង គឺគាត់ចង់បះបោរប្រឆាំងនឹងមជ្ឈិម តើលោកធ្លាប់ឮផែនការហ្នឹងទេ?

**ឆ៖** បាទ ផែនការហ្នឹង ខ្ញុំមិនដែលបានឮទេ ប៉ុន្តែគ្រាន់តែអ្នកទទួលខុសត្រូវនៅកន្លែងកម្មកររទេះភ្លើង គេឱ្យកម្មករហ្នឹង មិនថា១៧ មិនថាមូលដ្ឋានអីទេ គេឱ្យៗតែកម្មករ ទាំងចាស់ទាំងថ្មីហ្នឹង គេឱ្យហាត់បច្ចេកទេសសង្គ្រាមនៅតាមអង្គភាពរៀងៗខ្លួន បំបែកជាក្រុមៗ ហើយមិនឱ្យអង្គភាពដទៃឃើញ អាហ្នឹងខ្ញុំដឹង។

**ស៖** អ៊ីចឹងលោកបានទទួលការបណ្តុះបណ្តាលផ្នែកយោធា តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ លោកបានទទួលការបណ្តុះបណ្តាលហ្នឹងនៅពេលណា? ហើយគេបណ្តុះបណ្តាលពួកលោកទាំងអស់ហ្នឹងក្នុងបំណងអ្វី? ក្នុងបំណងការពារប្រទេស ឬក៏ដើម្បីបុព្វហេតុអីផ្សេងពីហ្នឹង?

[១៥:១២:៥០]

**ឆ៖** បាទ ពេលហ្នឹងគេអត់មានប្រាប់ថា ពីបុព្វហេតុអីមួយឲ្យច្បាស់លាស់ផង ប៉ុន្តែគ្រាន់តែថា គេឲ្យហាត់ ហើយលាក់ការណ៍ឲ្យស្ងាត់ មិនឲ្យអង្គភាពដទៃដែលនៅជិតខាង ដូចជាអង្គភាពរោងចក្រ ហើយក៏ខាងពាណិជកម្មអីហ្នឹង គេអត់ឲ្យខាងហ្នឹងដឹងទេ។ គេឲ្យហាត់នៅតាមអង្គភាព ហើយបំបែកជាក្រុមតូចៗ ហាត់នៅតាមកៀនៗចន្លោះផ្ទះ ក្នុងអង្គភាពខ្លួនឯងហ្នឹង។ គេអត់ឲ្យមានអង្គភាពណាមួយឃើញហើយដឹងអីទេ គេឲ្យហាត់តែពេលថ្ងៃល្ងាច ថ្ងៃលិចបានគេឲ្យហាត់ប្រហែលជាកន្លះម៉ោងអ៊ីចឹងទៅ។

**ស៖** ការដែលគេមិនឲ្យលោកនិយាយពីរឿងហ្នឹងៗ គឺជាករណីលើកលែង ឬក៏ថាជាទូទៅហ្នឹង គឺត្រូវតែរក្សាការសម្ងាត់អំពីការងារដែលគេប្រគល់ឲ្យពួកលោកធ្វើ?

**ឆ៖** អាហ្នឹងបើតាមខ្ញុំពិនិត្យឃើញទៅ តែខុសគេតែអង្គភាពរទេះភ្លើងហ្នឹងផង គេមិនឲ្យហាត់ -- គេមិនឲ្យនេះ គេឲ្យហាត់អ៊ីចឹង។ ដល់អង្គភាពគេដទៃទៀត អត់មានធ្វើដូចអង្គភាពរទេះភ្លើងទេ ហើយគេក៏គ្មានប្រាប់ថាហាត់ហ្នឹងដើម្បីអី ៗក៏អត់ដែរ គេគ្រាន់តែប្រាប់ថាឲ្យលាក់ការណ៍។

**ស៖** តើនៅក្នុងរយៈពេលហ្នឹង លោកធ្លាប់ទាក់ទងជាមួយក្រុមកុម្មុយនីស្តថៃដែរឬទេ? ហើយតើលោកធ្លាប់ទៅប្រទេសថៃដែរឬទេ ដើម្បីដឹកជញ្ជូនស្បៀង ឬក៏សម្ភារៈអីហ្នឹង?

[១៥:១៥:២៤]

**ឆ៖** អត់ដែលទេ ខ្ញុំមិនដែលទៅដល់ហ្នឹងទេ ព្រោះខ្ញុំខាងធ្វើផ្លូវ មិនមែនខាងដឹកជញ្ជូនផង។ ហើយធ្វើផ្លូវហ្នឹង ក៏ចន្លោះផ្លូវដែលគេចែកក្រុម ឲ្យក្រុមពួកខ្ញុំធ្វើហ្នឹង តែត្រឹមចេញពីវ៉ាបាត់ដំបងទៅលិចទៅជើងហ្នឹង បានតែ៨គីឡូម៉ែត្រទេ ហើយនិងចេញមកកើតវិញ បានតែ៨គីឡូម៉ែត្រទេ។ បើអ៊ីចឹងក្រុមកម្មករខ្ញុំហ្នឹង ដឹងតែប៉ុណ្ណឹង ដឹងតែ១៦គីឡូម៉ែត្រហ្នឹង ទៅមកទៅមក ដើរជួសជុលតែប៉ុណ្ណឹង ធ្វើតែប៉ុណ្ណឹងរហូត។

**ស៖** តើលោកបានទទួលការបណ្តុះបណ្តាលយោធាហ្នឹង រយៈពេលប៉ុន្មានដែរ រយៈពេលយូរ ឬក៏យ៉ាងម៉េច? ព្រោះថាពេលណាមួយនោះ លោកបាននិយាយថាលោកជាយោធា ហើយក្នុងពេលជាមួយគ្នាហ្នឹង លោកធ្វើការនៅខាងផ្លូវរទេះភ្លើងដែរ។ អ៊ីចឹងខ្ញុំចង់សួរលោកបញ្ជាក់ថា តើលោកជាយោធា ឬក៏ជាស៊ីវិល ជនជាស៊ីវិល ដែលគេឲ្យធ្វើការនៅខាងការងាររទេះភ្លើង ផ្លូវរទេះភ្លើង?

**ឆ៖** បាទ ជាស៊ីវិល។

**ស៖** បើខ្ញុំមិនច្រឡំទេ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ លោកបាននិយាយថា លោកធ្វើគ្រាប់បែក។ តើលោកមានចូលរួមរៀនធ្វើគ្រាប់បែក ឬក៏គ្រឿងបំផ្ទុះអីទេ?

**ឆ៖** អត់ដែរ ព្រោះខ្ញុំអត់ដែលដឹងធ្វើគ្រាប់បែកម៉េចផង កម្មកររទេះភ្លើង ទើបតែវៀតណាមចូល បានឈប់ដែរ។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក នៅចម្លើយ១២១ លោកបាននិយាយថា៖ "នៅអំឡុងរបបនោះ គឺខ្ញុំធ្វើគ្រាប់បែក ហើយគេបានចាត់តាំងឱ្យពួកខ្ញុំហ្នឹង ទៅធ្វើនៅ<ផ្នែកហ្នឹង>។" <ដូច្នេះខ្ញុំយល់ថា លោកនិយាយអំពីផ្លូវរថភ្លើងរហូតចេញពី>ក្បាលខ្មោច ទៅអូរស្រឡៅ។" អ៊ីចឹងឥឡូវលោកបញ្ជាក់ ថាអំមិញលោកបញ្ជាក់ថា លោកអត់<>ធ្វើគ្រាប់បែកទេ <លោកមិនបានផលិតគ្រឿងផ្ទុះ>ទេ។ <តើនេះជាអ្វីដែលលោកប្រាប់យើងឬ>?

[១៥:១៨:៤៣]

**ឆ៖** បាទ ខ្ញុំអត់មានពាក់ព័ន្ធអីរឿងហ្នឹងទេ។ ប៉ុន្តែគ្រាន់តែថា បើធ្វើផ្លូវរទេះភ្លើង អាហ្នឹងធ្វើមួយជួរក្បាលខ្មោចហ្នឹងមកបាត់ដំបង ហើយនិងពីបាត់ដំបងមកព្រំប្រទល់អូរស្រឡៅ។ អាហ្នឹងធ្វើតែថ្នល់ និងស្ពានរហូត។ បើរទេះភ្លើងហ្នឹង ស្ពានវាទ្រុឌទ្រោម ធ្វើស្ពាន បើផ្លូវហ្នឹងវាខូច ធ្វើផ្លូវ។ អ៊ីចឹងខ្ញុំដឹងតែខ្ញុំធ្វើផ្លូវហ្នឹងរហូត តួនាទីតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណដែលបានឆ្លើយបញ្ជាក់។ ឥឡូវខ្ញុំសូមសួរលោក ថាតើនៅក្នុងរយៈពេល <>ឆ្នាំ<ចុងក្រោយ>ហ្នឹង លោកមានធ្លាប់ទាក់ទងជាមួយនឹងសមិទ្ធិករថតកុន ដែលគាត់មកកន្លែងលោកធ្វើការហ្នឹង ពីព្រោះអីគាត់ចង់ថតកុន កុនភាពយន្តឯកសារ។ លោកមានធ្លាប់ជាប់ទាក់ទងជាមួយអ្នកថតកុនទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់អ្នកថតកុនហ្នឹង គេទៅ ១ទំនាក់ទំនងជាមួយខ្ញុំ ហើយគេឱ្យខ្ញុំហ្នឹងទៅជាមួយគេ ហ្នឹងខ្ញុំដែល។

**ស៖** លោកអាចពិពណ៌នាអំពីរូបរាងកាយអ្នកថតកុនទាំងអស់ហ្នឹងបានទេ? ហើយលោកនៅចាំឈ្មោះពួកគាត់ទេ?

**ឆ៖** ដល់ខ្ញុំស្គាល់វាមិនប្រាកដដែរ ប៉ុន្តែថាឈ្មោះ សម្បត្តិ ជាអ្នកថតកុន និងជាមួយជនជាតិម្នាក់ តែដឹងជនជាតិហ្នឹង ខ្ញុំមិនចេះហៅឈ្មោះវា មិនដឹងជាហៅយ៉ាងម៉េច អីយ៉ាងម៉េច។

**ស៖** ចុះបើខ្ញុំនិយាយឈ្មោះ រ៉ប លឹមគិន នេះ លោកចាំទេ លោកនឹកឃើញឈ្មោះគាត់ទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ដល់ពេលលោកថាអ៊ីចឹង បានខ្ញុំចាំបាន ព្រោះគេអ្នកចតជាមួយ សម្បត្តិ ហ្នឹង។

[១៥:២១:២៧]

**ស៖** តើលោកមាននៅចាំថា លោកបាន<>ជួបអ្នកចតកុនហ្នឹងនៅពេលណាដែរឬទេ? ឆ្នាំណា ខែណា?

**ឆ៖** ខ្ញុំអត់ចាំ ព្រោះវា ខ្ញុំមិនបានជាចាប់អារម្មណ៍អីធំដុំផង ប៉ុន្តែគ្រាន់តែថា បានដឹងថាពីរនាក់ហ្នឹងគេទៅថតកុន។

**ស៖** អម្បាញ់មិញនេះលោកបាននិយាយថា បើខ្ញុំយល់មិនច្រឡំទេនោះ លោកបាននិយាយថា លោកបានជូនដំណើរពួកគាត់។ អ៊ីចឹងខ្ញុំសួរលោកថា ជូនគាត់ទៅឯណា? ហើយក្នុងបំណងអ្វី? ហើយលោកបានធ្វើដំណើរជាមួយគាត់ហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** អាត្រង់ហ្នឹង ខ្ញុំមិនជាចាំបានដែរ ប៉ុន្តែគ្រាន់ថា បើថតនៅជិតៗហ្នឹង គេឲ្យខ្ញុំជួយរកកន្លែងរកអីថតអ៊ីចឹងទៅ។ ខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹង ហើយគ្រាន់តែគេទំនាក់ទំនងឲ្យថត ឲ្យអីហ្នឹង។

**ស៖** តើលោកមាននៅចាំថា លោកបានទៅប្រទេសថៃជាមួយនឹងអ្នកថតកុនទាំងអស់ហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំចាំ។

**ស៖** ហើយអ៊ីចឹងកាលនៅប្រទេសថៃហ្នឹង មានរឿងអីកើតឡើងដែរ?

**ឆ៖** អាពេលទៅដល់ហ្នឹង មិនមានរឿងអីកើតផង ប៉ុន្តែថាដល់ទៅកន្លែងមួយហ្នឹង គេសម្ភាសអ្នកពីរនាក់ដែលរួមដំណើរទៅជាមួយ សម្បត្តិ ហ្នឹង។ ហើយដល់គេសម្ភាសខ្ញុំ ខ្ញុំអត់ដឹងរឿងអីផង អត់ដឹងនិយាយអី ប៉ុន្តែគ្រាន់តែបានទៅ។

[១៥:២៤:១៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំងសម្រង់វីដេអូមួយមានចំណងជើងថា *"អេណឹមី អូហ្វ ភីប ភល"* មានលេខកូដ E186.1R នៅផ្នែកជាភាសាអង់គ្លេសគឺ<ហៅថា "ភាពយន្តបន្ថែម គឺការប្រជុំពិភាក្សាតាមសោតទស្សន៍រវាងជនរងគ្រោះ និងអ្នកប្រព្រឹត្តបទឧក្រិដ្ឋ។"> បាទគឺជាសម្រង់ដែលចាប់ផ្តើមនៅនាទី ទី០៥:២២វិនាទី។ បើអ៊ីចឹងសូមឲ្យខាង អេ.វី ចាក់បញ្ចាំងសម្រង់នេះ។

**ប្រធានអង្គជំនុំ៖**

បាទអេ.វី ចាក់ផ្សាយវីដេអូឃ្លីបលើអេក្រង់ទូរទស្សន៍ តាមសំណើសុំរបស់លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

[១៥:២៥:២០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...ខ្ញុំសូមជម្រាបសួរបងប្អូនដែលនៅខាងក្រៅប្រទេស ដែលខ្ញុំបានឮបងស្រីគាត់មានប្រសាសន៍អម្បាញ់មិញនេះ គឺខ្ញុំមានអារម្មណ៍អាណិតអាសូរដល់គាត់ ប៉ុន្តែសម័យនោះ យើងមិនអាចជួយអ្នកណាបានទេ សូម្បីតែខ្ញុំផ្ទាល់ហ្នឹង ក៏មានបងប្អូនមួយចំនួនហ្នឹង វាស្លាប់អស់ច្រើនដែរ ជាពិសេសបងប្អូនស្លាប់អស់ ដល់រស់ រស់តែខ្លួនឯងប្រហែលជាពីរបីនាក់ដែរ ដូចគ្នាដែរ បាទ។ អ៊ីចឹងខ្ញុំសូម..."*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:២៦:០៣]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ លោកសាក្សី ខ្ញុំសូមឱ្យលោកកុំប្រាប់ឈ្មោះអ្នកដែលចូលរួមក្នុងកិច្ចប្រជុំហ្នឹង បើសិនលោកស្គាល់ឈ្មោះគាត់។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកស្គាល់រូបលោកទេ នៅក្នុងឃ្លីបវីដេអូហ្នឹង? ហើយលោកអ្នកនិយាយហ្នឹងមែនទេ នៅក្នុងឃ្លីបវីដេអូហ្នឹង?

**លោក ជាល ជឿន៖**

**ឆ៖** ខ្ញុំអ្នកនិយាយ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន លោក លោកស្រីចៅក្រម យើងខ្ញុំគ្រាន់តែចង់បញ្ជាក់ថា ខាងព្រះរាជអាជ្ញាក៏ដូចជាខាងយើងខ្ញុំនេះ មើលអត់ឃើញទេនៅលើអេក្រង់នោះ។ ដូច្នេះខ្ញុំសូមអនុញ្ញាតថា ប្រសិនបើអាច ៗ ចាក់បញ្ចាំងឡើងវិញម្តងទៀតនូវខ្សែវីដេអូ គឺនៅខាងយើងខ្ញុំនេះ គឺមើលអត់ឃើញទេនៅលើអេក្រង់ទាំងអស់ គឺថាខាងព្រះរាជអាជ្ញាទាំងអស់គ្នាហ្នឹង មើលអត់ឃើញអ្វីទាំងអស់រូបភាពអម្បាញ់មិញនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ហើយខាងភាគីការពារក្តី មានបានឃើញសម្រង់វីដេអូអំមិញនេះ<ទេ>? បើសិនជាលោកអត់ជំទាស់អីទេ ខ្ញុំបន្តទៀត។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**សៈ** លោកសាក្សី តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើមានរឿងអ្វីកើតឡើងនៅក្នុងពេលប្រជុំហ្នឹង បើសិនជាលោកចាំ? យើងមើលទៅឃើញថា ម្ខាងមានអ្នកដែលនៅបរទេស ហើយម្ខាងទៀតហ្នឹង មានមនុស្សបីនាក់ដែលជាអតីតយោធា ឬក៏កម្មាភិបាលខ្មែរក្រហម។ <តើលោកចង់ឲ្យខ្ញុំនិយាយម្តងទៀត-->

[១៥:២៨:០៥]

**លោក ជាល ជឿន៖**

**ឆៈ** ខ្ញុំស្តាប់សំណួរអត់បាន។

**សៈ** លោកចង់ឲ្យខ្ញុំសួរម្តងទៀត ឬយ៉ាងម៉េច? អ៊ីចឹងខ្ញុំសួរលោកថា គេប្រជុំហ្នឹងគេមានគោលបំណងអ្វីដែរ? ក្នុងកិច្ចប្រជុំហ្នឹង យើងឃើញរូបលោកនៅក្នុងហ្នឹងហើយ អ៊ីចឹងខ្ញុំសួរថាតើគោលបំណងនៃកិច្ចប្រជុំហ្នឹងអ្វីដែរ? ហើយឃើញលោកនិយាយទៅកាន់មនុស្សមួយចំនួននោះ អ៊ីចឹងខ្ញុំសួរលោកថា លោកនិយាយទៅកាន់អ្នកណានៅក្នុងកិច្ចប្រជុំហ្នឹង?

**ឆៈ** បាទ ពេលខ្ញុំនិយាយហ្នឹង ទៅកាន់អ្នកដែលនៅក្រៅប្រទេសដែលពេលគាត់ក្តុកក្តួលពីកាលពីសម័យ៣ឆ្នាំ ដល់អ៊ីចឹងខ្ញុំគ្រាន់តែបញ្ជាក់ប្រាប់គាត់ ដែលពេលគេ -- គាត់សួរសំណួរទៅលើអ្នកពីរនាក់ដែលទៅជាមួយខ្ញុំហ្នឹង។ ដល់អ៊ីចឹងខ្ញុំគ្រាន់តែបញ្ជាក់ជូនគាត់ពីសម័យនុំង។

**សៈ** បាទ អរគុណដែលមិនបាច់ប្រាប់ឈ្មោះពួកគាត់ទេ គឺមានមនុស្សពីរនាក់នៅអង្គុយជិតលោកហ្នឹង។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើអ្នកទាំងពីរនាក់ហ្នឹង ជាអ្នកចូលរួម ឬក៏ទទួលបន្ទុកក្នុងការសម្លាប់អ្នកទោសនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យមែនទេ?

[១៥:២៩:៥៤]

**ឆៈ** បាទ អ្នកៗពីរនាក់ហ្នឹងដែលខ្ញុំអាចដឹងគាត់ខ្លះៗ ត្រឹមពេលអ្នកថតកុនទៅសម្ភាសគាត់ហ្នឹង។ តែបើកាលពីសម័យ៣ឆ្នាំ អាហ្នឹងខ្ញុំអត់ដឹងទេ ហើយខ្ញុំអត់ដែលរស់នៅជាមួយគាត់ទេ ព្រោះគាត់ពោធិ៍សាត់ ខ្ញុំនៅបាត់ដំបង។ ពេលខ្ញុំដឹងរយៈពេលក្រោយដែលត្រឹមគេទៅថតកុន ហើយសម្ភាសគាត់ពេលដែលគេសម្ភាសហ្នឹង ក៏ខ្ញុំអត់មាននៅជិតគាត់ដែរ ខ្ញុំអត់មាននៅស្តាប់គាត់និយាយ ស្តាប់អីទេ ប៉ុន្តែពេលក្រោយ គាត់ចេះតែនិយាយផ្តោយមាត់ប្រាប់មកខ្ញុំ អាហ្នឹងបានខ្ញុំដឹងប្រាកដថា គាត់ធ្វើស្អីៗហ្នឹង។

**សៈ** តើលោកមានដឹងថា គាត់ហ្នឹងបានសម្លាប់អ្នកទោស ឬក៏គាត់ហ្នឹងទទួលបន្ទុកខាងសម្លាប់អ្នកទោសដែរឬទេ?

**ឆ៖** បាទ អាហ្នឹងពេលៗក្រោយពីគេសម្ភាសគាត់មក គាត់និយាយប្រាប់ខ្ញុំអ៊ីចឹង គាត់ថាបាន គាត់បានទទួលបន្ទុកអស់ហ្នឹង។

**ស៖** ឥឡូវយើងត្រឡប់មកនិយាយអំពីសមិទ្ធករវិញម្តង អ្នកថតកុនវិញម្តង លោកនិយាយថា លោកស្គាល់គាត់។ តើនៅពេលណាមួយ គេមានស្នើថាផ្តល់លុយកាក់ខ្លះឲ្យលោក ដោយសារលោកចូលរួមថតកុនឯកសារហ្នឹងដែរឬទេ?

**ឆ៖** គេថាដែរ តែដល់ពេលគេថា ឲ្យរៀបចំរួចរាល់អស់ទៅ អាហ្នឹងគេជួយផ្តល់ឲ្យៗ។ ដល់ពេលក្រោយមក ក៏មិនដែលឃើញមានទទួលអីពីគេផង ក៏ស្ងាត់ឈឹងរហូតទល់សព្វថ្ងៃទៅ។

[១៥:៣២:២៩]

**ស៖** បាទសូមអរគុណ។ ឥឡូវខ្ញុំសូមអានឯកសារមួយ គឺសម្រង់នៃសៀវភៅមួយដែលសរសេរដោយ ជីណា <ចន> ហើយនិងថេត សម្បត្តិ <>ដែលមានចំណងជើងថា *"ប៊ឺហាញ ឌឹ ឃីល្លីងហ្វីល"* ឯកសារនេះ មានលេខកូដ E3/4202, ERN អង់គ្លេសគឺ 00757532, ជាភាសាបារាំង 00849437 ដល់38, ជាភាសាខ្មែរគឺ 00858343។ មានសរសេរដូចតទៅនេះ "រស់ ញឹម បញ្ជាទៅ ជាល <ជឿន> ជាប្រធានកង<វរសេនាធំ>ឲ្យទាក់ទងកុម្មុយនីស្តថៃ ដើម្បីឲ្យស្តុកស្រូវ និងត្រី<ងៀត> ហើយនិងរៀបចំឃ្លាំងអាវុធរហូតដល់ពេលចេញការវាយប្រហារ ហើយឲ្យបញ្ជូន<ទំនិញ>ទៅថៃពេលយប់។" នេះ<គាត់បានដឹងស្រង់នូវអ្វីដែល> ជៀល <ជឿន> ហ្នឹងក៏បាននិយាយថា ខ្ញុំខកចិត្តណាស់ ដែលផែនការយើងហ្នឹងមិនជោគជ័យ (គាត់និយាយដូច្នេះនៅក្នុងពេលសម្ភាសមួយ)។ "នៅពេលដែលខ្ញុំនៅកន្លែងដែលគេកសាងខ្ញុំនុ៎ង យើងស្តាយណាស់ អង្គាល់នុ៎ង យើងមិនបានវាយប្រហារឲ្យបានមុន ខ្ញុំសុខចិត្តងាប់<ក្នុងការប្រយុទ្ធ> ជាជាងទៅជាប់នៅក្នុងជាប់ជំរំឃុំឃាំង។" <ឥឡូវនេះលោកសាក្សី តើលោកបានឮនូវអ្វីដែលខ្ញុំទើបតែ>អានអំមិញនេះ<ទេ?> តើលោកមានបានឆ្លើយចម្លើយលោកពីមុនៗមកហ្នឹង មានស៊ីគ្នា និងត្រូវគ្នានឹងអ្វីដែលខ្ញុំទើបនឹងអានហ្នឹងទេ?

**លោក វិ៉ចទ័រ កូប៉េះ៖**

សូមអភ័យទោស។ ខ្ញុំសូម -- ខ្ញុំមិនប្រាកដថាវាជាការជំទាស់ ឬក៏ការកត់សម្គាល់ទេ។ ខ្ញុំសូមជម្រាបដល់អង្គជំនុំជម្រះផងដែរថានៅក្នុងអនុស្សរណៈរបស់ខ្លួនដែលផ្ញើជូនភាគីទាំងអស់ E29/489/1 គឺ *មេម៉ូ* ចុះថ្ងៃទី<២៧> ខែកញ្ញា ២០១៦ ទាក់ទងទៅនឹងអ្នកផលិតករភាពយន្ត លឹមគិន គឺបានសរសេរថា--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បើសិនជាលោកធ្វើការកត់សម្គាល់លើការពិត <ដែលមាននៅក្នុងសៀវភៅនោះ> ខ្ញុំគិតថាគួរតែទុកឲ្យសាក្សីនេះឆ្លើយមុនទៅ ខ្ញុំមិនចង់ឲ្យលោកជះឥទ្ធិពលទៅលើសាក្សីនោះទេ។

[១៥:៣៦:១៩]

**លោក វ៉ិចទ័រ កូប៉េ៖**

<ក៏ប៉ុន្តែគាត់មិនបាននិយាយពាក្យហ្នឹងទេ។>

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ្វីដែលខ្ញុំអាននោះវាច្បាស់ណាស់ ហើយសំណួរច្បាស់ហើយ អ៊ីចឹងសាក្សីនេះគាត់មានលទ្ធភាពឆ្លើយនឹងសំណួរខ្ញុំហើយ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមកត់សម្គាល់ទៅលើការហៅឈ្មោះអ្នកដែលជាប់ពាក់ព័ន្ធក្នុងនេះ ដោយសារជាភាសាខ្មែរហៅអត់ច្បាស់ខុសពីសំណេរនេះ គឺក្នុងនេះគឺដាក់ឈ្មោះថា ចែលឈឿន។ អ៊ីចឹងខ្ញុំសូមបញ្ជាក់មិនមែន ជាល ឈិន ទេ គឺ ចែល ឈឿន។ សូមអរគុណ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ហើយបញ្ហាដែលសួរសាក្សីហ្នឹង ថាតើសាក្សីបាននិយាយនេះឬក៏អត់? ដូច្នេះគឺវាអត់មានអីពាក់ព័ន្ធទេ ដូច្នេះសូមអនុញ្ញាតបន្តទៅមុខទៀតចុះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមរំឭកផងដែរថា ច្បាប់ដើមនៃសៀវភៅនេះជាភាសាអង់គ្លេស មិនមែនជាភាសាខ្មែរនោះទេ។ អ៊ីចឹងអ្វីដែលខ្ញុំអានហ្នឹងគឺវាមានន័យខ្លឹមសារគ្រប់គ្រាន់ហើយ។

[១៥:៣៧:២៤]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** អ៊ីចឹងលោកសាក្សី លោកចង់ឲ្យខ្ញុំអានសម្រង់ហ្នឹងម្តងទៀត ឬក៏លោកនៅចាំសំណួរខ្ញុំហើយអាចឆ្លើយបាន? សំណួរខ្ញុំសួរអម្បាញ់មិញ ខ្ញុំសួរថាអ្វីដែលខ្ញុំអានហ្នឹងវាត្រូវគ្នានឹងចម្លើយដែលលោកធ្លាប់បានឆ្លើយមកទេ?

**លោក ជាល ជឿន៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ អត់។ ហើយឈ្មោះហ្នឹងក៏ខ្ញុំមិនដែលឮផង។

**ប្រធានអង្គជំនុំ៖**

ចែល ឈឿន! ចែល ឈឿន ដែលឮទេ?

**លោក ជាល ជឿន៖**

**ស៖** បាទ អត់ដែលស្គាល់ទេ។ ខ្ញុំមិនដែលបានឮឈ្មោះហ្នឹងផង មិនថាត្រឹមមិនស្គាល់ទេ មិនដែលឮឈ្មោះហ្នឹងទៀត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូច្នេះសូមលោកឆ្លើយសំណួរសិនទៅ ថាតើលោកបាននិយាយដូចអ្វីដែលចៅក្រមទើបតែអានឲ្យលោកស្ដាប់មុននេះបន្តិចទេ គឺលោកគ្រាន់តែឆ្លើយថា លោកបាននិយាយ ឬក៏អត់បាននិយាយទៅ គឺសព្វគ្រប់ហើយ។ តើលោកចាំថា គាត់អានអីឲ្យស្ដាប់ទេអម្បាញ់មិញ ឬក៏មួយលោកចង់ឲ្យគាត់អានមួយសាទៀត?

**លោក ជាល ជឿន៖**

**ស៖** ខ្ញុំសូមអានមួយសាទៀត។

[១៥:៣៩:១១]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ សម្រង់របស់សៀវភៅ ជីណា <ចន> ហើយ ថេត សម្បត្តិ ខ្ញុំដកស្រង់៖ "វស់ ញឹម បង្រៀន ចែល ឈឿន មេបញ្ជាកងពល ឲ្យ<>ទាក់ទងជាមួយនឹងជនកុម្មុយនីស្តថៃដែលអាចទុកស្រូវត្រីងៀត និងអាវុធសម្រាប់ខ្លួន រហូតដល់ពេលវាយប្រហារ។ អ្នកទាំងនោះបញ្ជូនសម្ភារៈទៅប្រទេសថៃនៅពេលយប់។"

នេះខ្ញុំដកស្រង់ពាក្យសម្ដីរបស់ ចែល ឈឿន បាននិយាយនៅក្នុងកិច្ចសម្ភាសន៍គាត់ថា៖ "ខ្ញុំពិតជាសោកស្ដាយណាស់នៅពេលផែនការបានបរាជ័យ។ នៅពេលខ្ញុំជាប់ឃុំឃាំងក្នុងជំរំអប់រំកែប្រែ ខ្ញុំបន់ស្រន់ឲ្យពួកយើងបើកការវាយប្រហារមុន ខ្ញុំស៊ូស្លាប់ក្នុងសមរភូមិ ឲ្យតែបានអនុវត្តផែនការនេះប្រសើរជាជាងស្នាក់នៅក្នុងជំរំ។" អ៊ីចឹងខ្ញុំសួរម្ដងទៀត តើអ្វីដែលខ្ញុំអាននេះ វាត្រូវគ្នានឹងចម្លើយដែលលោកបានឆ្លើយទេ?

**ឆ៖** បាទ អត់ វាអត់ត្រូវគ្នា។

**ស៖** តើគេមានយកលោកទៅដាក់ក្នុងជំរំកែប្រែដែរឬទេ ដូចដែលមាននៅក្នុងសម្រង់ដែលខ្ញុំអានអម្បាញ់មិញនោះ? ហើយបើធ្លាប់មែននោះ ធ្លាប់គេយកទៅដាក់នៅក្នុងជំរំកែប្រែហ្នឹង តើគេយកទៅដាក់នៅពេលណាដែរ <ដោយសារមូលហេតុអ្វី>?

[១៥:៤១:០៨]

**ឆ៖** បាទ ខ្ញុំអត់ដែលជាប់នៅក្នុងជំរំកែប្រែផង ព្រោះខ្ញុំកម្មកររទេះភ្លើងទើសតែវៀតណាមចូល អត់មានដែលជាប់នៅក្នុងជំរំណាមួយទេ។

**ស៖** បាទ សូមអរគុណដែលលោកបានឆ្លើយបញ្ជាក់។ ឥឡូវនេះខ្ញុំចង់ត្រឡប់មកនិយាយអំពីហេតុការណ៍ដែលបានកើតឡើងនៅពេលដែលលោកធ្វើជាទាហាន ហើយនៅពេលដែលគេប្រគល់កាំភ្លើងឲ្យលោកមួយដើម។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ នេះគឺជាអ្វីដែលខ្ញុំរំពឹងថានឹងកើតឡើង ឥឡូវកើតឡើងមែន។ បញ្ហាគឺដូចតទៅនេះ សម្រាប់នីតិវិធីមួយនេះ គឺថាយើងស្ថិតក្នុងភាពងងឹតឈឹងតែម្តង ទាក់ទងទៅនឹងអ្វីដែលផលិតករម្នាក់បាននិយាយ <គឺថា>បុគ្គលនេះ<មិនដែលបាន>និយាយ<បែបនេះ>នោះទេ <ហើយគឺថា ថេត សម្បត្តិ បានបញ្ចូលគ្នារវាងបុគ្គលម្នាក់នេះ ជាមួយនឹងអ្នកផ្សេងទៀត>។ ដូច្នេះខ្ញុំចង់បញ្ជាក់ឲ្យបាននៅក្នុងកំណត់ត្រាប្រតិចារឹកដើម្បីឲ្យសាធារណជន<ដែលតាមដាន>ការសួរដេញដោលនេះ<បានដឹងពីអ្វីដែលកំពុងកើតឡើង>។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវី កូប៉េ បើសិនជាលោកចង់ដកស្រង់ឲ្យបានច្បាស់នូវសម្តីរបស់ រ៉ប លឹមគិន ដែល<និយាយថា ចែល ឈឿន មិនបាននិយាយអ្វីជាមួយគាត់ទេ អ៊ីចឹង>លោកប្រាប់មក។ <យើងចង់ដឹង> ខ្ញុំមិនដឹងទេ បើលោកមានឯកសារយោងច្បាស់លាស់ លោកលើកឡើងមក។

[១៥:៤២:៥៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រសិនបើលោកអនុញ្ញាតឲ្យខ្ញុំបញ្ចប់ការកត់សម្គាល់ពីមុនមក ខ្ញុំនឹងអាចនិយាយបាន គឺខ្ញុំនិយាយអំពីអនុស្សរណៈ<ដែលយោងទៅលើអ៊ីម៉ែលមួយរបស់ រ៉ប លឹមគិន >នៅថ្ងៃ<១> កញ្ញា ២០១៦ ដែលលោកបាននិយាយថា អ៊ិន តួន ហើយនិង <ជាល ជឿន គឺ "ដាក់ឈ្មោះមិនត្រឹមត្រូវលើ>

ទំព័រ<១០៤> និង<១០៦> នៃសៀវភៅ “នៅពីក្រោយវាលពិឃាដ” គឺថាគាត់អត់មានអ្វីទាក់ទងទេ។ ហើយ<គាត់>ព្យាយាមប្រាប់លោកថាអ្វីដែល ថេត សម្បត្តិ និយាយអំពី <ជាល ជឿន> គឺជារឿងខុស។ ហើយវា<ច្បាស់ណាស់>ថា ថេត សម្បត្តិ <បាន>ការដកស្រង់សម្ដីនេះ<មកឱ្យ>សាក្សី<គឺដាក់ដោយខុសទាំងស្រុង>។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំអត់មានអ៊ីម៉ែលនេះទេ ប៉ុន្តែខ្ញុំចាំថាបើតាមដែលខ្ញុំយល់ គឺថា<គាត់និយាយថា> គេដាក់ឈ្មោះខុស <ហើយគាត់បានបញ្ជាក់>ថា គាត់មិនមានសិទ្ធិអំណាចបញ្ជាក់ឈ្មោះបុគ្គលនេះតែប៉ុណ្ណោះដោយសារតែការរក្សាការសម្ងាត់។ ដូច្នេះ អានេះគឺជាអ្វីដែលខ្ញុំចាំតាមការបកស្រាយទៅលើអនុស្សរណៈ។ ប៉ុន្តែនៅក្នុងអ៊ីម៉ែលហ្នឹង មិនបាននិយាយថានរណាម្នាក់ជាអ្នកនិយាយនោះទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមលោកមេធាវីអាចលើកឡើងវិញបានទេ នៅពេលដែលដល់វេនរបស់លោកគឺលោកអាចសួរ។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

[១៥:៤៤:៣០]

**អ្នកបកប្រែ៖**

លោកប្រធានស្នើសុំឱ្យមេធាវី និង--

**លោក វ៉ិចទ័រ កូប៉េ៖**

<វាមិនសមរម្យទេ អ្វីដែលកំពុងធ្វើនេះ មិនមែនសំដៅតែលើសាក្សីនេះទេ ប៉ុន្តែក៏សំដៅលើផលិតករភាពយន្តផងដែរ។ វាត្រូវតែមានតម្លាភាពនូវអ្វីដែលកំពុងកើតឡើង។> នេះគឺជាអនុស្សរណៈដែលលោកបានដាក់នៅក្នុងអ៊ីម៉ែលជាមួយនឹង <រ៉ូប៊ីត> លឹមគិន។ <លោកបានផ្ញើទៅឱ្យភាគីទាំងអស់ហើយពេលនេះលោកនិយាយថា យើងមិនដឹង>អនុស្សរណៈ<នោះទេ។ វាជាអនុស្សរណៈរបស់លោកមិនមែន>របស់ខ្ញុំទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងមិននិយាយ<ថា យើងមិនដឹង>អំពី *មេម៉ូ*នោះទេ។ <អ្វីដែល>យើងនិយាយ<នោះគឺ>ថា

លោកនៅពេលដែលដល់វេនលោក ៗលើកអំពីចំណុចនេះទៅ យើងអត់មានហាមឃាត់លោកទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

នេះគឺជាអ្វីដែលសាក្សីត្រូវឆ្លើយទាក់ទងទៅនឹងអ្វីដែល ចេត សម្បត្តិ <សរសេរ>នៅក្នុងសៀវភៅហ្នឹង ឬមួយក៏ម៉េច?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

<គាត់ដឹងថាយើងកំពុងតែនិយាយអំពីអ្វី>។ អ៊ីចឹង<ហើយបានជា>ខ្ញុំសួរសំណួរទៅគាត់<>។

[១៥:៤៥:១៥]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** អ៊ីចឹងឥឡូវនេះខ្ញុំចូលទៅប្រធានបទថ្មី។ ខ្ញុំត្រឡប់មកនិយាយអំពីបទពិសោធន៍របស់លោក លោកសាក្សី នៅពេលដែលលោកជាទាហាន។ ហើយនៅពេលដែលគេប្រាប់ឱ្យលោកនាំទាហានទៅទទួលសម្តេចឪ លោកអាចជម្រាបជូនតុលាការបានទេ ថាហេតុការណ៍ហ្នឹងកើតឡើងនៅឆ្នាំណាដែរ? ហើយទាហានដែលលោកការពារនាំទៅទទួលសម្តេចឪហ្នឹងជាអ្នកណាដែរ?

**លោក ជាល ជឿន៖**

**ឆ៖** បាទ ពេលទាហានដែលគេឱ្យទៅការពារហ្នឹង គឺគេយកអ្នកការពារហ្នឹងទៅមុន។ ហើយគេប្រាប់ថា ការពារទាហានទទួលសម្តេច។ ដល់ពេលគេយកទាហានទទួលសម្តេចហ្នឹងទៅ ពេលទាហានហ្នឹងកំពុងតែចុះដើរ អាហ្នឹងបានឮស្នូរអាវុធបាញ់ពីក្រោយខ្នងទាហានហ្នឹង បណ្តោយជួរទាហានហ្នឹង។ ហើយបានអ្នកដែលនៅទៅការពារទាហានហ្នឹង មានគេអ្នកគ្រប់គ្រងនៅហ្នឹង គេរត់បញ្ជាទាហានដែលការពារហ្នឹងឱ្យ ៗបាញ់។ អាហ្នឹងខ្ញុំបានដឹងអ៊ីចឹង។

**ស៖** ខ្ញុំចង់ដឹងថាទាហានដែលលោកនាំទៅហ្នឹងជាអ្នកណា ជាទាហានរបស់ខ្មែរ<ក្រហម> ឬក៏ជាទាហានរបស់លន់នល់? ហើយពួកអ្នកទាំងអស់ហ្នឹងមានឋានៈ មានបុណ្យស័ក្តិអ្វីខ្លះ? ហើយមកពីខាងណាដែរ?

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោសលោកចៅក្រម ឡាវែន។ នៅក្នុងសំណួរមុននោះ លោកចៅក្រមសួរអំពីកាលបរិច្ឆេទហ្នឹង ហើយសាក្សីមិនទាន់ឆ្លើយនៅឡើយទេ។ ចំណុចនេះសំខាន់ណាស់ <ដើម្បីឱ្យយើងដឹងថាតើទាហានណាដែលគាត់និយាយនោះ>?

[១៥:៤៧:៣៩]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បាទ ឥឡូវខ្ញុំចាប់ផ្ដើមអ៊ីចឹងសួរពីថ្ងៃខែឆ្នាំហ្នឹងសិន។ ឥឡូវលោកសាក្សី តើលោកចាំទេ ថាហេតុការណ៍ហ្នឹងកើតឡើងនៅពេលណាដែរ?

**លោក ជាល ជឿន៖**

**ឆ៖** បាទ ហេតុការណ៍ហ្នឹង នៅពេលដែលខ្មែរក្រហមបានជ័យជម្នះហ្នឹងភ្លាមៗហ្នឹង នៅក្នុងអំឡុងឆ្នាំ៧៥។

**ស៖** ហើយទាហានដែលទៅទទួលសម្ដេចឪហ្នឹង ជាទាហានខាងណា? ខាងខ្មែរក្រហម ឬខាងលន់ នល់?

**ឆ៖** បាទ ទាហានលន់ នល់។

**ស៖** យូរទេក្រោយពី១៧ មេសា ៧៥មក ឬក៏ភ្លាមៗហ្នឹង? គ្រាន់តែក្រោយ១៧ មេសា ៧៥ ភ្លាមហ្នឹង គឺលោកទទួលភារកិច្ចហ្នឹង ឬក៏យូរមកហើយ ក្រោយមកយូរដែរ?

**ឆ៖** បាទ ពេលសន្តិភាពភ្លាមៗហ្នឹង ដល់ពេលហ្នឹងគេ ក៏ស្រាប់តែហេតុការណ៍ហ្នឹងកើតឡើង ព្រោះគ្រាន់តែសន្តិភាពភ្លាមៗ ដែលពេលគេជម្លៀសប្រជាជនចេញពីទីក្រុងហ្នឹង តែទាហានហ្នឹង គេៗឱ្យទៅទទួលសម្ដេច។ ហើយដូចពួកខ្ញុំ ពួកអី ដឹងតែទាហានទទួលសម្ដេច អត់មានដឹងថា ផែនការគេយកទាហានទៅធ្វើអ៊ីចឹង អត់ដឹង។

**ស៖** ទាហានហ្នឹង គាត់នៅកន្លែងណាដែរ ពីមុនហ្នឹង?

[១៥:៤៩:៥៦]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោកស្រីមេធាវី អង់តា ហ្គីសសេ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសោកស្ដាយដែលកាត់ផ្ដាច់លោកចៅក្រម។ ដោយសារតែសាក្សីគាត់ឆ្លើយចម្លើយមុនហើយ គាត់ថា គាត់និយាយពីហេតុការណ៍ដែលពាក់ព័ន្ធទៅនឹងទាហានទាំងអស់ហ្នឹង គឺភ្លាមៗក្រោយពីជ័យជម្នះថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ហើយនិងពេលជម្លៀសប្រជាជនចេញពីទីក្រុង។ ដូច្នេះតាមរយៈចម្លើយរបស់សាក្សីគឺ យើងស្ថិតនៅក្នុងអង្គហេតុនៃសំណុំរឿង០០២/០១ហើយ មិនស្ថិតនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្នុងសំណុំរឿង០០២/០២ទេ អ៊ីចឹងវាក្រៅវិសាលភាពហើយ អ៊ីចឹងអង្គជំនុំជម្រះគួរតែទាញផលវិបាក។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ៊ីចឹងរបបកម្ពុជាប្រជាធិបតេយ្យចាប់ផ្ដើមនៅពេលណា ១៧ មេសា ៧៥ ឬក៏ក្រោយហ្នឹង?

**កញ្ញា អង់តា ហ្គីសសេ៖**

ពាក់ព័ន្ធទៅនឹងបញ្ហាជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះ បើតាមដីកាបំបែកនីតិវិធីនោះ គឺបានកំណត់ពីវិសាលភាពរួចហើយថា ការជម្លៀសប្រជាជនហ្នឹង គឺវានៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ឯណោះទេ មិនមែននៅក្នុងវិសាលភាពនៃសំណុំរឿងសព្វថ្ងៃយើងនេះទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធានតើខ្ញុំបន្តទៀត ឬក៏យ៉ាងម៉េច?

[១៥:៥១:២១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! អញ្ជើញតទៀត!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** តើទាហានទាំងអស់នោះ នៅកន្លែងណាដែរ ពេលដែលគេឱ្យលោកការពារពួកគាត់ទៅទទួលសម្ដេចឪហ្នឹង?

**លោក ជាល ជឿន៖**

**ឆ៖** ទាហានហ្នឹង គេដឹកពីបាត់ដំបងមក។

**ស៖** អ៊ីចឹងលោកថា អ្នកទាំងអស់ហ្នឹងជាទាហាន លន់ នល់ លោកដឹងពីឋានន្តរសក្តិរបស់ពួកគេទេ?

**ឆ៖** បាទខ្ញុំ ត្រង់ហ្នឹងខ្ញុំដឹងមិនប្រាកដដែរ ព្រោះបើក្រោយមកបានឮអ្នកផ្សេងៗទៀតគេនិយាយថា អ្នកមានបណ្ដាស័ក្តិ អាហ្នឹងគេគ្រាន់តែនិយាយអ៊ីចឹង ប៉ុន្តែមិនដឹងជា មានស័ក្តិប៉ុន្មាន ស័ក្តិប៉ុន្មានទេ គ្រាន់តែដឹងថាអ្នកមានបណ្ដាស័ក្តិ។

**ស៖** ចុះលោកផ្ទាល់ ភារកិច្ចរបស់លោកនោះ គឺការពារទាហានទាំងអស់ហ្នឹង ឬក៏លោកត្រូវធ្វើអ្វីផ្សេង? តើតួនាទីពិតប្រាកដ ពេលដែលគេចាត់តាំងលោក គេប្រាប់ថា ឱ្យលោកធ្វើយ៉ាងម៉េចចំពោះទាហានទាំងអស់ហ្នឹង?

[១៥:៥៣:០៦]

**ឆ៖** តួនាទីដែលគេយកទៅហ្នឹង គេប្រាប់ថា ការពារទាហានទទួលសម្តេច។ គេអត់មានប្រាប់ថាយ៉ាងម៉េចទៀតផង។

**ស៖** ការពារហ្នឹង ការពារយ៉ាងម៉េច? ខ្លាចមានគ្រោះថ្នាក់ចំពោះទាហានទាំងអស់ហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ត្រង់ហ្នឹង ពេលដែលទៅហ្នឹង គឺអ្នកដែលទៅទាំងអស់ហ្នឹងឲ្យតែកូនទាហាន គឺអត់មានអ្នកណាដឹងថាទៅធ្វើអីមួយទេ។ គេគ្រាន់តែប្រាប់ថា ទៅការពារទាហានទទួលសម្តេចហ្នឹង តែដល់ពេលទាហានហ្នឹងមក នែឈ្មោះ សារឿន ហៅ រ៉េន ហ្នឹង គេនាំគ្នាគេ និងបក្ខពួកគ្នាគេច្រើននាក់ គេបាញ់ពីក្រោយបណ្តោយជួរទាហានមក បានគេស្រែកបញ្ជាឲ្យអ្នកទាំងអស់ហ្នឹងបាញ់ទាំងអស់គ្នាអ៊ីចឹងបណ្តោយទៅ។ ហើយពេលនោះ ខ្ញុំដែលខ្ញុំចូល ពេលដែលរយៈពេលខ្លី ពេលសន្តិភាពហើយហ្នឹង បានខ្ញុំទៅកឿងជាប់ត្រឹមអូរស្រឡៅហ្នឹង ខ្ញុំអត់ដែលប្រយុទ្ធដែលអីទេ ដល់ពេលអ៊ីចឹងខ្ញុំភ័យស្លន់ស្លោខ្លួនឯងហ្នឹង បានមានអនុសេនាធំគេម្នាក់មកបញ្ជា ហើយគេទាត់ ១ខ្ញុំ បញ្ជាខ្ញុំ។ តែដល់ពេលខ្ញុំសម្លឹងមើលទៅទាហានទាំងអស់ហ្នឹងគេបាញ់ដួលអស់ហើយ។ ហើយខ្ញុំក៏គេសម្លុត គេទាត់ខ្ញុំ គេថាចុះមិត្តឯងម៉េចមិនបាញ់ ម៉េចមិនបើកសោបាញ់។ ដល់ពេលខ្ញុំបើកសោបាញ់ហ្នឹង ទាហានហ្នឹងដួលអស់ហើយ ខ្ញុំចេះតែបាញ់១ឲ្យតែឮស្នូរនឹងគេដែរទៅ អស់គ្រាប់មួយបង់នឹងគេដែរទៅ។ ប៉ុន្តែមុននឹងបានបាញ់ហ្នឹង គេទាត់ផងអីផង ព្រោះខ្លួនអត់ដែលប្រយុទ្ធ វាភ័យ ឮស្នូរអាវុធ វាខ្លាំងពេក។ វារកតែនឹងសោកាំភ្លើងហ្នឹងមិនឃើញទៀត។

[១៥:៥៥:៥៦]

**ស៖** ដើម្បីឲ្យខ្ញុំយល់កាន់តែច្បាស់ ទាហានដែលលោកនាំទៅហ្នឹង មានកាំភ្លើងទេ? ខ្ញុំចង់សួរថាតើទាហានលន់នល់ហ្នឹង មានកាំភ្លើងទេ ឬក៏មានតែទាហានខ្មែរក្រហមទេ ដែលមានកាំភ្លើងនោះ?

**ឆ៖** បាទ ពេលហ្នឹងមានតែទាហានខ្មែរក្រហមទេ ដែលមានកាំភ្លើង បើទាហានលន់នល់ មានតែសម្លៀកបំពាក់ អត់មានអាវុធជាប់ខ្លួនទេ។

**ស៖** ពេលនុ៎ង តើលោកឃើញគេដឹកទាហាន លន់ នល់ហ្នឹង ប៉ុន្មាននាក់ដែរ?

**ឆ៖** ទាហានហ្នឹងមិនដឹងជាប៉ុន្មានទេ ខ្ញុំស្មានវាមិនត្រូវដែរ តែបើតាមការកាត់ស្មានរបស់ខ្ញុំដែលឃើញគេឲ្យចុះដើរមកហ្នឹង បើតាមខ្ញុំស្មានមើលទៅ ប្រហែលជា៥០នាក់ហើយ ទាហានហ្នឹង។

**ស៖** គេដឹកហ្នឹង ដឹកតាមឡានអីដែរ? ដឹកតាមឡានកាំមីញ៉ុង ឬក៏យ៉ាងម៉េច? ហើយបើថាដឹកហ្នឹង តាមឡានកាំមីញ៉ុង តើមានប៉ុន្មានឡានដែរ?

**ឆ៖** បាទ ពេលគេដឹកតាមឡានមកហ្នឹង ខ្ញុំអត់មានបានឃើញឡាន ឃើញអីនឹងគេទេ ស្រាប់តែគេឲ្យទាហានហ្នឹងចុះដើរពីផ្លូវជាតិលេខ៥ឡើងទៅផ្លូវ តាមផ្លូវ៦៤ហ្នឹងទៅភ្នំធិបតី។

**ស៖** ចុះក្រោយមកនោះ លោកដឹងថា គេធ្វើយ៉ាងម៉េចចំពោះសាកសពទាហាន លន់ នល់ ដែលគេសម្លាប់ចោលហ្នឹង?

**ឆ៖** ក្រោយមកខ្ញុំអត់ដឹងគេធ្វើយ៉ាងម៉េចផង គ្រាន់តែហេតុការណ៍ហ្នឹងកើតឡើងភ្លាមអ៊ីចឹងទៅ ហើយគេដេញទ័ពដែលគេឲ្យការពារហ្នឹងចេញភ្លាម។ គេអត់ឲ្យនៅហ្នឹងផង គេឲ្យមកឯផ្លូវជាតិនេះវិញ ហើយគេឲ្យឡើងឡានមកមោងណោះ។

[១៥:៥៩:០៦]

**ស៖** តើគេធ្វើហ្នឹងធ្វើតែម្ដង ហើយតែមួយថ្ងៃទេ ឬក៏ច្រើនដង ហើយច្រើនថ្ងៃ?

**ឆ៖** ខ្ញុំដឹងតែម្ដងហ្នឹង។

**ស៖** ទោះបីជាលោក<មិន>ធ្លាប់<ចូលរួម ឬក៏ឃើញ>ក៏ដោយចុះ <តើ>លោកធ្លាប់ឮគេនិយាយថា មានហេតុការណ៍ដឹកទាហាន លន់ នល់ បែបហ្នឹងកើតឡើងទៀតទេ?

**ឆ៖** អត់ ខ្ញុំអត់ដែលដឹង ហើយអត់ៗដែលឮ ព្រោះពេលដែលគេយកខ្ញុំមកដល់មោងហ្នឹង ថ្ងៃមួយ ខ្ញុំសួរគេ ខ្ញុំសួរមនុស្សដែលខ្ញុំស្គាល់ ដែលឈ្មោះ ឌឿន ហ្នឹង ខ្ញុំសួរថា "ចុះអាម៉េចបានគេយកទាហានទៅធ្វើអ៊ីចឹង គេប្រាប់ខ្ញុំថា ចុះម៉េចមិត្តឯងម៉េចក៏ចង់ដឹងទូលំទូលាយម្ល៉េះ?" ដល់អ៊ីចឹងខ្ញុំនឹកឃើញតែសំណួរខ្ញុំវាខុស ខ្ញុំអត់ហ៊ានសួរដេញទៅមុខទៀត ខ្ញុំនៅស្ងៀម។ ហើយរយៈពេលក្រោយមកបានគេដកខ្ញុំទៅធ្វើកម្មកររទេះភ្លើងទៅ។ គេអត់មានឲ្យខ្ញុំហ្នឹងនៅក្នុងជួរកងទ័ពអីនឹងគេទៀតទេ។ គេដកយកទៅឲ្យធ្វើកម្មកររទេះភ្លើង ប៉ុន្តែពេលដែលទៅហ្នឹង ក៏គេអត់ទាន់មានដកអាវុធ ដកអីពីខ្លួនទេ គឺគេឲ្យយកទៅទាំងអស់ ប៉ុន្តែទៅដល់កន្លែងរទេះភ្លើងនៅបាត់ដំបងចូលជាកម្មករហ្នឹង អាហ្នឹងបានគេបានប្រាប់ខ្ញុំថា ឲ្យយកអាវុធដាក់ឃ្លាំង ហើយខ្ញុំសួរគេយកដាក់ឯណាទៅបង? គេថា យកមកដាក់ផ្ទះខ្ញុំមក។ ខ្ញុំក៏យកអាវុធហ្នឹងទៅដាក់ឲ្យគេនៅនឹងផ្ទះគេទៅ។ ហើយទៅ ក៏ខ្ញុំនៅរស់នៅជាកម្មករធ្វើផ្លូវដែកហ្នឹងរហូតទល់វៀតណាមចូលហ្នឹង។

[១៦:០១:៣៥]

**សៈ** ពេលដែលលោកធ្វើការជាកម្មករផ្លូវដែក លោកមានកត់សម្គាល់ឃើញថា មានអ្នកណាត្រូវបានចាប់ខ្លួន ឬក៏មានអ្នកណាបាត់ខ្លួនទេ? ហើយប្រសិនបើលោកសង្កេតឃើញអ៊ីចឹងមែន គឺចាប់ពីពេលណា ដែលលោកបានឃើញមានមនុស្សបាត់ខ្លួន ឬក៏ត្រូវបានចាប់ខ្លួននោះ?

**ឆៈ** ពេលខ្ញុំនៅកម្មកររទេះភ្លើងហ្នឹង ពេលមុនដំបូង មិនដឹងជាថ្ងៃប៉ុន្មាន ខែប៉ុន្មានហើយ ខ្ញុំក៏អត់បានគិតថា វាក្នុងអំឡុងឆ្នាំណាដែរ។ តែឈ្មោះ ភាព ដែលខ្ញុំយកកាំភ្លើងទៅដាក់ឲ្យគាត់ ដែលគាត់ប្រាប់ថា ឲ្យយកអាវុធដាក់ឃ្លាំងហ្នឹង ឈ្មោះហ្នឹងគេយកទៅមុន បាត់មុន បាត់ខ្លួនមុនគេ ប៉ុន្តែបាត់យប់មិនមែនថ្ងៃទេ។ តែដល់តែព្រឹកឡើងបានប្រពន្ធឈ្មោះ ភាព ហ្នឹងថា គេចាប់ប្ដីគាត់យកទៅបាត់ហើយ។ ដល់រយៈពេលក្រោយមក តានិល ដែលគាត់ទទួលខុសត្រូវធំជាងគេនៅក្នុងស្ថានីយរថភ្លើងចាប់ពីព្រំប្រទល់ស្វាយដូនកែវ ទល់ប៉ោយប៉ែតហ្នឹង ដែលគាត់គ្រប់គ្រងរួមហ្នឹង បាត់ខ្លួនមួយទៀត។ ដល់បាត់ខ្លួនហ្នឹង ប៉ុន្តែតាហ្នឹង គេថា ហៅទៅរៀន ដល់ពេលទៅរៀនហ្នឹង វាទៅបាត់រហូតទៅ។ ដល់ពេលក្រោយមក ក៏គេឲ្យឈ្មោះ តាហឿន ហៅ ម៉ូម នៅពោធិ៍សាត់នេះ គាត់ត្រឡប់ទៅទទួលខុសត្រូវរួមនៅកន្លែងបាត់ដំបងហ្នឹង។ ហើយមិនដឹងជាក្នុងអំឡុងឆ្នាំណាដែរ តែមុនៗរៀតណាមចូលរយៈពេលខ្លីដែរហើយ ដែលគាត់បាត់ខ្លួនដែរ គេឲ្យទៅរៀនហ្នឹង ក៏ទៅបាត់ខ្លួនដែរ រហូតដល់សព្វថ្ងៃដែរទៅ។ ហ្នឹងខ្ញុំដឹងបានត្រឹមបីនាក់ហ្នឹង ដែលបាត់ខ្លួនមិនដឹងជាបាត់ទៅណាមកណឺ អាហ្នឹងបាត់រហូតៗតែម្ដង។

**សៈ** លោកអាចជម្រាបជូនតុលាការបានទេថា តើការបាត់ខ្លួនដំបូងហ្នឹង គឺកើតឡើងមុនពេលដែល តាម៉ុក មកដល់ភូមិភាគពាយ័ព្យមែនទេ? ហើយបើលោកចាំច្បាស់នុ៎ង ថាតើពេលណាដែលមានមនុស្សបាត់ខ្លួនដំបូងនោះ?

[១៦:០៤:២៣]

**ឆៈ** ពេលដែលឈ្មោះ ភាព បាត់ខ្លួនហ្នឹង មុនពេល តាម៉ុក ទៅ។ ហើយ តានិល ដែលបាត់ខ្លួនហ្នឹងក៏បាត់ខ្លួនមុន តាម៉ុក ទៅដែរ។ ដល់ពេលក្រោយដែលឮសូរឈ្មោះ តាម៉ុក ទៅដល់ភូមិភាគពាយ័ព្យហ្នឹងបាត់ខ្លួន តាម៉ូម ទៀត។ ហ្នឹងក្រោយគេ តាម៉ូម ហ្នឹងគាត់បាត់ក្រោយគេ ពេលដែល តាម៉ុក ទៅគ្រប់គ្រងនៅភូមិភាគនុ៎ង។

**សៈ** លោកធ្លាប់ជួប តាម៉ុក ទេ? ហើយលោកធ្លាប់ស្ដាប់សុន្ទរកថា ឬក៏សេចក្ដីថ្លែងការអីរបស់ តាម៉ុក ទេ?

**ឆៈ** បាទ ខ្ញុំអត់ដែលជួបគាត់ផង។ ខ្ញុំបានតែឮតែឈ្មោះ ហើយនិងឮថាទៅ ហើយមិនដែលឮ

-- មិនដែលបានទៅស្តាប់គាត់ថ្លែងការណ៍អីទេ។ ហើយក៏សូម្បីតែមុខមាត់គាត់ ក៏អត់ស្គាល់ដែរ ឮតែឈ្មោះថាទៅៗ វាមិនដឹងគាត់នៅកន្លែងណា អត់ដឹងដែរ។

**ស៖** សំណួរចុងក្រោយលោកប្រធាន។ ពេលដែលគេចាប់ខ្លួនមនុស្ស <តើ>គេ<មាន>កោះហៅអ្នកផ្សេងមក ហើយគេប្រកាសប្រាប់ថា អ្នកដែលគេចាប់ទៅហ្នឹងគឺសុទ្ធតែជាជនក្បត់។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលៗដែលបាត់ខ្លួនហើយ ហ្នឹងបានគេមកប្រកាសថា អ្នកហ្នឹងក្បត់។ ហ្នឹងអាហ្នឹងបានដឹងថាអ៊ីចឹង ប៉ុណ្ណឹងទេ។ គេថាអ្នកហ្នឹងសុទ្ធតែក្បត់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ លោកប្រធានខ្ញុំគិតថា ដល់ពេលសមល្មមនឹងឈប់សម្រាកហើយ។

[១៦:០៦:៤៣]

**ប្រធានអង្គជំនុំ៖**

អរគុណៗលោកសាក្សី។ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៧ ខែតុលា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ជាល ជឿន បញ្ចប់ ហើយនឹងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1037 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកសាក្សី។ សក្ខីកម្ម -- សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សី នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឱ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយទៀត។ ដូចគ្នានេះដែរ គឺអង្គជំនុំជម្រះអញ្ជើញលោកស្រីមេធាវី សុក សុជាតា មកប្រឹក្សាសាក្សីរូបនេះនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយទៀត។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅ ហើយនិងអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃចន្ទ នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី១៧ ខែតុលា ឲ្យមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៨នាទី)*